ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

**អង្គជំនុំជម្រះសាលាដំបូង**

Trial Chamber
Chambre de Premiere instance

# <u>កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី</u>
# <u>ជំនុំជម្រះក្តីនៅដំណាក់កាលពីរ</u>

**<u>សាធារណៈ</u>**

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦**

**ម៉ោង ០៩:០៣នាទី**

**សវនាការលើកទី៤៨៧**

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 16-Feb-2017, 14:06
CMS/CFO: Sann Rada

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ក្លូឌា ហ្វេនស៍
*(Judge Claudia FENZ)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ម៉ាទីន ខារ៉ុបគីន (បម្រុង)
*(Judge Martin KAROPKIN)*

**ក្រឡាបញ្ជីសាលាដំបូង៖**

កញ្ញា ស្តាវរ៉ូឡា ប៉ាប៉ាដូពូឡូស
*(Ms.Stavoroula PAPADOPOULOS)*

កញ្ញា ជា ស៊ីវហ័ង

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក នីកូឡាស គូមជែន
*(Mr. Nicolas KOUMJIAN)*

លោក ស្រ៊ា រតនៈ

លោក សេង លាង

លោក ឌេល លីសាក់ *(Mr. Dale Lysak)*

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក លីវ សុវណ្ណា

លោក វ៉ិចទ័រ កូប៉េ(*Mr.Victor KOPPE)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

កញ្ញា អង់តា ហ្គីសសេ *(Ms. Anta GUISSE)*

**មេធាវីប្រចាំការលោក ខៀវ សំផន៖**

លោកស្រី ទូច វរល័ក្ស

លោក ខលវីន សោនដឺស៍

*(Mr. Calvin SAUNDERS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី ម៉ារី ហ្គីរ៉ូដ៍*(Ms.Marie GUIRAUD*

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុំ អរុណ

## បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ក្លូឌា ហ្វេនស៍ | អង់គ្លេស |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក នីកូឡាស គូមជែន | អង់គ្លេស |
| លោក ឌេល លីសាក់ | អង់គ្លេស |
| លោក វ៉ិចទ័រ កូប៉េ | អង់គ្លេស |
| កញ្ញា អង់តា ហ្គីសសេ | បារាំង |
| លោក ពេជ អង្គ | ខ្មែរ |
| លោក ស៊ិន អ៊ឹង (2-TCW-1069) | ខ្មែរ |
| លោក នួន ត្រិច(2-TCW-1060) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី៖ លោក ស៊ិន អ៊ុំ** (2-TCW-1069)


សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី ........................................ ទំព័រ ៣

សួរដោយលោក នីកូឡាស គូមជែន ផ្តើមពី........................................ ទំព័រ ១៤

សួរដោយលោក ពេជ អង្គ ផ្តើមពី ........................................ ទំព័រ ៥៤

សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៥៩

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី ........................................ ទំព័រ ៦៥


**ការសួរសំណួរទៅសាក្សី៖ លោក នួន ត្រិច/ទេស ត្រិច** (2-TCW-1060)


សួរដោយប្រធានអង្គជំនុំ ផ្តើមពី ........................................ ទំព័រ ៦៨

សួរដោយលោក វ៉ិចទ័រ កូប៉េ ផ្តើមពី........................................ ទំព័រ ៧១

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៣:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ សវនាការនៅថ្ងៃនេះ អង្គជំនុំជម្រះធ្វើសវនាការបន្តស្តាប់សក្ខីកម្មសាក្សី ស៊ិន អ៊ឹង បញ្ចប់ ហើយនិងមានសាក្សីបម្រុង 2-TCW-1060។

ក្រឡាបញ្ជីសវនាការ កញ្ញា ជា ស៊ីវហ៊ង ឡើងរាយការណ៍អំពីស្ថានភាពវត្តមាន អវត្តមានភាគី និងបុគ្គលដែលអង្គជំនុំជម្រះកោះអញ្ជើញឲ្យចូលរួមនៅក្នុងកិច្ចដំណើរការសវនាការថ្ងៃនេះ។

**ក្រឡាបញ្ជី៖**

សូមគោរពលោកប្រធាន សម្រាប់សវនាការនៅថ្ងៃនេះ ក្រឡាបញ្ជីកត់សម្គាល់ឃើញថា គ្រប់ភាគីទាំងអស់នៃរឿងក្តីនេះ មានវត្តមាន។ លើកលែងតែលោក សុន អរុណ មេធាវីជាតិការពារក្តីឲ្យលោក នួន ជា ដែលបានជូនដំណឹងមកថា នឹងអវត្តមាននៅសវនាការថ្ងៃនេះ ដោយមូលហេតុផ្ទាល់ខ្លួន។ ដោយឡែកលោក នួន ជា មានវត្តមាននៅបន្ទប់ឃុំខ្លួនខាងក្រោមសាលសវនាការនេះ ដោយលោកស្នើសុំលះបង់សិទ្ធិមានវត្តមានដោយផ្ទាល់ពីបន្ទប់សវនាការនៅថ្ងៃនេះ។ លិខិតលះបង់សិទ្ធិរបស់លោក នួន ជា បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។

ដើមបណ្តឹង -- សាក្សីដែលត្រូវមកផ្តល់សក្ខីកម្មបន្តនៅថ្ងៃនេះគឺលោក ស៊ិន អ៊ឹង។ សាក្សី និងមេធាវីប្រឹក្សាលោកស្រី សុក សុជាតា មានវត្តមានរួចហើយនៅក្នុងបន្ទប់សវនាការនេះ។ ហើយនៅថ្ងៃនេះដែរ មានសាក្សីបម្រុងមួយរូបដែលមានរហស្សនាម 2-TCW-1060។ សូមអរគុណលោកប្រធាន។

[០៩:០៤:៤០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសម្រេចលើសំណើសុំរបស់ជនជាប់ចោទ នួន ជា ជាមុនសិន។ អង្គជំនុំជម្រះបានទទួលលិខិតសុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ ក្នុងបន្ទប់សវនាការនេះ របស់ជនជាប់ចោទ នួន ជា ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ ដែលបានបញ្ជាក់ថា ដោយគាត់មានបញ្ហាសុខភាព ឈឺក្បាល ឈឺចង្កេះ មិនអាចអង្គុយយូរបាន មិនអាចផ្តង់អារម្មណ៍បានយូរ និងដើម្បី

មានលទ្ធភាពចូលរួមសវនាការនៅថ្ងៃខាងមុខឲ្យមានប្រសិទ្ធភាព ខ្លួនសុំលះបង់សិទ្ធិចូលរួម និងមានវត្តមានដោយផ្ទាល់នៅក្នុងបន្ទប់សវនាការនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦។

បានឃើញកំណត់ហេតុពិនិត្យសុខភាពជនជាប់ចោទ នួន ជា ដែលធ្វើឡើងដោយគ្រូពេទ្យប្រចាំការ ពិនិត្យព្យាបាល ថែទាំសុខភាពជនជាប់ចោទនៅ អ.វ.ត.ក ចុះថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៦ បានកត់សម្គាល់ពីស្ថានភាពសុខភាពរបស់លោក នួន ជា នៅថ្ងៃនេះថា មានអាការៈឈឺចង្កេះជាប្រចាំ។ ពេលអង្គុយយូរកាន់តែឈឺខ្លាំង និងបានផ្តល់អនុសាសន៍ថា សុំឲ្យអង្គជំនុំជម្រះ អនុញ្ញាតឲ្យលោក នួន ជា ចូលរួមតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតក្រោមសាលសវនាការនេះ។

ផ្អែកលើមូលដ្ឋាននេះ និង យោងតាមបទប្បញ្ញត្តិនៃវិធាន៨១(៥) នៃវិធានផ្ទៃក្នុង អ.វ.ត.ក អង្គជំនុំជម្រះអនុញ្ញាតឲ្យជនជាប់ចោទ នួន ជា ចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយពីបន្ទប់ឃុំខ្លួនមួយស្ថិតក្រោមសាលសវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

[០៩:០៥:៥៥]

ឲ្យបុគ្គលិកផ្នែកសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ នួន ជា អាចចូលរួម និង តាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងអំឡុងពេលនៃកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ។

បាទតទៅនេះ អង្គជំនុំជម្រះមិនដឹងទេថា ការបែងចែកពេលវេលារវាងសហមេធាវីការពារក្តីយ៉ាងម៉េចទេ លោកមេធាវី វ៉ិចទ័រ កូប៉េ អាចបញ្ជាក់បានដែរទេ? ព្រោះសហមេធាវីការពារក្តីទាំងពីរក្រុមនៅពេលមួយវគ្គ មួយវគ្គនៃថ្ងៃសវនាការទៀត។ ហើយជាគោលការណ៍គឺមេធាវីការពារក្តី លោក ខៀវ សំផន នឹងសួរក្រោយគេបង្អស់នៃភាគីផ្សេងទៀត ក្នុងរឿងក្តីនេះ។

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ជម្រាបសួរលោកប្រធាន។ ខ្ញុំគិតថា ខ្ញុំប្រើពេលវេលាពីរភាគបីនៃពេលវេលាសម្រាប់ថ្ងៃនេះ។ ហើយសល់ពីនោះ គឺថាសម្រាប់ក្រុមមេធាវីការពារក្តី ខៀវ សំផន ក្រោយពេលសហព្រះរាជអាជ្ញា និងសហមេធាវីនាំមុខបញ្ចប់ការតាំងសំណួររបស់ខ្លួន។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញ!

ផ្តល់វេទិកាជូនទៅមេធាវី នួន ជា។ សូមអញ្ជើញ!

[០៩:០៧:១១]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ អរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរបន្តដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** អរុណសួស្តីលោកសាក្សី។ ខ្ញុំសូមបន្តសួរសំណួរទៅកាន់លោកខ្លះៗទៀតនៅព្រឹកនេះ។ កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន យើងបាននិយាយគ្នាអំពី ហេង សំរិន, សោ ភឹម។ ហើយ សោ ភឹម នេះបានបញ្ជាទៅ ហេង សំរិន ឱ្យប្រមូលកម្លាំង។ ខ្ញុំមានសំណួរពីរបីសួរជាប់ពាក់ព័ន្ធទៅនឹងលោក ហេង សំរិន។ នៅពេលនោះ នៅពេល សោ ភឹម បញ្ជាទៅកាន់ ហេង សំរិន គឺថា ហេង សំរិន ហ្នឹង គាត់នៅតែជាមេបញ្ជាការកងពលលេខ៤នៅឡើយទេ នៅពេលនោះ តើត្រឹមត្រូវដែរឬទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំសុំឆ្លើយ គឺពិត។

**ស៖** នៅពេលនោះ តើលោកដឹងទេថា អ្នកណាជាអ្នក ជាមេបញ្ជាការទី២ ឬក៏ថាជាអនុមេបញ្ជាការរបស់លោក ហេង សំរិន?

**ឆ៖** បាទ ខ្ញុំសុំឆ្លើយ។ កាលនុំងខ្ញុំមិនដឹងទេ ខ្ញុំមិនស្គាល់ទេ គ្រាន់តែថា មកជួបតែថ្ងៃនុំង ឃើញតែលោក ហេង សំរិន ហ្នឹង។ បើក្រៅពីនេះ ខ្ញុំអត់ស្គាល់ទេ។ សូមចប់។

[០៩:០៩:០១]

**ស៖** ជួយកែតម្រូវខ្ញុំផង បើខ្ញុំមិនយល់ខុស។ ប៉ុន្តែលោកប្រាប់ទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ថា <លោកបានឃើញ សោ ភឹម និង> ហេង សំរិន ជួបគ្នាញឹកញាប់<ណាស់>។ ត្រឹមត្រូវដែរឬទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

បើសិនណាជាលោកយោងទៅឯកសារមកពីមជ្ឈមណ្ឌលឯកសារកម្ពុជា សូមផ្តល់លេខឯកសារយោងផង ដើម្បីឱ្យវាងាយស្រួល លោកមេធាវី។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**សៈ** <ពិតប្រាកដណាស់> គឺឯកសារ E3/10716, ERN ជាភាសាអង់គ្លេស 01353341, ខ្មែរ 01340556 និងបារាំង 01345494។ នេះគឺជាចម្លើយរបស់គាត់ឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា។ "សួរ៖ នៅពេលនោះ តើតា ហេង សំរិន ជា<មេ>បញ្ជាការកងពលលេខ៤ឬ? ហើយលោកឆ្លើយថា៖ ជាប្រធានកងពលលេខ៤។ សួរ៖ លោកពូធ្លាប់យកសំបុត្រទៅជូនគាត់ផ្ទាល់ដែរទេ? លោកឆ្លើយថា៖ ខ្ញុំឧស្សាហ៍<ហូប>បាយទឹកជាមួយគាត់ដែរ។ សួរ៖ ធ្លាប់បាយទឹកជាមួយគាត់ដែរ? ឆ្លើយ៖ ហ្នឹងហើយ បាយទល់មុខគ្នា។ សួរ៖ គាត់មានដែលនិយាយអីទេ? ឆ្លើយ៖ ធ្លាប់បេះទាំងខ្នុរយកទៅផ្ញើខ្ញុំ។"

ហើយលោកបន្តឆ្លើយជាច្រើនសំណួរនៅខាងក្រោមទៀត។ ដូច្នេះលោកសាក្សី ចំណុចនេះហាក់បីដូចជាបញ្ជាក់ឲ្យឃើញថា លោកនេះស្គាល់ ហេង សំរិន ច្បាស់ណាស់ <ហើយក៏បានធ្លាប់ជួបគាត់ជាញឹកញាប់។> ហើយលោកដឹងថា សោ ភឹម បានបញ្ជាឲ្យគាត់ប្រមូលកម្លាំង<ទ័ព> ត្រឹមត្រូវដែរទេ?

[០៩:១១:០៩]

**លោក ស៊ិន អ៊ឹង៖**

**ឆៈ** បាទ ខ្ញុំសូមឆ្លើយ កាលដែលខ្ញុំនៅហ្នឹងគឺ ធ្លាប់ទៅមែនកាលនៅនុំ្នង។ ដល់ពេលបែកនិរតីចូលទៅចាប់ទៅ វាបាត់ជាប់ បាត់ជួបគ្នារហូតមក ទាល់តែសព្វថ្ងៃហ្នឹងតែម្តង។ សូមបញ្ចប់។

**សៈ** ខ្ញុំសូមចូលទៅសំណួរខាងដើមរបស់ខ្ញុំ។ តើលោកដឹងទេថា អ្នកណាជាមេបញ្ជាការទី២នៃកងពលលេខ៤?

**ឆៈ** បាទ ខ្ញុំមិនស្គាល់ច្បាស់ទេ ព្រោះខ្ញុំកាលនុំ្នង មានអ្នកណាគេប្រាប់ ខ្ញុំគ្រាន់តែទៅហ្នឹង ទៅពីរនាក់ ជូនតែគេអ្នកចាស់ៗទេ បើគេចាស់ហ្នឹងគេស្គាល់ តែគេស្លាប់បាត់អស់ហើយ។ ខ្ញុំទៅហ្នឹងសម្រាប់តែទៅពីរនាក់ ដោយប្រដាប់ដោយអាវុធជំនាន់នោះ ព្រោះខ្លាច ផ្លូវសុទ្ធតែព្រៃ។ បាទ ប៉ុណ្ណឹងសូមបញ្ចប់។

**សៈ** ចម្លើយរបស់លោកឆ្លើយទៅមជ្ឈមណ្ឌលឯកសារកម្ពុជា ERN អង់គ្លេស 013-- តាមការពិតទៅ គឺទំព័រដដែល ដូចខ្ញុំលើកឡើងអម្បាញ់មិញទេ ឯកសារដដែល។ នៅពេលដែលលោកនិយាយអំពីលោក ហេង សំរិន នេះ លោកក៏និយាយអំពីមនុស្សម្នាក់ឈ្មោះ ហេង គីម។ កាលពីសប្តាហ៍មុនយើងបានលើកឈ្មោះនេះយកមកនិយាយខ្លះៗដែរថា គីម ជាមេបញ្ជាការកងពលលេខ៥។ តើត្រឹមត្រូវ

ដែរឬទេ ថានៅពេលមួយនោះ គីម គឺជាអនុមេបញ្ជាការកងពលលេខ៤ទេ មុននឹងគាត់ក្លាយទៅជាមេបញ្ជាការកងពលលេខ៥ ត្រឹមត្រូវដែរឬទេ?

**ឆ៖** ឈ្មោះ គីម ហ្នឹង ពីមុនខ្ញុំមិនស្គាល់ទេ ដល់តែពេលខ្ញុំគ្រាន់តែឮក្រោយមកដែលពេលជួបឧបទ្ទវហេតុហ្នឹង ឮតែថា កងពលលេខ៥។ បើថាពីមុនខ្ញុំមិនស្គាល់ទេ។ សូមបញ្ចប់។

[០៩:១៣:៣៥]

**ស៖** ហេតុផលដែលខ្ញុំសួរលោកពីគាត់នេះ ពីព្រោះមានសម្រង់មួយនៅក្នុងសៀវភៅមួយក្បាលដែលសរសេរដោយអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលី ដែលបានផ្តល់សក្ខីកម្មក្នុងឋានៈជាអ្នកជំនាញរយៈពេលប៉ុន្មានខែមុននេះ។ ខ្ញុំសូមដកសម្រង់របស់គាត់នេះ ឱ្យច្បាស់លាស់តែម្តង ខ្ញុំយោងទៅឯកសារ E3/10699 ERN អង់គ្លេស 01335197 មានតែ ERN ជាភាសាអង់គ្លេសទេ។ នេះគឺអ្វីដែលអ្នកនិពន្ធរូបនេះបានសរសេរ ហើយខ្ញុំនឹងសួរទៅលោក តើលោកយល់ដូចម្តេចដែរ? សូមដកស្រង់៖ "យោងទៅតាមវរសេនីយ៍ម្នាក់មកពីកងទ័ពកម្ពុជាប្រជាធិបតេយ្យ ដែលបានរត់គេចខ្លួនទៅប្រទេសថៃនៅខែកញ្ញា ឆ្នាំ១៩៧៨ នោះ<គឺ> ហេង សំរិន មានគោលបំណងធ្វើរដ្ឋប្រហារប្រឆាំងទៅនឹងរដ្ឋបាលទីក្រុងភ្នំពេញនៅខែមេសាមុន។ ក៏ប៉ុន្តែអនុបញ្ជាការរបស់ហេង សំរិន កងពលលេខ៤នេះ ដែលមានមូលដ្ឋាននៅកំពង់ចាម បានព្រមានទៅរដ្ឋាភិបាល ហើយក៏ផែនការហ្នឹង ក៏បានកម្ទេចទៅ។ ហេង សំរិន នេះគឺជាក្រុមធំ<មួយ>ក្នុងចំណោមក្រុមកងទ័ពដែល<គាំទ្រវៀតណាម នៅក្នុងជួរបក្សកុម្មុយនីស្តកម្ពុជា ហើយក្រុមនេះបាន>រត់ទៅវៀតណាម <ជាមួយនឹងទាហាន ព្រមទាំងសព្វាវុធមួយចំនួន>។" តើចំណុចទាំងអស់នេះ លោកសាក្សី លោកធ្លាប់ដែរឮទេ ថាអនុមេបញ្ជាការកងពលលេខ៤ហ្នឹងទៅជាក្បត់ ហេង សំរិន ហើយប្រាប់ទៅរដ្ឋាភិបាលថា គេមានផែនការធ្វើរដ្ឋប្រហារ លោកដឹងរឿងនេះទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ខ្ញុំគ្មានដឹងរឿងហ្នឹងទាំងអស់ អត់ដឹងទេរឿង ព្រោះពេលនោះខ្ញុំក៏ចេញបាត់ទៅ អត់ដឹង។ សូមបញ្ចប់។

[០៩:១៥:៥៥]

**ស៖** លោកសាក្សី ខ្ញុំបានយករូបថតមកបង្ហាញលោកកាលពីសប្តាហ៍មុន នៅក្នុងបន្ទប់សវនាការយើងនេះ។ រូបថតនេះ គឺរូបថតមកពីខ្សែវីដេអូភាពយន្ត។ ខ្ញុំបង្ហាញលោកនូវខ្សែវីដេអូដែលមានរយៈពេលតែ៩វិនាទីទេ ហើយសូមឱ្យលោកមើលមើល៍ សូមសួរលោកម្តងទៀតមើល ថាតើលោកអាចស្គាល់បុគ្គលរូបនេះដែរទេ។ លោកប្រធាន យើងខ្ញុំសូមការអនុញ្ញាតបញ្ចាំងនៅលើអេក្រង់គឺឯកសារ

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

E3/3015R នៅនាទី ០១:៥១ ដល់ទី០២:០៩វិនាទី សូមការអនុញ្ញាត។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត!

ហើយផ្នែកសោតទស្សន៍ចាក់ផ្សាយខ្សែវីដេអូផ្នែកពាក់ព័ន្ធ តាមសំណើសុំរបស់មេធាវីការពារក្ដីដែលលោក នួន ជា គឺលោកមេធាវី វ៉ិចទ័រ កូប៉េ។

*(ការបង្ហាញឯកសារជារូបភាព)*

[០៩:១៧:៣៦]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** មនុស្សដែលលោកឃើញគាត់លើកដៃនេះ នៅក្នុងខ្សែវីដេអូនេះ តើរូបនេះជាលោក ហេង សំរិន មែនទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ខ្ញុំស្រពេចស្រពិលណាស់ ព្រោះវាយូរពេកជំនាន់នុំង នៅមកទល់ដល់ឥឡូវភ្លេច ខ្ញុំស្រពេចស្រពិល។ សូមថាឆ្លើយ ខ្ញុំសូមថាមិនឆ្លើយ មិនបានច្បាស់លាស់ ព្រោះស្រពេចស្រពិល។ សូមបញ្ចប់។

**ស៖** សំណួរ ប្រហែលជាសំណួរចុងក្រោយពាក់ព័ន្ធប្រធានបទនេះ។ លោកឃើញថាបុរសម្នាក់លើកដៃនៅពេលដែលគាត់ថ្លែងទៅកាន់អ្នកដែលមកចូលរួមប្រជុំនោះ តើរូបនេះមើលទៅដូចរូបដែល<លោក>ឃើញ <នៅពេល>ដែល សោ ភឹម <>បានបញ្ជា<>ឲ្យគាត់ប្រមូលកម្លាំង<ដែរឬទេ?> មើលទៅដូចលោក ហេង សំរិន ទេ?

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

<សុំអភ័យទោស លោកមេធាវី បើសិនជាខ្ញុំយល់ច្រឡំ។> គាត់បានឆ្លើយហើយលោកមេធាវីថាគាត់អត់ស្គាល់ទេ។ ចុះឥឡូវហ្នឹង លោកចេះតែសួរជជីកដដែល តើគោលបំណងនៃការតាំង<សំណួរ>ដើម្បីអ្វី ព្រោះគាត់ឆ្លើយថាមិនស្គាល់ទៅហើយ។

[០៩:១៩:០៧]

**លោក វ៉ិចទ័រ កូប៉េ៖**

យើង<>ឃើញ<យ៉ាងច្បាស់>ថា នេះគឺរូប ហេង សំរិន ហើយ។ គាត់បានជួប ហេង សំរិន

ជាញឹកញាប់។ អ៊ីចឹងហើយបានខ្ញុំសួរមើល ថាបើគាត់<>ធ្លាប់ជួបលោក ហេង សំរិន ញឹកញាប់អ៊ីចឹង រូបដែលគាត់ឃើញអម្បាញ់មិញនេះ តើជា ហេង សំរិន ឬដូច ហេង សំរិន ឬក៏យ៉ាងម៉េច? <ខ្ញុំទទួលស្គាល់ថាជាការសួរដេញដោលវែងឆ្ងាយ ប៉ុន្តែ -->

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបទេ សំណួរបែបនេះ។ សំណួរនាំមុខ ហើយខ្លួនឯងគឺច្បាស់លាស់បង្ហាញភស្តុតាងដោយខ្លួនឯង ហើយចំណែកសាក្សីបានឆ្លើយរួចហើយ។

**លោក វ៉ិចទ័រ កូប៉េ៖**

ដូចខ្ញុំជម្រាបអ៊ីចឹងគឺថាវាមិនជាសំខាន់ទេចំណុចនេះ អ៊ីចឹងខ្ញុំបន្តទៅមុខទៀត។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ឥឡូវខ្ញុំសួរបន្តអ្វីដែលលោកបានឆ្លើយកាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន អំពី រស់ ញ៉ឹម ដែលលោកបានឆ្លើយថា រស់ ញ៉ឹម នេះ បានទៅលេង សោ ភឹម។ ហើយខ្ញុំក៏បាន<សុំឲ្យ> លោក<រៀបរាប់ពីផ្ទះដែលជាកន្លែងពួកគេជួបគ្នា> ហើយលោកក៏បានពន្យល់យ៉ាងល្អិតល្អន់នៅ<> នៅម៉ោង១៤:៣០នាទី<។ បើតាម>សេចក្តីព្រាងប្រតិចារឹក ផ្ទះហ្នឹងមានទីតាំងនៅសោម <មិនមែនទេ> តាមការពិត<គឺ>ស្លងទេ<>។ លោកសាក្សី ឥឡូវខ្ញុំចូលសួរតទល់ជាមួយលោក ជាមួយនឹងសាក្សី 2-TCW-1070។ យកកំណត់ហេតុរបស់គាត់មកសួរ លោកប្រធាន នេះគឺជាស្ថានភាពមួយពាក់ព័ន្ធទៅនឹងប្រតិចារឹកជាភាសាអង់គ្លេសនៃឯកសារ <E3/10717>។ យើងមើលទៅឃើញបាត់១០ទំព័រឯណោះ ក្នុងឯកសារ<បកប្រែ>ហ្នឹង។ អត្ថបទជាភាសាបារាំងនោះ គឺថាវាពេញលេញហើយ ហើយយើងមានអត្ថបទនេះ មានជាភាសាខ្មែរទៀត។ ខ្ញុំអាន<ឯកសារ>ជាភាសាអង់គ្លេស ក៏ប៉ុន្តែទាន់ដាក់លេខ ERN នៅឡើយទេ ប៉ុន្តែយើងមានលេខ ERN ជាភាសាខ្មែរ និងភាសាបារាំង <>។ <ឯកសារនេះដូចជាច្របូកច្របល់បន្តិច។> ហើយយើងខ្ញុំយល់ថា ERN ជាភាសាអង់គ្លេសនេះ គឺថានឹងអាចផ្តល់ជូនពេលក្រោយបន្តិចទៀតនេះ។

[០៩:២១:៥៦]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំសូមការបញ្ជាក់ឲ្យបានច្បាស់។ អ្នកណាជាអ្នកធ្វើប្រតិចារឹក ដែលបាត់១០ទំព័រដែលមាននៅក្នុងសំណុំរឿងហ្នឹង?

**លោក វ៉ិចទ័រ កូប៉េ៖**

អ្វីដែលបានកើតឡើងនោះ គឺឃ្លាចុងក្រោយនៅក្នុងអត្ថបទជាភាសាអង់គ្លេសនៃសាក្សីដែលនឹងមកចូលឆ្លើយនៅពេលបន្ទាប់នេះ បាននិយាយថា – E3/10717, ERN ជាភាសាអង់គ្លេស 01354231 ថាចុងបញ្ចប់ គឺថានៅសល់ទំព័រជាភាសាខ្មែរហ្នឹង១០ទំព័រទៀត មិនទាន់បកប្រែ។ <បន្ទាប់មក> យើងបានទាក់ទងអង្គភាពបកប្រែភាសាហ្នឹង ថាអា១០ទំព័រចុងក្រោយហ្នឹង ក៏បានបករួចរាល់ហើយ <ប៉ុន្តែ>គ្រាន់តែថាមិនទាន់ដាក់លេខ ERN ជាភាសាអង់គ្លេសទេ។ <ចំណែកឯភាសាបារាំងបានបកប្រែរួចរាល់អស់ហើយ។>

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

អ៊ីចឹង<សម្រាប់កំណត់ត្រា>ប្រតិចារឹក គឺថាលោក<មេធាវី បានកំពុង ឬមានគម្រោង>ដកស្រង់ចេញអំពីការបកប្រែជាផ្លូវការ<មួយ>?

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ ត្រឹមត្រូវហើយ គឺការបកប្រែជាផ្លូវការ។

[០៩:២៣:១១]

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី ERN ជាភាសាបារាំងនោះគឺ 01348564, ខ្មែរ 01340521 ដល់522។ សាក្សីរូបនេះ បានផ្តល់សក្ខីកម្មអំពីវត្តមានរបស់ រស់ ញឹម ទៅភូមិភាគបូព៌ា។ ខ្ញុំសូមអានឲ្យលោកស្តាប់ "សួរ៖ ដូច្នេះពេលដែលគាត់ទៅបូព៌ា តើគាត់ទៅកន្លែងណា? តើគាត់ភាគច្រើន ទៅទស្សនកិច្ចនៅកន្លែងណា? ឆ្លើយ៖ គាត់ទៅទួលព្រីង ហើយនិងទៅសំរោង – ទួលព្រាប (សូមកែតម្រូវ) – ទៅទួលព្រាបនិងសំរោង។ សួរ៖ គាត់មិនទៅស្ទួងទេឬ? ឆ្លើយ៖ គាត់មិនដែលទៅកន្លែងនោះទេ។ សួរ៖ តើគាត់មកលេងតែទួលព្រាប ហើយនិងសំរោងទេឬ? ឆ្លើយ៖ បាទ។ ដូច្នេះគាត់ទៅទួលព្រាប និងសំរោង ទៅលេងយាយការ៉ូ? បាទ ព្រោះកន្លែង យាយការ៉ូ នៅហ្នឹងស្រាប់។" បញ្ចប់ការដកស្រង់។

ដូច្នេះសាក្សីរូបនេះ បានឆ្លើយថា រស់ ញឹម មិនដែលបានទៅលេង សោ ភឹម នៅឯស្ទួងនោះទេ។ ក៏ប៉ុន្តែលោកបានរៀបរាប់ថា គាត់បានទៅផ្ទះមួយនៅជិតស្ទួងនោះ<ជាច្រើនដង>ដែរ ទៅលេងតែម្តុំផ្ទះនុ៎ង។ តើលោកប្រាកដទេថា លោកបានឃើញ រស់ ញឹម ទៅលេង សោ ភឹម នៅស្ទួង?

**ឆ៖** បាទ សូមឆ្លើយ ខ្ញុំឃើញម្តង គាត់ទៅលេង ទៅនុ៎ងចូលមួយភ្លែត។ សូមចប់បាទ។

01391923



**ស៖** សាក្សីដដែលនេះ នៅពេលដែលគាត់រៀបរាប់អំពីដំណើរទស្សនកិច្ចរបស់ រស់ ញឹម នេះ ត្រង់ទំព័រដដែល គាត់និយាយថា៖ "រស់ ញឹម ទៅសម្រាកនៅទីនោះ គឺអស់រយៈពេលពីរ ឬក៏បីយប់"។ តើចំណុចនេះថា រស់ ញឹម ធ្លាប់បានទៅសម្រាកពីរបីយប់នោះ លោកដឹងដែរទេ រឿងនេះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ រឿងថាទៅសម្រាក ដូចតែ មិន ខ្ញុំមិនដែលឃើញទេ ដូចមិនដែលទេ ខ្ញុំ ឬក៏ខ្ញុំភ្លេចស្រពេចស្រពិលយ៉ាងណា ហ្នឹងខ្ញុំសូមមិនឆ្លើយទេបាទ ព្រោះមិន -- ភ្លេចភ្លាំងត្រង់នុ៎ង ឬក៏មិនដែលបានឃើញទេត្រង់នុ៎ង។ សូមបញ្ចប់បាទ។

[០៩:២៦:៣៧]

**ស៖** មិនថ្វីទេ ខ្ញុំសួរបន្តទៀត។ កាលពីថ្ងៃព្រហស្បតិ៍សប្តាហ៍មុន យើងនិយាយអំពី នួន ជា នេះខ្លះៗមកហើយ។ ហើយខ្ញុំក៏បានអានឲ្យលោកស្តាប់នូវចម្លើយរបស់លោក ដែលឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ដែលលោកឆ្លើយថា នួន ជា បានទៅសម្រាន្តនៅកន្លែងមន្ទីររបស់លោកនុ៎ង<បី ឬបួន> ដង។ លោកថា លោកស្គាល់ នួន ជា។ <លោនិយាយ>ថា គាត់បានទៅសម្រាកនៅឯស្នួង ហើយ នួន ជា ហ្នឹងបានទៅទីនោះញឹកញាប់ណាស់។ បន្ថែមទៅលើព័ត៌មាននេះ លោកក៏បានឆ្លើយដូចតទៅនេះ៖ "ខ្ញុំបានឃើញគាត់ នៅពេលដែលគាត់ទៅដល់ គឺថាពេលនោះ គាត់ឱបគ្នា នៅពេល នួន ជា ទៅដល់ទីតាំងនោះ គាត់ចុះទៅ ហើយគាត់ចាប់ដៃ ហើយនិងឱបគ្នាជាមួយថ្នាក់ដឹកនាំដទៃ។" តើលោកនឹកឃើញទេ ថាលោកនិយាយពីចំណុចពីរនេះ?

**ឆ៖** បាទ កាលនុ៎ងមែន ដែលខ្ញុំធ្លាប់ឃើញ សូម្បីតែអ្នកធំណាអ៊ីចឹងដែរ តែទៅជួបគ្នា គេឱបចាប់ដៃ ឱបគ្នាហ្នឹង។ អ៊ីចឹងមែន។ សូមចប់។

**ស៖** ខ្ញុំយល់ហើយ។ ឥឡូវខ្ញុំសូមបង្ហាញសម្រង់មួយចេញពីសៀវភៅមួយក្បាល ដែលសរសេរដោយអ្នកកាសែតកម្ពុជាម្នាក់ឈ្មោះ ថេត សម្បត្តិ។ មានជំពូកមួយរៀបរាប់អំពីទំនាក់ទំនងរវាង នួន ជា ជាមួយនឹង សោ ភឹម។ ឯកសារ E3/4202, ERN ជាភាសាអង់គ្លេស 00757535, ហើយបារាំង <00849445>, ខ្មែរ 00858353 និង<មានបន្តទៀត>។ អ្នកនិពន្ធបានសរសេរថា៖ "នួន ជា និង សោ ភឹម គឺជិតដិតនឹងគ្នាណាស់ ហើយ សោ ភឹម នេះគឺដូចជាប្អូនប្រុសរបស់ នួន ជា អ៊ីចឹង។" មានសម្រង់ដែលសរសេរនៅត្រង់ចំណុចនេះដែរ។ នួន ជា និយាយថា៖ "ខ្ញុំស្រលាញ់គាត់ គាត់ស្រលាញ់ខ្ញុំ។ ខ្ញុំជិតដិតនឹងគាត់ណាស់ ពីព្រោះយើងធ្លាប់តស៊ូជាមួយគ្នា ធ្លាប់ជួយគ្នាក្នុងគ្រាអាសន្ន។" ហើយក៏មានការរៀបរាប់បន្ថែមទៀតដែរ ប៉ុន្តែសរុបមកវិញគឺថា សារនេះបញ្ជាក់ថា នួន ជា និងសោ ភឹម ជិតដិត

នឹងគ្នាណាស់។ តើលោកមានបានកត់សម្គាល់ឃើញថា គាត់ទាំងពីរនាក់ជិតដិតនឹងគ្នាអ៊ីចឹងទេ?

[០៩:៣០:១៩]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ គឺខ្ញុំមិនដែលឃើញទេ ដែលថាជិតដិតនឹងគ្នា គ្រាន់ថាធម្មតាដែលទៅជួបម្តងៗនោះ ធ្វើដូចតែភ្ញៀវអ្នកដទៃ ដូចតែភ្ញៀវរាល់ដងអ៊ីចឹងដែរ បើថាជិតដិតហួសពីហ្នឹងទៀត ខ្ញុំអត់បានដឹងទេ ក្នុងកិច្ចការផ្ទៃក្នុង។ បាទ សូមចប់យោបល់ហើយ។

**ស៖** ខ្ញុំយល់ ប៉ុន្តែឥឡូវខ្ញុំចង់សួរលោកអ៊ីចេះវិញ ថាតើលោកឃើញថាមានភាពខុសគ្នាយ៉ាងណាដែរ នៅពេលដែល សោ ភឹម គាត់ពិភាក្សាជាមួយ នួន ជា តើខុសពីពេលដែលគាត់ពិភាក្សាជាមួយមេដឹកនាំដទៃទៀតយ៉ាងដូចម្តេចដែរ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ត្រង់កន្លែងពិភាក្សា ខ្ញុំអត់បានដឹងទេ ខ្ញុំអត់បាននៅ ព្រោះខ្ញុំនៅតែក្រៅទេ។ គ្រាន់តែថាឃើញមកដល់ ខ្ញុំនឹងបានឃើញ ព្រោះខ្ញុំនៅខាងក្រៅ ខ្ញុំនៅកាន់ខាងក្រោម។ ថាត្រង់ពិភាក្សាអី ខ្ញុំអត់ដឹងទាំងអស់។ បាទ សូមបញ្ចប់។

**ស៖** នៅខាងក្រោមបន្តិចនៅក្នុងជំពូកនេះ គឺអង់គ្លេស <00757536>, ខ្មែរមានលេខ <008 58355>, ហើយបារាំងមានលេខ <00849446>។ គឺមានការនិយាយយោងអំពីទំនាក់ទំនងរវាង នួន ជា និង ហេង សំរិន ផងដែរ។ គឺ "នៅខែឧសភា ៧៨ មេដឹកនាំ<ម្នាក់ក្នុងចំណោមមេដឹកនាំ>ជាន់ខ្ពស់មកពីខាងបូព៌ាគឺ ហេង សំរិន ដែលជាមនុស្សជិតស្និទ្ធនឹង នួន ជា និងបានការពារ នួន ជា ខណៈពេលបងធំទី២ រូបនោះទៅសួរសុខទុក្ខ ប៉ុល ពត នៅទសវត្សរ៍ឆ្នាំ១៩៦០ បានរត់គេចទៅប្រទេសវៀត-ណាមជាមួយកម្មាភិបាលរាប់រយនាក់ផ្សេងទៀត។" តើលោកបានសង្កេតឃើញថា នួន ជា ហើយនិង ហេង សំរិន មានទំនាក់ទំនងយ៉ាងដូចម្តេចដែរ?

[០៩:៣២:៤២]

**ឆ៖** បាទ សំណួរនេះគឺខ្ញុំសូមថា មិនឆ្លើយ ព្រោះខ្ញុំអត់បានដឹងទេជំនាន់នោះ មិនដែលដឹងទេ។ បាទ សូមបញ្ចប់។

**ស៖** អ៊ីចឹងមានន័យថា លោកមិនដែលឃើញ នួន ជា នៅពេលដែល នួន ជា ទៅជួប សោ ភឹម គឺបានន័យថា លោកមិនដែលឃើញ នួន ជា ជួបដដែក ឬក៏ពិភាក្សាជាមួយ ហេង សំរិន ទេ នៅពេលដែលគាត់ទៅជួប សោ ភឹម ឬមួយក៏ថាលោកមិនដែលបានឃើញទាល់តែសោះតែម្តង?

**ឆ៖** សូមឆ្លើយ ខ្ញុំថា ខ្ញុំមិនដែលទេ ខ្ញុំឃើញ គ្រាន់ថាដល់ពេលពិភាក្សា ឬជជែក ខ្ញុំមិនដែល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

បានដឹង មិនដែលបានស្តាប់ឮទេ ព្រោះខ្ញុំនៅតែឃើញ ៗពីចម្ងាយ ពីឆ្ងាយដែរ ព្រោះខ្ញុំការពារ វាឃ្លាត ២០, ៣០ម៉ែត្រ, ៥០ម៉ែត្រ មិនមែនជិតទេ។ សូមបញ្ចប់។

**ស៖** មិនអីទេ ខ្ញុំយល់អំពីចំណុចនេះ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅប្រធានបទថ្មីមួយទៀត។ នៅក្នុងចម្លើយរបស់លោក គឺលោកនិយាយអំពីកន្លែងមួយឈ្មោះថា "កណ្តាលជ្រុំ"។ តើកណ្តាលជ្រុំហ្នឹងនៅកន្លែងណាដែរ? ហើយតើមានអ្វីនៅកណ្តាលជ្រុំនោះ?

**ឆ៖** បាទ ខ្ញុំឆ្លើយកណ្តាលជ្រុំនោះ គ្រាន់តែថានៅចេញពីស្នួងមកកើត។ តែកណ្តាលជ្រុំហ្នឹងមានអី គ្រាន់តែភូមិអ្នកកសិករ ភូមិអីហ្នឹង មានស្អីនៅនុ៎ង មានតែកសិករ មានអីនៅ។ គ្រាន់តែឈ្មោះថាភូមិកណ្តាលជ្រុំ។ សូមឆ្លើយប៉ុណ្ណឹង។

[០៩:៣៥:០៥]

**ស៖** តើទីបញ្ជាការរបស់ កែ ពក នៅជិតកណ្តាលជ្រុំនោះមែនទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ព្រោះកន្លែងដែលទីបញ្ជាការគេនៅត្រង់ណា ខ្ញុំអត់ដឹងទេ គ្រាន់តែឃើញតែគេទ័ពដើរទៅមកតាមផ្លូវជាតិ ដែលពេលខ្ញុំទៅឃើញម្តងៗហ្នឹង។ ទាល់តែខ្ញុំទៅដែរ បានឃើញ បើកន្លែងទីបញ្ជាការ មិនដឹងជាស្ថិតនៅត្រង់ណាទេ។ សូមបញ្ចប់។

**ស៖** តើលោកនៅជាមួយ សោ ភឹម ដែរឬទេ នៅកណ្តាលជ្រុំនោះ?

**ឆ៖** បាទ សូមឆ្លើយ នៅកណ្តាលជ្រុំ ខ្ញុំមិនដែលនៅទេ ជាមួយ សោ ភឹម កណ្តាលជ្រុំ។ គ្រាន់តែថាផ្លូវ ដំណើរទៅមកហ្នឹង តាមនុ៎ងដែរ ធ្លាប់ដែរតាមនុ៎ង បើថាឲ្យទៅនៅហ្នឹង មិនដែលទេ។ សូមចប់។

**ស៖** តើលោកដឹងទេថា ប្រហែលជា៤, ៥ ឬ ៦ខែ នៅមុនពេល សោ ភឹម សម្លាប់ខ្លួនឯងនោះ <ហើយ>រថក្រោះរបស់វៀតណាមបានចូលមក<ក្នុងទឹកដីភូមិភាគ>បូព៌ា<។> នៅក្នុងខែធ្នូ <ឆ្នាំ> ១៩៧៧ <>រថក្រោះវៀតណាមហ្នឹងបរចូល<ជិតតំបន់ស្នួង ហើយព្យាយាមបើកចូលកណ្តាលជ្រុំ> តើលោកចាំដែរឬទេ គឺបានមកដល់ស្នួងហ្នឹង តើលោកចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ មិនដល់ស្នួងទេ។ គ្រាន់តែថា មកដល់ត្រឹមឃុំអញ្ចើម គេហៅឃុំអញ្ចើមហ្នឹងឆ្ងាយពីស្នួង ឆ្ងាយប្រហែលជាប់ជិត១០គីឡូណោះ ចម្ងាយហ្នឹង។ បាទ សូមចប់យោបល់។

[០៩:៣៧:២៤]

**ស៖** ប៉ុន្តែជាពិសេស តើលោកដឹងអំពីរថក្រោះវៀតណាមពីរ<គ្រឿង> ដែលបើកចូលមកដល់

កណ្ដាលជ្រុំ នៅថ្ងៃ២២ ខែធ្នូ ៧៧ ទេ?

**ឆ៖** បាទ ខ្ញុំ រឿងនេះ ខ្ញុំដឹងមិនច្បាស់ទេបាទ ខ្ញុំមិនដឹងទេ។ ខ្ញុំសូមមិនឆ្លើយ ព្រោះមិនដឹង។

**ស៖** ឥឡូវនេះខ្ញុំសូមអាននូវសម្រង់មួយឲ្យលោកស្ដាប់<។ លោកប្រធាន> គឺឯកសារ <E3/1593> អង់គ្លេសមានលេខ – គឺជាសៀវភៅរបស់ ប៉ែន ឃៀរនិន អង់គ្លេសមានលេខ 01150194, បារាំងមានលេខ 00639154, ខ្មែរមានលេខ 00637826 ដល់27។ នេះគឺជាអ្វីដែលគេសរសេរ គឺនៅក្នុងសៀវភៅរបស់ ឃៀរនិន ដោយប្រើប្រាស់សម្ដីរបស់ ហែម សាមិន ជាប្រភព គឺជាប្រភពព័ត៌មានដែលអាចជឿជាក់បាន។ ខ្ញុំសូមដកស្រង់៖ "នៅថ្ងៃ២២ ធ្នូ រថក្រោះវៀតណាមពីរបានបើកមកដល់ទីប្រជុំជនកណ្ដាលជ្រុំ ហើយព្យាយាមទាក់ទងជាមួយ សោ ភឹម ហើយបន្ទាប់មកទៀត គឺគេបរត្រឡប់ទៅព្រំដែនវិញ។ នៅក្នុងរថក្រោះហ្នឹង គឺមានអ្នកបដិវត្តន៍ខ្មែរជាច្រើននៅក្នុងនោះ ដែលបានរត់គេចទៅវៀតណាម។ ហ៊ុន សែន, ហែម សាមិន ហើយនិងមនុស្សប្រាំបីនាក់ផ្សេងទៀត បានអមដំណើរទាហានវៀតណាម នៅពេលដែលធ្វើដំណើរមកកាន់ព្រំដែននេះផងដែរ។ សាមិន បានជ្រៀតចូលទៅក្នុងទីរួមខេត្តស្វាយរៀង ដោយពាក់ខោអាវ<ខ្មៅអមដោយអង្គរក្សចំនួន១០នាក់>។"

លោកសាក្សី តើលោកដឹងទេ អំពីអ្នកបដិវត្តន៍ខ្មែរ ដែលជាអតីតទាហានខាងបូព៌ា ដែលជាអតីតកម្មាភិបាលបូព៌ាហ្នឹង គឺបានជិះនៅក្នុងរថក្រោះរបស់វៀតណាម ហើយពួកគេព្យាយាមចូលមក<នៅខែធ្នូ ឆ្នាំ១៩៧៧> ដើម្បីទាក់ទងជាមួយមេរបស់លោក <សោ ភឹម>ដែរឬទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេក្នុងរឿងនេះ។ ណាគ្រាន់តែឮថារថក្រោះបរទេសនោះ ភ័យរត់ខ្លាច ឬក៏មានការកម្លាំងការពារ ឬកម្លាំងទប់នេះហើយ។ បើថាឲ្យទៅជួបស្គាល់គ្នា ម៉េចនឹងដឹង សូម -- ខ្ញុំមិនដឹង។ ប៉ុណ្ណឹងបាទ សូមឆ្លើយប៉ុណ្ណឹង ចប់។

[០៩:៤០:៣៧]

**ស៖** ប៉ុន្តែជាទូទៅ តើលោកដឹងទេថា កងទ័ពវៀតណាមព្យាយាមទាក់ទងជាមួយនឹងកងកម្លាំងខាងបូព៌ានៅ<ខែធ្នូ> ឆ្នាំ១៩៧៧ ដែរឬទេ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ខ្ញុំអត់បានដឹងទេ។ ការទាក់ទង ព្រោះមិនដឹងទេខាងផ្នែកក្នុងនយោបាយជំនាន់នោះ។ បាទ សូមចប់។

**ស៖** មិនអីទេលោកសាក្សី។ នៅមានសំណួរមួយទៀត ទាក់ទងទៅនឹងការប្រជុំសម្ងាត់នៅខែមីនា ឆ្នាំ១៩៧៨ ដែលដឹកនាំដោយ សោ ភឹម នៅក្នុងភូមិមួយឈ្មោះថា ផ្អាវ គឺភូមិផ្អាវ។ ខ្ញុំសូមផ្ដល់នូវ

ឯកសារយោងគឺជាសៀវភៅរបស់ ឃៀវនិន គឺឯកសារ E3/1593។ អង់គ្លេសមានលេខ 01150203, ខ្មែរមានលេខ 00637947, បារាំងមានលេខ <00639172>។ ខ្ញុំសូមដកស្រង់៖ “មាននារីម្នាក់មកពីពញាក្រែក បាននិយាយថា សោ ភឹម បានកោះធ្វើការប្រជុំសម្ងាត់មួយនៅភូមិផ្អាវ នាខែមីនា ឆ្នាំ១៩៧៨។ ខ្ញុំបានស្ថិតនៅទីនោះដើម្បីបម្រើបាយទឹកកម្មាភិបាលសំខាន់ៗ ប៉ុន្តែខ្ញុំអាចចូលទៅជិត និងស្តាប់ឮសម្តីសន្ទនារបស់ពួកគេបាន។ ភឹម បាននិយាយថា ស្ថានការណ៍បានប្រែប្រួលយ៉ាងសម្បើម ហើយថាសមមិត្តទាំងអស់ត្រូវតែយកចិត្តទុកដាក់ពីរឿងនេះ។” <បន្តពីនេះបន្តិច> “<សោ ភឹម បានប្រាប់គ្រប់គ្នាឲ្យ>ប្រុងប្រយ័ត្ន។” តើលោកចាំទេ ថាមានការប្រជុំនៅខែមីនា ឆ្នាំ១៩៧៨ គឺប្រហែលជាពីរខែកន្លះមុនពេលដែល សោ ភឹម ស្លាប់ គឺមានការប្រជុំសម្ងាត់នៅផ្អាវ តើលោកដឹងទេ?

[០៩:៤២:៥៦]

**ឆ៖** បាទ សូមឆ្លើយ ខ្ញុំអត់ដឹងទេ កន្លែងនោះ ក្រែងតែពេលទៅហ្នឹង ខ្ញុំមិនដឹង -- ខ្ញុំមិនបានទៅជាមួយមិនដឹង ព្រោះផ្នែកកងការពារជូនបានទៅ ជួនមិនបានទៅ វាមានគ្នាច្រើន។ ពេលនោះខ្ញុំអត់ដឹង ខ្ញុំក៏មិនប៊ានឆ្លើយដែរបាទ។ សូមបញ្ចប់។

**ស៖** តើលោកដឹងទេ ថាភូមិផ្អាវហ្នឹងនៅកន្លែងណាដែរ?

**ឆ៖** បាទ ខ្ញុំស្គាល់មិនច្បាស់ទេ មិនដឹងនៅត្រង់ណាផ្អាវ។ បាទ សូមបញ្ចប់។

**ស៖** អរគុណលោកសាក្សី។ នៅខ្ញុំនៅសល់ពីរបីសំណួរចុងក្រោយទៀត គឺចង់ឲ្យលោកបញ្ជាក់បន្ថែមទៅលើអ្វីដែលលោកបាននិយាយកាលពីសប្តាហ៍មុន។ លោកនិយាយថា បងប្អូនរបស់ សោ ភឹម ឈ្មោះ ឌុល គឺជា ប្រាក់ ទិត។ លោកនិយាយថា ឌុល ឬក៏ប្រាក់ ទិត ហ្នឹងគឺជាមេស្រុកក្រូចឆ្មារ។ តើលោកដឹងទេថា ឌុល ឬក៏ ប្រាក់ ទិត <>គាត់<ធ្លាប់>មានតួនាទីនៅក្នុង<ស្រុក>ឆ្លូងដែរឬទេ<>?

**ឆ៖** បាទ សូមឆ្លើយ ខ្ញុំមិនសូវដឹងច្បាស់លាស់ទេ ព្រោះឆ្ងាយពីខ្ញុំ គ្រាន់តែថាមក ពេលជួបគាត់មកលេងម្តងអីចឹង គាត់សួរថានៅណា? គាត់អ្នកកាន់ក្រូចឆ្មារ ដឹងតែប៉ុណ្ណឹង។ បើខុសពីហ្នឹង អត់ដឹងទៀតទេ។ សូមបញ្ចប់។

[០៩:៤៥:០៥]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំហើយ លោកសាក្សី គឺខ្ញុំចង់និយាយអំពីរយៈពេលមុនឆ្នាំ១៩៧៥វិញម្តង។ នៅក្នុងកំណត់ហេតុ<>របស់មជ្ឈមណ្ឌលឯកសារកម្ពុជា<> គឺ<ឯកសារជាភាសា> អង់គ្លេសមានលេខ <01353309>, បារាំងមានលេខ <01345473> និងក្រោមបន្តិច, ខ្មែរមានលេខ

01340536។ <>លោកនិយាយយ៉ាងច្រើនអំពីការទម្លាក់គ្រាប់បែករបស់អាមេរិក គឺការទម្លាក់គ្រាប់បែក<ដ៏ច្រើនសន្ធឹកសន្ធាប់>នៅតំបន់របស់លោក។ តើលោកចាំទេថា លោកបានឆ្លើយប្រាប់មជ្ឈ-មណ្ឌលឯកសារកម្ពុជា អំពីការទម្លាក់គ្រាប់បែកនេះ?

**ឆ៖** បាទ កាលនុ៎ង ខ្ញុំសូមឆ្លើយ គឺទម្លាក់មែន។ គ្រាន់ថាមិនចាំថ្ងៃខែ ប៉ុន្តែទម្លាក់ ខ្ញុំរត់ពីរបីសាទម្លាក់មកហួសខ្ញុំក៏មាន ពីមុខខ្ញុំក៏មាន។ សូមចប់សំណួរ។

**ស៖** លោកនិយាយថា មានការទម្លាក់គ្រាប់បែកខ្លាំងណាស់នៅពេលនោះ គឺថាសម្លាប់ទាំងពូជទាំងពូជតែម្តង។ ហើយលោកបាននិយាយថា “ពួកគេស្លាប់នៅចុងភូមិ គឺថាមនុស្សជាច្រើនបានស្លាប់នៅពេលសង្គ្រាម។” ហើយលោកនិយាយអំពី<តាឡឹក> “កូន <តាឡឹក និងចៅគាត់ទាំងអស់ត្រូវ> ស្លាប់ទាំងអស់នៅក្នុងភូមិត្បែង។” តើលោកបាននិយាយទេថា កូនចៅ តាឡឹក <មួយគ្រួសារ>ស្លាប់ទាំងអស់នៅភូមិត្បែង ដោយសារតែការទម្លាក់គ្រាប់បែក<ដោយយន្តហោះចម្បាំងរបស់អាមេរិក>នោះ?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ ខ្ញុំបាននិយាយពិតមែន។ សូម្បីតែមិនទម្លាក់គ្រាប់បែកទេ គ្រាប់ផ្លោងផ្លោងពី ឡើងពីខាងទឹកដីអាមេរិកកាន់កាប់មក មកធ្លាក់ចំត្រង់ហ្នឹងមែន។ អ្នកភូមិអ្នកស្រុក ក៏គេដឹងដែរលោក មិនតែខ្ញុំទេ ធ្លាក់ចំរណ្តៅត្រង់សេដែលនៅក្នុងផ្ទះគាត់ ស្លាប់ទាំងអស់ហ្នឹង។ ខ្ញុំបាននិយាយមែន។ សូមចប់។

**លោក វ៉ិចទ័រ កូប៉េ៖**

លោកបានបញ្ជាក់រួចហើយ សូមអរគុណលោកសាក្សី។ សូមអរគុណលោកប្រធាន។

[០៩:៤៧:៤៩]

**ប្រធានអង្គជំនុំ៖**

បាទ តទៅនេះផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញា ដើម្បីមានឱកាសសួរដេញដោលចំពោះសាក្សី។

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី។ សូមអរគុណដែលលោកបានអញ្ជើញមកផ្តល់សក្ខីកម្ម ហើយសូមឱ្យលោកប្រាប់យើង ដូចដែលលោកបានឆ្លើយអ៊ីចឹង គឺថាគ្រាន់តែប្រាប់ថា អ្វីដែលលោកបានដឹង បានឮ។ ប្រសិនបើលោកមិនដឹងទេ ឆ្លើយមកថា លោកមិនបានដឹង។ ឥឡូវនេះយើងមានការយល់

ដឹងខ្លះ អំពីអ្វីដែលលោកបានដឹង បានឮ។ លោកបានប្រាប់យើងរួចហើយថា លោកត្រូវបានគេជ្រើសរើសឲ្យចូល<ធ្វើការនៅមន្ទីរការពារ របស់> សោ ភឹម គឺប្រហែលជាក្នុងខែមេសា <ឬខែឧសភា ឆ្នាំ> ៧៦។ ដូច្នេះតើលោកអាចប្រាប់បានទេ ថា មន្ទីរការពារនុ៎ង វាមានតួនាទី ឬក៏មានមុខងារអ្វីដែរ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំជម្រាប ថាកន្លែងមន្ទីរការពារហ្នឹង គ្រាន់តែមុខងារ គ្រាន់តែថាគាត់ស្នាក់នៅកន្លែងហ្នឹង ការពារតែនៅតែកន្លែងហ្នឹង គ្មានតួនាទីអីទេ ការពារគ្រាន់តែតួនាទីការពារ។ បាទ ប៉ុណ្ណឹង។

**ស៖** សូមអរគុណ។ លោកបាននិយាយថា មេបញ្ជាការរបស់លោក គឺឈ្មោះ ឈួក -- ឈ្មោះ ជឿក។ តើ ជឿក ហ្នឹងរាយការណ៍ទៅអ្នកណាដែរ? <តើលោកស្ថិតនៅក្រោមកងវរសេនាតូច ឬក៏កងពលធំ តើលោក> រាយការណ៍<ដោយផ្ទាល់>ទៅអ្នកណាដែរ?

[០៩:៤៩:៣៣]

**ឆ៖** បាទ ជឿក ហ្នឹងគ្រាន់តែថា មេក្ដោបក្ដាប់ពីលើពួកខ្ញុំនៅក្នុងមន្ទីរការពារហ្នឹង។ មានដូចថា តាសោ ភឹម ទៅណាទៅណាអ៊ីចឹង ជឿក ហ្នឹងអ្នកចាត់កម្លាំងឲ្យទៅ។ មានតែប៉ុណ្ណឹង ខ្ញុំដឹងតែប៉ុណ្ណឹង។

**ស៖** ដើម្បីបញ្ជាក់ឲ្យបានច្បាស់ គឺថា ជឿក រាយការណ៍ផ្ទាល់ទៅ សោ ភឹម អ៊ីចឹងមែនទេ?

**ឆ៖** បាទ គ្រាន់តែថា ជឿក, សោ ភឹម មកប្រាប់ ជឿក ១ហ្នឹងក៏រាយការណ៍ទៅ តាសោ ភឹម។ គ្រាន់តែប៉ុណ្ណឹង ច្បាស់ បាទ។ សូមបញ្ចប់យោបល់។

**ស៖** ឥឡូវនេះ ខ្ញុំចង់សួរអ្វីដែលលោកបានឆ្លើយកាលពីសប្ដាហ៍មុន <ដែល>និយាយអំពីកងពលមួយទៀត គឺលោកនិយាយអំពីកងពល<លេខ>១ នៅខាងបូព៌ា។ សាក្សីដែលនឹងត្រូវមកដល់ គឺថាដែលមេធាវីការពារក្ដីបានអានច្រើនដងហើយ<ពីកំណត់ហេតុស្ដាប់ចម្លើយរបស់គាត់> គឺ<ឯកសារ> E3/10717 គាត់បានឆ្លើយ <ខ្មែរ>នៅទំព័រ <01340494>, បារាំងមានលេខ <01348538>, អង់គ្លេសមានលេខ 01354194 ដែលថាកងពលលេខ១ ត្រូវបានប្រគល់ទៅឲ្យភ្នំពេញវិញ។ ហើយនៅក្នុងសៀវភៅដែលមេធាវីការពារក្ដី និយាយទាក់ទងទៅនឹង<>សៀវភៅរបស់ ប៉ែន យៀវនិន <ដែលជាអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលី> គឺឯកសារ E3/1593 <ហើយ>គាត់បាននិយាយថា <នៅខែកក្កដាឆ្នាំ៧៥> កងទ័ពបដិវត្តន៍កម្ពុជាបានបង្កើត<កម្មវិធីមួយ> ហើយ<ភូមិភាគផ្សេងៗគ្នាជាច្រើន>បានប្រគល់<កម្លាំងកងទ័ពរបស់ខ្លួន>ទៅឲ្យ<គណ:>មជ្ឈិម។ តើលោកចាំ<បានស្រដៀងៗនេះ>ទេ<? តើ>កងពលលេខ១ <ឬកម្លាំងផ្សេងទៀត មកពីភូមិភាគ>បូព៌ា ត្រូវបានប្រគល់ទៅឲ្យកងទ័ពមជ្ឈិម

<នៅក្នុងឆ្នាំ១៩៧៥>ដែរឬទេ? <ខ្ញុំដឹងថា រឿងនេះកើតឡើងមុនលោកមកដល់ ប៉ុន្តែ>តើលោកដែលធ្លាប់ឮអំពីបញ្ហាផ្ទេរនេះ ដែរឬទេ?

[០៩:៥១:៥៨]

**ឆ៖** បាទ ខ្ញុំមិនធ្លាប់ឮទេ ខ្ញុំមិនបានដឹង ព្រោះត្រង់កិច្ចការហ្នឹង ខ្ញុំអត់សូវដឹងទេ។ សូមឆ្លើយប៉ុណ្ណឹង សូមបញ្ចប់។

**ស៖** ដើម្បីឲ្យច្បាស់ថាយើងយល់គ្នា គឺថា លោក ហើយនិងមន្ទីរការពាររបស់លោក គឺ<>ជាផ្នែកការពារ <មិនមែនជាផ្នែកប្រយុទ្ធដែលស្ថិតនៅក្រោមកងពលមួយទេ> ហើយ<ការងាររបស់លោកគឺគ្រាន់តែ>ដើម្បីការពារ សោ ភឹម<>។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំឆ្លើយ ដូចថាគ្មានកងពលណាការពារទេ ព្រោះកន្លែងខ្ញុំនៅតាម នៅក្រសួងហ្នឹងមានតែគ្នាខ្ញុំនៅហ្នឹង គ្មានកន្លែងណា ទៅខាង កងចល័តគេនៅ ហើយទៅខាងនោះសុទ្ធតែប្រជាពលរដ្ឋគេនៅភូមិជុំវិញហ្នឹង។ នៅខាងក្រោយវាលស្រែ។ បាទ សូមចប់ចម្លើយ។

**ស៖** តើមាន<អ្នកការពារ>ប្រដាប់អាវុធប៉ុន្មាននាក់ដែរនៅក្នុងមន្ទីរ ឬក៏នៅក្នុងកងរបស់លោកនោះ?

**ឆ៖** បាទ ទាហានដែលនៅនេះតែគ្នាខ្ញុំ បីបួនដប់នាក់ហ្នឹង។ ក្រៅពីហ្នឹងគេ គ្រាន់ថាបុគ្គលិកប៉ុន្តែមានក្រសួងគេទៅធ្វើការខ្លះ ទៅស្រែ ទៅធ្វើស្រែ ខ្លះទៅមើលគោ ខ្លះទៅច្រូតស្មៅអ៊ីចឹងទៅ ខ្លះគេទៅដឹកជី ដឹកអីទៅដាក់ស្រែ មានតែអ៊ីចឹង វាមិននៅ -- សុទ្ធតែមានការងារធ្វើ។ សូមបញ្ចប់ចម្លើយ។

**ស៖** តើមានផ្នែកទូរសារដែរឬទេ នៅក្នុងមន្ទីរការពារនោះ គឺខាងផ្នែកទូរលេខ?

**ឆ៖** បាទ ជំនាន់នុំងមាន សូមឆ្លើយជំនាន់នោះមានតែ គេហៅស៊ី វីដេអូ អានៅជាប់នឹងឡាននុំងមានតែអានុំង បើថាក្រៅពីហ្នឹង គ្មានទេ។ ខ្ញុំឃើញតែហ្នឹង ក្នុងនុំងមិនចេះប្រើទៀតផង។ សូមបញ្ចប់។

**ស៖** តើលោក<បាន>ដឹង<លេខកូដអ្វីខ្លះដែល> សោ ភឹម <ប្រើ>នៅពេលដែលគាត់ផ្ញើលិខិត<ទំនាក់ទំនងទៅមជ្ឈិម>? ថាតើគាត់មានប្រើប្រាស់ឈ្មោះជាលេខ<កូដ>ផ្សេង ក្រៅពី<ការចុះហត្ថលេខាដាក់>ឈ្មោះពិតរបស់គាត់ទេ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងទេ អាត្រង់លេខ មិនលេខនោះ អាហ្នឹងមិនសូវចាប់អារម្មណ៍ផង អត់បានដឹង ខ្ញុំមិនហ៊ានឆ្លើយទេ កន្លែងណាដែលមិនដឹង ព្រោះមិនមែនការពិតអត់ ហ៊ានឆ្លើយទេ។ សូមបញ្ចប់។

[០៩:៥៥:១៧]

**ប្រធានអង្គជំនុំ៖**

តែលោកសាក្សីឲ្យមានជំហរច្បាស់លាស់។ សាក្សីត្រូវមានកាតព្វកិច្ចត្រូវឆ្លើយ ពាក្យថាឆ្លើយសំណួរគឺយល់ដឹង ហើយអាចឆ្លើយតបនឹងសំណួរបាន គឺឆ្លើយក្នុងករណីមិនដឹងទេ ឆ្លើយថាមិនដឹង ពាក្យឆ្លើយថា "មិនដឹង" គឺជាចម្លើយដូចគ្នា ឬក៏ជាចម្លើយដែរ។ កាលណាលោកសាក្សីឆ្លើយមិនច្បាស់លាស់ គឺវានាំឲ្យមានសំណួរបន្តទៀត ហើយវាអត់មានទាញយកការវាយតម្លៃអំពីសក្ខីកម្មរបស់លោកមកជាការពិចារណា ដើម្បីប្រយោជន៍ក្នុងការស្វែងរកការពិតទេ។ អ៊ីចឹងឲ្យមានជំហរច្បាស់លាស់ បើមិនដឹងទេ គឺឆ្លើយថាមិនដឹង។ ភាពស្រពេចស្រពិល គឺស្មើនឹងមិនដឹង នៅចំពោះមុខអង្គជំនុំជម្រះ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមអរគុណ។ ឥឡូវនេះខ្ញុំចង់សួរអ្វីដែលលោកបានឆ្លើយប្រាប់តុលាការនេះ គឺលោកនិយាយថា កែ ពក <>នៅក្នុងចម្លើយរបស់លោកប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា អង់គ្លេសមានលេខ <01353373>, ខ្មែរមានលេខ 01340575 និងបារាំងមានលេខ <01345513>។ លោកបាននិយាយអំពី កែ ពក ថា៖ "កែ ពក មកញឹកញាប់ គាត់មកច្រើន<ដងណាស់> នៅពេលដែលសួរថា តើគាត់មកប៉ុន្មាន<ថ្ងៃក្នុងមួយ>ដងដែរ? លោកនិយាយថា៖ ពេលខ្លះគាត់មកមួយអាទិត្យម្តង។ ហើយលោកនិយាយតទៅទៀតថា "នៅពេល<ដែល>ខ្មែរក្រហមវាយ<ប្រហារ>វៀតណាមហ្នឹងគឺ កែ ពក មកនៅទីនេះ <ស្នាក់នៅទីនេះ ហើយនៅ>តែ<កន្លែងនេះប៉ុណ្ណោះ>។" ដូច្នេះខ្ញុំចង់សួរថា តើលោកមានន័យយ៉ាងម៉េច ដែលពេលលោកឆ្លើយថា ពេលខ្មែរក្រហមវាយ<ប្រហារ>វៀតណាមហ្នឹង?

[០៩:៥៧:២៦]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ខ្ញុំឃើញតែ ពេលនុ៎ងខ្មែរក្រហមមិនវាយវៀតណាមមែនជំនាន់នុ៎ង វាយវា ផ្ទុះអាវុធគ្រប់កន្លែងមែន។ មានន័យអី មានតែថាវាយគ្នា ខ្ញុំត្រង់ន័យ មិនន័យ ខ្ញុំអត់បានដឹងយល់ច្បាស់។ គ្រាន់តែថាជំនាន់ហ្នឹងគឺវាយមែន វាយសង្គ្រាម វាយជាមួយវៀតណាម ប្រយុទ្ធទៅប្រយុទ្ធមក។ សូមចប់ចម្លើយ។

**ស៖** ឥឡូវនេះ យើងនិយាយអំពីពេលវេលាទាក់ទងទៅនឹងការចាប់ខ្លួនកម្មាភិបាលបូព៌ាវិញ ដែលលោកបាននិយាយរួចហើយនោះ។ តើការវាយជាមួយវៀតណាមកើតឡើងមុនពេលចាប់ខ្លួន ឬក៏នៅក្នុងពេលដែលមានការចាប់ខ្លួនដែរ? តើលោកអាចពន្យល់បានទេពីពេលវេលានោះ?

**ឆ៖** ការដែលចាប់ខ្លួនហ្នឹង វៀតណាមក៏វាយ ក៏នៅតែវាយដែរ ចាប់ខ្លួនក៏ចាប់ដែរ ពេលនោះ។

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

តាមខ្ញុំដឹង គ្រាន់តែថាវាយទ្រង់ទ្រាយធំហ្នឹងវាយមុនហ្នឹង។ មុនហើយ ដល់ក្រោយមកបានចាប់ខ្លួនជាបណ្តើរៗ តាមខ្ញុំយល់។ សូមបញ្ចប់។

**ស៖** តើ សោ ភឹម បានចូលរួមក្នុងការវាយ<ប្រហារប្រឆាំងនឹង>វៀតណាមដែរឬទេ?

**ឆ៖** បាទ ជំនាន់នុំងខាង សោ ភឹម ដែលខ្ញុំការពារនៅតែកន្លែង ត្រង់មិនដែលទៅវាយទេ តែត្រូវវាយ មានតែកងទ័ពនៅខាងមុខ។ ត្រង់ពួកខ្ញុំ ខ្ញុំនៅតែក្រោយនេះ ត្រង់វាយមិនវាយខ្ញុំអត់ដឹងទេ។ សូមបញ្ចប់។

[០៩:៥៩:២៧]

**ស៖** តើលោកធ្លាប់ទៅមើលសមរភូមិ ឬក៏ទៅសួរសុខទុក្ខមេបញ្ជាការនៅក្រោយសមរភូមិហ្នឹងជាមួយ សោ ភឹម ដែរឬទេ?

**ឆ៖** បាទ សូមឆ្លើយ ពេលនោះបែបមិនដែលបានទៅទេ។ បាទ សូមបញ្ចប់។

**ស៖** នៅពេលដែលលោកនិយាយអំពីការចាប់ខ្លួនកម្មាភិបាលបូព៌ា ឥឡូវនេះខ្ញុំព្យាយាមបំបែកទៅជាពេលពីរ អំឡុងពេលពីរ គឺ<ការចាប់ខ្លួន>មុនពេលដែល សោ ភឹម ទៅភ្នំពេញ <ហើយបន្ទាប់មកបានសម្លាប់ខ្លួនឯងនៅភ្នំពេញ និងការចាប់ខ្លួន>ក្រោយ<ការធ្វើដំណើររបស់> សោ ភឹម <>ទៅភ្នំពេញ។ មុនទៅភ្នំពេញជាមួយ សោ ភឹម ហ្នឹង តើមានការចាប់ខ្លួនកម្មាភិបាលនៅបូព៌ាដែរឬទេ?

**ឆ៖** បាទ សូមឆ្លើយ មុននឹង សោ ភឹម មកភ្នំពេញហ្នឹង គឺចាប់កម្មាភិបាលហ្នឹងអស់ច្រើនទៅហើយ ចាប់មុននុំងរហូតមក បាន សោ ភឹម ទៅភ្នំពេញ។ បាទ សូមចប់។

**ស៖** វាហាក់ដូចជា<សាក្សី>និយាយក្រោយពេលអ្នកបកប្រែជាភាសាអង់គ្លេស <ដូច្នេះ> ខ្ញុំមិនច្បាស់<ថាយើងបានបាត់ចម្លើយរបស់សាក្សីខ្លះ ឬក៏ប្រហែលមីក្រូត្រូវបានបិទ ដូច្នេះដើម្បីឲ្យច្បាស់នៅពេលលោកឆ្លើយ សូមបើកភ្លើងក្រហមផង>។ ដូច្នេះ ខ្ញុំចង់សួរថា តើមានកម្មាភិបាលបូព៌ាណា<ខ្លះ>ត្រូវបានគេចាប់ខ្លួន? <ហើយនរណាខ្លះ>ដែល<បាន>វាយប្រហារជាមួយវៀតណាម<>? ហើយខ្ញុំគិតថា ប្រហែលជាមេធាវីប្រឹក្សាអាចជួយរុញមីក្រូឲ្យខិតទៅជិតសាក្សីបន្តិចទៅ ដើម្បីឲ្យគាត់និយាយស្រួបសំឡេងបានច្បាស់។

**ប្រធានអង្គជំនុំ៖**

ប្រហែលហ្នឹង ប្រហែលហ្នឹងត្រឹមត្រូវហើយ។ នេះជាខ្នាតដែលត្រូវកំណត់ឲ្យគាត់និយាយហើយ។

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១០:០២:១០]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ខ្ញុំមិនស្ទូវច្បាស់សំណួរ។ សូមលោកបញ្ជាក់សំណួរម្តងទៀត។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** មុនពេល សោ ភឹម ធ្វើដំណើរមកភ្នំពេញ មកជួបថ្នាក់ដឹកនាំនេះ ដែលលោកបានមកជាមួយនឹងគាត់ដែរនោះ។ លោកនិយាយថា កម្មាភិបាលមកពីភូមិភាគបូព៌ាហ្នឹង ត្រូវបានគេចាប់ខ្លួន។ តើនៅពេលហ្នឹង តើជាអ្នកដែលបានវាយប្រយុទ្ធនឹងកងទ័ពវៀតណាមនោះ<ស្ថិតនៅក្នុងចំណោមអ្នកដែលត្រូវចាប់ខ្លួនដែរ>ឬ<ទេ>?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយចម្លើយនេះ។ កាលដែលគេចាប់ភូមិភាគបូព៌ាហ្នឹង គឺចាប់ មិនថាកម្មាភិ-បាលទេ ទាំងអស់ ឲ្យតែបុគ្គលិក ក្រសួងមន្ទីរណាក៏ដោយ ឲ្យតែនៅក្នុងបូព៌ា គឺចាប់ទាំងអស់តែម្តង។ តែត្រង់ថា មានថាជាកងទ័ព ឬក៏ជាកម្មាភិបាល ឬក៏ស៊ីវិលទេ គឺចាប់ទាំងអស់តែម្តង។ អ្នកណាគេរួចទៅរួចទៅ ពីណាមិនរួចទៅ គឺបានចាប់យកទៅ បាត់ៗទៅ ទៅរៀនសូត្រ ប៉ុន្តែមិនដឹងយកទៅណា។ បាទ សូមចប់។

**ស៖** តើលោកដែលធ្លាប់បានឃើញពួកគាត់ទាំងនោះ ឡើងវិញទេ ឬក៏បាត់ខ្លួនរហូត?

**ឆ៖** បាទ អត់ដែលឃើញផង អត់ឃើញមកវិញទេ។ ឃើញតែបាត់រហូត ហើយខ្ញុំក៏រត់មកស្រុក មកខេត្ត ស្រុកកំណើតវិញដែរ ដល់អ៊ីចឹងបាត់គ្នាទៅ វាបាត់ស្គាល់អស់ បាត់មិនដែលជួបផង។ បាទ សូមបញ្ចប់ចម្លើយ។

[១០:០៤:០០]

**ស៖** ខ្ញុំនឹងនិយាយអំពីការធ្វើដំណើររបស់លោកមកភ្នំពេញជាមួយនឹង សោ ភឹម<។ ខ្ញុំគិតថាវាចាំបាច់ណាស់។> ហើយលោកមិនទាន់បាននិយាយអំពីរឿងនេះនៅឡើយទេ ក៏ប៉ុន្តែមុនចូលទៅសួរត្រង់ចំណុចនេះ ខ្ញុំបញ្ចប់ចំណុចពីរបីសិន។ លោកថា ឈូក នេះ -- ជឿក គឺជាប្រធានរបស់លោក តើមានអ្វីកើតឡើងទៅដល់ឈ្មោះ ជឿក នេះ? <តើលោកអាចពន្យល់បានទេ?>

**ឆ៖** បាទ មុន – សូមឆ្លើយ មុននឹងខ្ញុំមកភ្នំពេញហ្នឹង ជឿក ហ្នឹងត្រូវគេចាប់។ មុន -- អ្ហា! គេចាប់ ដូចថាគេចាប់ថ្ងៃហ្នឹង ខ្ញុំ ល្ងាច -- អំ ថ្ងៃស្អែក ខ្ញុំនឹងចេញមកភ្នំពេញ។ គេចាប់បាត់ថ្ងៃហ្នឹង។ បាទ សូមបញ្ចប់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** តើលោកដឹងទេថា ហេតុអ្វីបានជាគេចាប់ខ្លួនគាត់?

**ឆ៖** បាទ កន្លែងគេចាប់នោះ ខ្ញុំអត់ដឹងអីទេ ព្រោះខ្ញុំមិនបានទៅជាមួយគាត់ផង។ បើកាលណានេះម៉េចនឹងដឹង បើទៅបាត់ខ្លួនតែម្តង។ ខ្ញុំសន្និដ្ឋានថា គេចាប់ហើយ ហើយវាបាត់ទាល់តែរាល់ថ្ងៃ។ បាទ សូមបញ្ចប់។

**ស៖** ក្នុងចម្លើយរបស់លោក ឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា លោកបានរៀបរាប់លម្អិតជាងនេះ ហើយខ្ញុំសូមអានសម្រង់នេះ ឲ្យលោកស្តាប់។ នេះនៅត្រង់ទំព័រ <ជាភាសាអង់គ្លេស >01353339, ខ្មែរ01340555 ហើយបារាំង 01345492។ លោកបាននិយាយថា៖ "នៅពេលដែល <មានការចាប់ខ្លួនកើតឡើង គឺ>ឈ្មោះ <ជឿក> នេះបានមកដោះស្រាយបញ្ហា ហើយគេក៏ចាប់ ជឿក ហ្នឹងទៀត។ ពីណាចូលទៅ ឲ្យតែឃើញលេខឡាន លេខម៉ូតូ បូព៉ាចាប់ទាំងអស់ គ្មានចន្លោះពីណាម្នាក់ទេ ចងដៃ វ៉ៃសម្លាប់ចោល ចាប់ចងសម្លាប់ចោល។ <នៅពេលដែលឈ្មោះ> ជឿក ទៅដោះស្រាយគ្រាន់តែចូលទៅដល់<ភ្លាម> គេវ៉ៃ<រហូតដល់ស្លាប់ ហើយរុញ>ទម្លាក់អណ្តូងតែម្តង។" លោកសាក្សី ចំណុចត្រង់ចំណុចនេះលោកបានឃើញដោយផ្ទាល់ លោកបានឮពីគេ ឬក៏យ៉ាងណា?

[១០:០៧:១៥]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ កន្លែងហ្នឹងពេលដែលសង្គ្រាមចប់ ចប់នៅឆ្នាំ៧៩, ៨០ ខ្ញុំទៅលេងដល់កន្លែងនុំង លេងដល់កន្លែងនុំង អ្នកភូមិគេប្រាប់ខ្ញុំ ប្រាប់ថា គេចាប់វ៉ៃទម្លាក់អណ្តូងនៅនឹងហ្នឹង ក្រោយដែល ជឿក មក។ អ្នកភូមិគេប្រាប់ខ្ញុំ ដែលពេលខ្ញុំទៅនៅ ទៅលេងនុំង ហើយគេថា កោតខ្ញុំនៅរស់ បាននៅរស់។ ហើយអ្នកភូមិដែលនៅនុំងគេ ខ្លះគេយំ គេឃើញខ្ញុំ គេនឹកកូនគេដែលនៅរស់ខ្លះ អំ! ដែលស្លាប់អស់នោះ។ គេឃើញខ្ញុំនៅរស់ គេនៅ -- យំបាត់ខ្ញុំ។ ដឹងតាមអ្នកភូមិគេប្រាប់បាទ។ សូមបញ្ចប់។

**ស៖** សូមអរគុណ។ ចម្លើយនេះបានជួយដល់ខ្ញុំច្រើនមែន។ លោកនិយាយថា <ជឿក>ហ្នឹងមកដោះស្រាយបញ្ហាអ្វីណានោះ តើលោកអាចពន្យល់អំពីបញ្ហានេះបានទេ?

**ឆ៖** បាទ ទៅដោះស្រាយហ្នឹង គឺទៅដោះស្រាយឈ្មោះ យ៉ន មួយគាត់ទៅធ្វើឡាន ឡានដែលខូច។ ទៅធ្វើឡាន ដល់ចូលទៅ គេដេញចាប់ គេឃាត់ទុក គាត់នៅខាងក្នុងគាត់ គេចាប់ទាំង យ៉ន ហ្នឹងទុក, ជឿក ហ្នឹងទៅដោះ យ៉ន ហ្នឹង។ ហើយពេលដែលទៅដល់កន្លែងដោះនុំង គេចាប់ទាំងអស់គ្នាទៅ។ ខ្ញុំឮអ្នកភូមិ ក្រោយពីខ្ញុំទៅឆ្នាំ៧៩ ឆ្នាំ៨០ហ្នឹង ខ្ញុំទៅនុំង អ្នកភូមិគេប្រាប់អីចឹង។ សូមបញ្ចប់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

ឈ្មោះ ជឿក ករណីនេះ យើងជជែក ជឿក ទៅ ឈូក ផង ជឿក ផង ច្របូកច្របល់គ្នា។

**លោក ស៊ិន អ៊ឹង៖**

*(មីក្រូហ្វូនមិនទាន់ប្រតិបត្តិការ)*

[១០:០៩:០៥]

**ប្រធានអង្គជំនុំ៖**

អត់ទេ លោកឆ្លើយត្រូវហើយ ប៉ុន្តែការបកប្រែភាសា ទំនងអាចជាប្រើចេញភាសាអង់គ្លេសមក ឈ្មោះ ឈូក គឺឈ្មោះ ជឿក ខុសគ្នាឆ្ងាយណាស់ រវាងពាក្យខ្មែរហ្នឹង មិនស្រដៀងគ្នាទេ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** តើលោកដឹងទេថា អ្នកណាជាអ្នកសម្លាប់ ជឿក និង ចន និងអ្នកដទៃទៀតនោះ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ អត់បានដឹងទេ។

**ស៖** តើពួកគាត់ទាំងពីរនេះ ជាកងទ័ពមកពីភូមិភាគបូព៌ា ឬក៏ជាកងទ័ពមកពីខាងណា?

**ឆ៖** អ្នកដែលសម្លាប់ អ្នកដែលចាប់នោះគឺខាងៗនិរតី ខាងមជ្ឈិមហ្នឹង ឡើងចូលទៅចាប់ហ្នឹងតែម្តង។ សូមបញ្ចប់។

**ស៖** ខ្ញុំសួរពីរបីសំណួរអំពី សោ ភឹម តើលោកដឹងថា សោ ភឹម មានតួនាទីអ្វីដែរទេនៅមជ្ឈិម?

**ឆ៖** នៅក្នុងមជ្ឈិម ខ្ញុំមិនដឹងតួនាទីអីទេ គ្រាន់តែដឹងដែលថា គាត់ប្រធានភូមិភាគ តែប៉ុណ្ណឹង។ សូមចប់ចម្លើយ។

**ស៖** ចុះលោកធ្លាប់ដែលឮពាក្យថា "គណៈអចិន្ត្រៃយ៍" ដែរឬទេ?

**ឆ៖** បាទ មិនសូវដែលឮទេខាង ថាគណៈអចិន្ត្រៃយ៍អីហ្នឹង។ ខ្ញុំមិនច្បាស់ មិនពិត មិន ស្រពេចស្រពិល ខ្ញុំសូមឆ្លើយថា ខ្ញុំមិនដឹងតែម្តង ព្រោះមិនច្បាស់លាស់។ សូមបញ្ចប់យោបល់។

[១០:១១:២៥]

**ស៖** នៅពេលដែលលោកឡើងមកភ្នំពេញជាមួយនឹង សោ ភឹម តើលោកពេលហ្នឹងលោកទៅកន្លែងណា? <ហើយតើគាត់បានទៅកន្លែងណាខ្លះ?>

**ឆ៖** មុនខ្ញុំឡើងមកភ្នំពេញជាមួយ សោ ភឹម ខ្ញុំមក ថាមកភ្នំពេញ ប៉ុន្តែមកដល់ត្រើយម្ខាងត្រង់

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឱ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អរិយក្សត្រហ្នឹង ក៏គ្មានផ្លូវទៅដល់ហ្នឹង ទើរទន្លេទៅ ខាងនីរសារនៅភ្នំពេញហ្នឹងគេៗចាប់នៅក្នុងហ្នឹងដែរ គេក៏រត់គេចមកខាងក្រៅហ្នឹង គេប្រាប់ ខ្ញុំក៏នៅត្រឹមនុ៎ងទៅ។ ត្រឹមផ្ទះនៅកន្លែងចម្ការហ្នឹង។ បាទ សូមចប់ចម្លើយ។

**ស៖** លោកបាននិយាយអំពីដំណើរចុងក្រោយរបស់លោកមកភ្នំពេញជាមួយនឹង សោ ភឹម។ <ដូច្នេះយើង>មិនមានការឡើងជំទាស់តវ៉ារំខានអីទេ ខ្ញុំនឹងសួរលោកក្រោយពេលឈប់សម្រាក<។ មុន>ពេលឈប់សម្រាក<ដែល>នឹងមកដល់ឆាប់ៗនេះ<> ខ្ញុំនឹងបន្តសួរលោកអំពីដំណើររបស់ សោ ភឹម <>មុនពេល<ព្យាយាមធ្វើ>ដំណើរ<ឡើងមកភ្នំពេញ ហើយចុងបញ្ចប់>គាត់<បែរជា>ធ្វើអត្ត-ឃាតខ្លួនឯង<ទៅវិញ>។ នៅក្នុងឆ្នាំ១៩៧៦ និងឆ្នាំ៧៧ និងដើមឆ្នាំ៧៨ <ក្នុងពេលដែលលោកធ្វើការជាមួយគាត់> តើគាត់ឡើងមកភ្នំពេញនេះញឹកញាប់ប៉ុនណាដែរ សោ ភឹម នុ៎ង?

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ កាលដែលហ្នឹងរឿងញឹកញាប់នោះ ខ្ញុំចាំមិនបានច្បាស់ទេ។ ខ្ញុំគ្រាន់តែថាខ្ញុំមក ធ្លាប់មកហ្នឹងបីទៅបួនដងដែរ ហ្នឹងជូនគាត់មកហ្នឹង។ ថាញឹកញាប់ទៅទៀត ខ្ញុំមិនបានដឹងដែរ។ បាទ សូមចប់។

[១០:១៣:៣៥]

**ស៖** នៅក្នុងចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រង់ទំព័រ 01340559, បារាំង 01345498, អង់គ្លេស 01353348។ លោកបានឆ្លើយថា គាត់ឡើងមកប្រហែលជាពីរដងក្នុងមួយខែ។ ត្រឹមត្រូវដែរឬទេ? តើលោកឡើងមកជាមួយគាត់ប្រហែលជាពីរដងក្នុងមួយខែហ្នឹង ឬក៏<អ្នកការពារ>ផ្សេងទៀតដែលឡើងមកជាមួយ សោ ភឹម ពីរដងក្នុងមួយខែនោះ?

**ឆ៖** ខ្ញុំសូមឆ្លើយជូន ខ្ញុំ ជូនគេអ្នកផ្សេងទៀត។ មិនមែនទាំងអស់ ជួនវេនគេ ជួនវេនខ្ញុំ។ បាទ សូមឆ្លើយប៉ុណ្ណឹង។ វា គេចាត់ចំពីណា ពីហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងដប់កន្លះ សូមអញ្ជើញចូលវិញដើម្បីបន្តដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្តល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះនៅក្នុងអំឡុងពេលឈប់សម្រាក និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងដប់កន្លះ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:១៥ នាទី ដល់ម៉ោង ១០:៣០ នាទី)*

[១០:៣០:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី កាលពីថ្ងៃព្រហស្បតិ៍ គឺយើងបាននិយាយអំពីអ្វីដែលលោកបានប្រាប់ទៅខាងមជ្ឈមណ្ឌលឯកសារកម្ពុជា មុនពេលដែលលោកធ្វើដំណើរជាមួយ សោ ភឹម គឺជាដំណើរចុងក្រោយទៅកាន់ទីក្រុងភ្នំពេញ ហើយគាត់ទៅហ្នឹង បានទៅជាមួយ ហេង សំរិន។ ហើយនៅទំព័រអង់គ្លេសគឺ 0135 3388, ខ្មែរមានលេខ01340585 និងបារាំងមានលេខ <01345523>។ លោកបាននិយាយថា៖ សោ ភឹម បានប្រាប់ ហេង សំរិន ថា៖ "គាត់ទៅភ្នំពេញ ទៅដោះស្រាយ<បញ្ហា>។ គាត់ថា បើខ្ញុំមកភ្នំពេញបាត់ត្រឹមមួយអាទិត្យ រិន ឯងរត់ចូលព្រៃ ហើយប្រមូលអ្នកសេសសល់ប៉ុន្មានឲ្យចូលព្រៃតស៊ូ។" ខ្ញុំចង់សួរលោកមួយចំនួនទៅលើចំណុចនេះ នៅពេលដែលលោកនិយាយថា ថាតើ សោ ភឹម គាត់មានន័យយ៉ាងម៉េច ដែលថាគាត់ទៅដោះស្រាយ? តើលោកគិតថា គាត់ទៅភ្នំពេញទៅដោះស្រាយហ្នឹង តើវាមានន័យយ៉ាងដូចម្តេចដែរ?

[១០:៣២:៣៤]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំឮគាត់ថា ទៅដោះស្រាយហ្នឹង គាត់ទៅដោះស្រាយជាមួយកម្មាភិបាលកំពូលៗនៅភ្នំពេញហ្នឹង។ បែបគម្រោងការមានន័យប្រហែលអ៊ីចឹងយ៉ាង នៅភ្នំពេញហ្នឹង គាត់មកដោះស្រាយពីព្រោះកិច្ចការផ្ទៃក្នុងរបស់គាត់ ខ្ញុំមិនសូវដឹង។ សូមចប់។

**ស៖** ហើយលោកបាននិយាយថា សោ ភឹម បាននិយាយថា "ឲ្យប្រមូលអ្នកសេសសល់ប៉ុន្មាន

ហ្នឹង"។ តើលោកចង់មានន័យយ៉ាងម៉េច ដែលលោកឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាថា សោ ភឹម ថាឲ្យប្រមូលអ្នកសេសសល់ប៉ុន្មានហ្នឹង តើលោកចង់មានន័យយ៉ាងម៉េច?

**ឆ៖** បាទ ខ្ញុំឆ្លើយ ថាអ្នកដែលសេសសល់ហ្នឹង គឺសល់ពីដែលគេចាប់ខ្លួន សល់ ហ្នឹងហើយ សល់ពីគេចាប់ខ្លួនហ្នឹង ដើម្បីមកប្រមូលផ្ដុំកម្លាំង។ តាមខ្ញុំយល់ទៅ បែបគាត់ឲ្យមកប្រមូលកម្លាំងហ្នឹង ចាប់ផ្ដើមវ៉ៃតស៊ូម្ដងទៀតហ្នឹង មើលទៅបែបអ៊ីចឹង។ សូមបញ្ចប់ ហ្នឹងតាមខ្ញុំយល់។

**ស៖** អ៊ីចឹងនៅពេលដែល<លោក>និយាយថា "អ្នកសេសសល់" គឺគាត់សំដៅទៅលើកម្មាភិបាលបូព៌ា ដែលមិនត្រូវបានគេចាប់ខ្លួន<ដោយកងទ័ព>មជ្ឈិម<ឬកងទ័ពនិរតី> អ៊ីចឹងមែនទេ?

**ឆ៖** បាទ អ៊ីចឹងមែន មើលទៅអ៊ីចឹង។ សូមបញ្ចប់។

**ស៖** អ៊ីចឹងខ្ញុំយល់ថា លោក<ពិតជា>បានធ្វើដំណើរជាមួយគាត់<>ទៅភ្នំពេញនុ៎ង តើលោកប្រាប់បានទេថា ក្រៅពីលោក ហើយនិង សោ ភឹម ហ្នឹង តើ សោ ភឹម យកអ្នកណាផ្សេងទៀត<ទៅ> ជាមួយដែរឬទេ?

[១០:៣៤:៥១]

**ឆ៖** បាទ គ្មានអ្នកណាទេ ទៅតែពួកខ្ញុំដែលមកជាមួយគ្នាហ្នឹង មានអ្នកណាផ្សេងទៀតទេ។ សូមបញ្ចប់។

**ស៖** នៅពេលដែលលោកនិយាយថា សោ ភឹម គ្រប់គ្រងកងពលជាច្រើននៅកម្រិតស្រុក កម្រិតតំបន់ ថាតើមានយុទ្ធជនប៉ុន្មាននាក់ដែលទៅជាមួយគាត់នៅពេលដែលធ្វើដំណើរនោះ? ក្រៅពីលោក តើមានុ<អ្នកដែលបំពាក់អាវុធ>ប៉ុន្មាននាក់ដែរ ដែលធ្វើដំណើរទៅជាមួយគាត់?

**ឆ៖** កន្លែងហ្នឹង ខ្ញុំមិនដឹងទេ គឺលោកសួរអ៊ីចឹង សាចុះសាឡើងអ៊ីចឹង ដូចខ្ញុំដូចវ៉ល់ វាគិតអត់ឃើញ ដល់អ៊ីចឹង កន្លែងហ្នឹងមិនដឹងតែម្ដង។ ខ្ញុំសូមមិនឆ្លើយ។ សូមបញ្ចប់។

**ស៖** លោកសាក្សី ខ្ញុំច្របូកច្របល់បន្តិច ព្រោះពេលដែលលោកប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំមុន គឺលោកប្រាប់ដូចតទៅនេះ ខ្ញុំដកស្រង់នូវទំព័របន្ទាប់។ គេសួរថា "មានមនុស្សប៉ុន្មាននាក់ដែលទៅជាមួយលោកទៅភ្នំពេញហ្នឹង" លោកឆ្លើយថា "មានប្រាំបួននាក់ រួមទាំងគាត់ផង គឺពួកខ្ញុំ តែកុងឡានពីរនាក់ អ្នកដាំបាយម្នាក់ តាហ្នឹងម្នាក់ ហើយ<សរុប>ពួកខ្ញុំទាំងអស់ ប្រាំបួននាក់<> ។" តើអ្វីដែលលោកបានប្រាប់-- តើនេះគឺជាអ្វីដែលលោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំមុនមែនទេ?

**ឆ៖** បាទហ្នឹងមែន ខ្ញុំទទួលស្គាល់ថា ខ្ញុំឆ្លើយមែន ថាខ្ញុំទៅប្រាំបួននាក់មែន ទាំងគាត់ ទាំងពួកខ្ញុំនោះ ទាំងតែកុងឡាន។ សូមបញ្ចប់។

**ស៖** តើ សោ ភឹម គាត់មានប្រាប់ទេ ថាតើគាត់ទៅភ្នំពេញហ្នឹង គ្រោងទៅជួបអ្នកណាដែរ? តើគាត់មាននិយាយប្រាប់ពួកលោកទេ នៅពេលដែលគាត់ធ្វើដំណើរទៅភ្នំពេញហ្នឹង?

[១០:៣៧:១៥]

**ឆ៖** បាទ គាត់មាននិយាយប្រាប់ទេ។ មិនដឹងថាគាត់ទៅជួបអ្នកណាទេ គឺទម្លាប់មុនខ្ញុំទៅតែត្រឹមកន្លែងវត្តឧណ្ណាលោមហ្នឹង ខ្ញុំឈប់ ខ្ញុំសម្រាកត្រឹមហ្នឹង ហើយគាត់ទៅៗ។ មើលតែម្តងហ្នឹង បែបគម្រោងគាត់ទៅហ្នឹងទៀត ក៏មិនដឹង ព្រោះខ្ញុំក៏មិនបានដឹងដែរ ហើយទៅក៏មិនទាន់បានដល់ដែរ អាហ្នឹងបាទ។ សូមបញ្ចប់។

**ស៖** លោកសាក្សី លោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាយ៉ាងលម្អិត អំពីអ្វីដែលកើតឡើងនៅពេលដែលលោកធ្វើដំណើរ គឺថាទាក់ទងជាមួយនឹងលោក ក៏ដូចជា សោ ភឹម។ ដូច្នេះខ្ញុំចង់ឲ្យលោកជម្រាបប្រាប់តុលាការ ក៏ដូចជាចៅក្រម<ដោយផ្ទាល់>ឲ្យបានលម្អិត<។ យើងពិតជាមានការចាប់អារម្មណ៍ចង់ដឹង>ថាតើលោកបានឃើញអ្វី លោកបានឮអ្វីនៅពេលដែលលោកធ្វើដំណើរនោះ? គឺថាក្នុងចម្លើយដែលលោកប្រាប់ហ្នឹង គឺថា<មានមនុស្សប្រាំបួននាក់ដែល>ជិះឡាន<ពីរហ្នឹង> ដូច្នេះតើលោកអាចលម្អិតទេ ថាតើលោកទៅណា? ហើយវាមានអ្វីកើតឡើង? គឺឲ្យបានលម្អិតបន្តិច ប្រាប់ដល់ចៅក្រមអង្គជំនុំជម្រះ។

**ឆ៖** ត្រង់កន្លែងហ្នឹង ខ្ញុំដូចតែ លោកសួរហ្នឹង ខ្ញុំដូចជាច្រឡំ ដូចជាស្តាប់សំណួរមិនដឹងន័យទៅណាទៅណីទេ។ ខ្ញុំឆ្លើយមិនបានទេ អារឿងលម្អិត គ្រាន់តែថាមុខទៅភ្នំពេញ ខ្ញុំនេះ។ គ្រាន់តែប៉ុណ្ណឹងត្រង់លម្អិតរឿងរ៉ាវន័យស្អីទៀត ខ្ញុំមិនយល់ទេ។ សូមអស់យោបល់។

[១០:៣៩:០៤]

**ប្រធានអង្គជំនុំ៖**

បំណងនៃសំណួរអ៊ីចេះ សួរឲ្យលោករៀបរាប់ឲ្យបានក្បោះក្បាយបន្តិចអំពីដំណើរនៃការដែលចាកចេញពីខេត្តព្រៃវែងមកសំដៅនៅក្រុងភ្នំពេញ កាលពីលោកមកជាមួយ សោ ភឹម នោះ។ វាដំណើរហ្នឹង វាប្រព្រឹត្តទៅយ៉ាងដូចម្តេច? មកតាមច្រកណា អីច្រកណា មធ្យោបាយអីយ៉ាងម៉េចខ្លះ ឡានប៉ុន្មានអីប៉ុន្មានអ៊ីចឹង? លោកយល់ទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ សូមអរគុណ។ សំណួរហ្នឹងខ្ញុំស្ដាប់បាន លោកបញ្ជាក់។ ពេលហ្នឹងខ្ញុំមកភ្នំពេញ វាមានតាមផ្លូវលំបាកដែរផ្លូវ ព្រោះផ្លូវលំ ផ្លូវកាត់ ផ្លូវមានស្ពានត្នោត ស្ពានអីហ្នឹង ពិបាកផ្លូវមែនតាមផ្លូវៗកាត់ មិនមែនតាមផ្លូវជាតិទេ។ មកតាមដងផ្លូវនោះមានការ ជួបការលំបាកណាស់។ ប៉ុណ្ណឹងបាទ សូមបញ្ចប់។

**ប្រធានអង្គជំនុំ៖**

លោក និង សោ ភឹម ចាប់ចេញដំណើរពីណាមកណា? ពេលប៉ុន្មាន ម៉ោងប៉ុន្មានចាប់ផ្ដើមចេញពីព្រៃវែងមក ដែលលោកតាមឯកសារហ្នឹងគឺមកពីព្រៃវែង? មកព្រៃវែងមកដំណើរភ្នំពេញហ្នឹង កាលនោះធ្វើដំណើរដែលថា មកមានស្ពានផ្លូវដោយដើមត្នោត មានអី មិនមកតាមផ្លូវជាតិ មកតាមផ្លូវណាខ្លះកាត់តាមផ្លូវណាខ្លះ រហូតមកដល់អរិយក្សត្រដែលជាទីតាំងដែលមានបញ្ហាកើតឡើង នូវព្រឹត្តិការណ៍បាញ់គ្នានោះ? លោកអាចនិយាយបានទេ? លោកឆ្លើយលើកមុនបាន នៅក្នុងសំណុំរឿងលើកមុន លោកយល់ទេ? ក្នុងន័យឲ្យលោករៀបរាប់ វាគួរតែស្ដាប់បានដែលពេលរៀបចំចេញដំណើរពីព្រៃវែងមកដល់អរិយក្សត្រ។

[១០:៤០:៥៦]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ។ ចេញពីព្រៃវែងមកតាមភូមិស្ទឹព្រៃខ្លា ព្រៃញៀហ្នឹងមកចុះមក តែមកដល់ខាងព្រែកតាមាក់ ព្រែកអីហ្នឹង ប៉ុន្តែដល់ភូមិលម្អិតនោះ ខ្ញុំមិនសូវស្គាល់ភូមិសាស្ត្រគេទេ ទាល់តែមកដល់ កន្លែងអរិយក្សត្រហ្នឹង។ អរិយក្សត្រហ្នឹងក៏មិនស្គាល់ទេ ទាល់តែអ្នកភូមិគេថា ភូមិអរិយក្សត្រត្រង់ហ្នឹង។ មកដល់ត្រឹមហ្នឹងតែម្ដង រួចពីព្រៃវែងមកចុះមកតាមហ្នឹង មកតាមព្រៃខ្លា។ ពីព្រៃវែងមកជើងវិញ មកស្វាយអន្ទរ មកដល់ឃុំព្រៃខ្លា ព្រៃញៀ បានចុះមកបត់បែនច្រើនកន្លែងណាស់ ខ្ញុំចាំមិនអស់ទេ អាបត់បែនហ្នឹង ហើយមិនសូវស្គាល់ភូមិសាស្ត្រផង។ មកដល់ហ្នឹង គេថា ព្រែកតាមាក់ ៗនឹងគេទៅគេថាស្វាយពល ៗទៅ ប៉ុណ្ណឹង។ ទាល់តែមកដល់អរិយក្សត្រ។ បាទ សូមបញ្ចប់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី នៅពេលដែលលោកមកដល់អរិយក្សត្រ សុំទោស បើសិនជាខ្ញុំអានឈ្មោះមិនត្រូវ ថាតើលោកនៅជាមួយ សោ ភឹម <និងមនុស្សប្រាំពីរនាក់ផ្សេងទៀត>ដែរឬទេ? ហើយនិង ថា

តើពេលដែលលោកមកដល់អរិយក្សត្រហ្នឹង គឺក្រុមលោកនៅសល់ប្រាំបួននាក់ ដដែលមែនទេ?

**ឆ៖** បាទ មកដល់អរិយក្សត្រហ្នឹង ក្រុមខ្ញុំនៅសល់ប្រាំបួននាក់ដដែល។ សូមបញ្ចប់។

**ស៖** នៅពេលដែលលោកមកដល់អរិយក្សត្រ តើលោកស្នាក់នៅអរិយក្សត្រមួយយប់មែនទេ?

**ឆ៖** បាទ ស្នាក់នៅមួយយប់ ស្នាក់នៅប្រហែល មិនដល់មួយយប់ផង ប្រហែលជាម៉ោងពីរ ម៉ោងបី មានកើតឧប្បត្តិហេតុនៅហ្នឹងតែម្តង។ សូមបញ្ចប់។

[១០:៤៣:១០]

**ស៖** សូមលោកពន្យល់ឲ្យបានលម្អិតបន្តិចអំពីហេតុការណ៍ដែលកើតឡើងនោះ។

**ឆ៖** នៅកន្លែងដែលកើតឡើងនោះ ខ្ញុំសូមឆ្លើយ ថាពេលសម្រាកមកដល់កន្លែងផ្ទះដែលសំណាក់នៅហ្នឹង គឺផ្ទះនៅក្នុងចម្ការ។ ចម្ការគេហ្នឹងមានដាំ មានចេក មានថ្នាំ ថ្នាំជក់យើងហ្នឹង ហើយមានកន្លែងខ្លះគេដាំបន្លែ ល្ពៅ ត្រឡាចអីហ្នឹង ហើយសម្រាកនៅហ្នឹង។ ដល់ពេលសម្រាកទៅ ពេលយប់ប្រហែលជាម៉ោងពីរជាង ទៅម៉ោងបីហ្នឹងមានកើតហេតុ គេព័ទ្ធបាញ់នៅហ្នឹងតែម្តង ពេលហ្នឹង។ ដល់ពេលហ្នឹង ពេលបាញ់ហ្នឹង គាត់ក៏ចុះពីលើផ្ទះមក ខ្ញុំនៅខាងក្រោម។ គាត់ចុះមក គាត់ប្រាប់ថា គេបាញ់អី? ថាមិនដឹងគេបាញ់ស្អីទេ។ ដល់ខ្ញុំទៅ គាត់ថាទៅមើល ចុះទៅកន្លែងបាញ់ហ្នឹង។ ដល់ខ្ញុំទៅដល់កន្លែងបាញ់ហ្នឹង ហើយគេថា គេបាញ់ អ្នកទ័ពខាងណាទេ គេមកព័ទ្ធចាប់យើងបាញ់អានៅខាងមុខនុ៎ង អាអ្នកយាមខាងមុខហ្នឹង វាបាញ់បន្តប្រតាយគ្នាទៅ។ ខ្ញុំក៏ឃាត់គេ ឈប់! មកប្រាប់គាត់ គាត់ក៏ប្រាប់ថាឃាត់ឲ្យឈប់លែងបាញ់ ហើយក៏ឈប់លែងបាញ់ទៅ។ ឈប់លែងបាញ់ ដល់មក ថយមក ដល់នេះជំនុំគ្នាថាទៅច្រក ថាទៅដើរ ទៅរកច្រកចេញពីកន្លែងអរិយក្សត្រហ្នឹង។ ដល់រកច្រកដើរទៅ មានអ្នកគេនៅភ្នំពេញ គេនៅធ្វើចម្ការហ្នឹង គេដឹងផ្លូវកាត់ គេដើរ គេនាំដើរៗចេញពីផ្ទះនោះ ប្រហែលមិនទាន់បានប៉ុន្មាន ប្រហែលជា៣០, ៤០ម៉ែត្រហ្នឹង ក៏គេព័ទ្ធចាប់បាញ់នៅនុ៎ងទៀតទៅ។ បាញ់នៅនុ៎ងទៅ ក៏ប្រតប់ប្រតាយគ្នាទៅ ក៏ដកខ្លួនរត់មកកន្លែងសម្រាកហ្នឹងវិញ។ សម្រាកហ្នឹងវិញ ប្រមូលកម្លាំងដែលយើងហ្នឹងនៅហ្នឹង អីហើយក៏គាត់ ខ្ញុំបែកគាត់ក៏ពេលហ្នឹងទៅ។ គាត់ក៏ថាឲ្យខ្ញុំមកបញ្ចោះកាណូតចាំគាត់ចុះទៅ ៗ តាមផ្លូវទឹក។

[១០:៤៥:៣៣]

ដល់ពេលខ្ញុំមកបញ្ចោះកាណូតទៅ គាត់នៅខាងលើហ្នឹង គាត់ អ្នកនៅខាងលើគេរកមធ្យោបាយគេរកផ្លូវច្រកចេញទៅបាត់ទៅ ហើយដល់ខ្ញុំបញ្ចោះកាណូតស្មានតែគាត់មក អត់ឃើញគាត់រហូត ទាល់

តែគេទៅចាប់ខ្ញុំនៅកន្លែងនុ៎ង ខ្ញុំក៏រត់ឡើងពីនុ៎ង ឡើងមកលើទៀតទៅ។ ដល់ព្រលឹមឡើង ខ្ញុំមិន -- ភ្លឺឡើងខ្ញុំអត់ស្គាល់គ្នា ខ្ញុំទៅរកកន្លែងសម្រាកនុ៎ង ទៅគេចាប់ខ្ញុំពេលនុ៎ង បាញ់ប្រតប់ប្រតាយគ្នាពេលនុ៎ងទៅ។ ខ្ញុំក៏រត់បណ្ដើរស្ទើបណ្ដើរ នឹកឃើញខ្លួនខ្ញុំស្លាប់ពេលហ្នឹង បើគេព័ទ្ធជាប់អស់ហើយ គេចាប់ដៃជាប់អស់ហើយ។ ខ្ញុំក៏រត់គ្រលែង ប្រតប់ប្រតាយគ្នាទៅ ខ្ញុំរត់ទៅ ក៏ចេះតែរត់ពី១ម៉ែត្រ ២ម៉ែត្រ ៣ម៉ែត្រទៅ គេបាញ់មិនត្រូវ ចេះតែរត់ៗ ដោយប្រថុយប្រថានទៅ។ រត់ទាល់តែមកចូលបឹង ខ្ញុំមុជក្រោមកំផ្លោកទៅខ្ញុំ គេមកដល់ ខ្ញុំរត់រួច ខ្ញុំនៅក្រោមកំផ្លោកហ្នឹង។ ដល់ខ្ញុំនៅក្រោមកំផ្លោកហ្នឹងទៅ គេមករត់ខ្ញុំកន្លែងខ្ញុំចុះហ្នឹង រត់មិនឃើញ គេក៏ឡើងទៅ។ ដល់ឡើងទៅ គេទៅផ្លូវម្ខាង ខ្ញុំចេះតែមុជបណ្ដោះខ្លួន។ ខ្ញុំឃើញកន្លែងគេងូតទឹកស្នួលទៅត្រើយម្ខាងហ្នឹង ខ្ញុំក៏ថាទៅរកស្នួលហ្នឹង ឡើងទៅត្រើយម្ខាង ឡើងវិលមកវិញមករកស្រុក មករកកន្លែងវិញ។ ដល់ពេលខ្ញុំចេះតែមុជៗ ដល់ទឹករាក់ ខ្ញុំឡើង នឹកឃើញថា លូនទៅមិនកើត ខ្ញុំឡើងឈរ គេឃើញខ្ញុំទៀត គេតាមបាញ់ខ្ញុំ ចាប់ខ្ញុំទៀត បាញ់ខ្ញុំទៀត។ ខ្ញុំទៅពួនកន្លែងគេងូតទឹកហ្នឹង។ ដល់ម្ខាងគេព័ទ្ធជិតអស់ ខ្ញុំក៏រត់។ នឹកឃើញថា គេព័ទ្ធជុំវិញអស់ហើយ ខ្ញុំក៏ប្រថុយប្រថានរត់កាត់មុខគេហ្នឹង។

[១០:៤៧:២៣]

ខ្ញុំទៅចូលក្នុងផ្ទះគេមួយ។ ផ្ទះគេហ្នឹង ខ្ញុំចូលទៅ ក៏ខ្ញុំចេញតាមទ្វារខាងក្រោយ។ ផ្ទះគេធ្វើទាបតាមពាងទឹកគេ ខ្ញុំក៏រត់មកខាងក្រោយជាក្នុងចម្ការគេទៅ។ វាអត់ឃើញខ្ញុំ ស្មានតែខ្ញុំនៅក្នុងផ្ទះនុ៎ង វាក៏ព័ទ្ធនៅផ្ទះហ្នឹងទៅ។ ខ្ញុំក៏រត់ពីចម្ការ ចេះតែទៅ ទៅខាងក្រោយផ្ទះរហូតមក។ ទាល់តែដើរកាត់ព្រៃ អត់បាយ អត់អី ពីរយប់។ យប់ទី៣ បានទៅដល់វិហារសួគ៌នុ៎ង គេចាប់ខ្ញុំ ពួកសេនាឃុំវិហារសួគ៌ហ្នឹង គេចាប់ខ្ញុំចង់នៅនុ៎ង។ គេប្រុងសម្រាប់ខ្ញុំចោល ប៉ុន្តែវិហារសួគ៌នុ៎ង អត់ទាន់មានខាងនិរតីចូលមកទេ នៅ។ ដល់ចូលដល់វិហារសួគ៌នុ៎ង គេរត់ទៅរាយការណ៍កន្លែងស្រុកថា ចាប់បាននិរតីមួយ។ គេអត់ទាន់សម្លាប់ខ្ញុំទេ នៅ។ ដល់ពេលស្រុកមក កន្លែងស្រុកគេអត់នៅ គេនៅតែសិល្បៈភូមិភាគ គេទៅលេងនៅមុខកំពូល គេមកសម្រាកនៅហ្នឹង។ ដល់គេសម្រាកនៅហ្នឹង គេរត់មកថា ចាប់និរតីបាន ដល់មកមើលឃើញខ្ញុំ គេក៏ស្រាយទៅ។ គេស្គាល់ ១ខ្ញុំស្រាយទៅ យកខ្ញុំមកកន្លែងស្រុកទៅ។ ដល់ជួបគណៈស្រុកស្គាល់ទៅ ខ្ញុំក៏នៅនុ៎ងទៅ បានបួនប្រាំថ្ងៃ។ ដល់គេ ខាងនិរតី ខាងមជ្ឈិម គេចេះចាប់កិលតាមឃុំនានាស្រុកនានា កិលចូលមកដល់ស្រុកនុ៎ង ខ្ញុំក៏សម្រេចចិត្តថា បើខ្ញុំមិនរត់ ក៏នៅតែស្លាប់ គេចាប់នឹងដែរ។ ដល់ហើយខ្ញុំក៏សម្រេចខ្លួនរត់ចេញពីស្រុកនុ៎ងទៀតទៅ។ ខ្ញុំរត់រហូតទាល់ទៅដល់ – ដំណើរខ្ញុំវែងឆ្ងាយ

ណាស់ បើរៀបរាប់ល្អិត មិននិយាយអស់ទេ។ ខ្ញុំបានជម្រាបនឹងឯកសារហ្នឹងខ្លះ ខ្ញុំរត់។ បាទ សុំឆ្លើយប៉ុណ្ណឹងល្អិត។ សុំបញ្ចប់។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំចង់បានព័ត៌មានលម្អិតបន្តិច នៅពេលដែលលោកនិយាយអំពីអរិយក្សត្រនោះ។ ថាតើអរិយក្សត្រហ្នឹង គឺជាកន្លែងមួយដែលលោកស្នាក់នៅមួយយប់ហើយវានៅក្បែរមាត់ទន្លេងហ្នឹងមែនទេ?

[១០:៤៩:៥១]

**ឆ៖** បាទ នៅមិនជិតមាត់ទន្លេប៉ុន្មានទេ ព្រោះខ្ញុំដើរទៅបញ្ចោះកាណូតហ្នឹងប្រហែលជា១០០ម៉ែត្រជាង ប្រហែលជាង១០០ម៉ែត្រ ព្រោះខ្ញុំវង្វេងអស់ មកដល់វាងងឹតហើយ ពេលនុ៎ង វាជិតយប់ហើយ ភ្លៀវផងថ្ងៃនុ៎ង។ ព្រោះថ្ងៃខ្ញុំវង្វេង មិនចាំដឹងលិច ដឹងកើតផង ព្រោះមិនដែលដើរឆ្ងាយ វាបត់បែនច្រើនពេក។ សូមបញ្ចប់។

**ស៖** នៅពេលដែលលោកនៅជាមួយ សោ ភឹម គឺលោកស្នាក់នៅមួយយប់ជាមួយ សោ ភឹម នៅអរិយក្សត្រហ្នឹង តើ<កន្លែង>ហ្នឹង<គឺគ្រាន់តែ>ឆ្លងទន្លេ<ពី>ភ្នំពេញ<ទៅគឺដល់ហើយ តើត្រឹមត្រូវដែរឬទេ>?

**ឆ៖** ខ្ញុំបាទសូមឆ្លើយ មកដល់អរិយក្សត្រហ្នឹងមានទាន់បានឆ្លងទេ។ គ្រាន់មកដល់កន្លែងផ្ទះចម្ការហ្នឹង នៅហ្នឹងតែម្តង។ បាទ សូមបញ្ចប់។

**ស៖** ខ្ញុំចង់សួរលោកអ៊ីចេះ នៅពេលដែលលោកនៅជាមួយ សោ ភឹម ហើយលោក <>និង សោ ភឹម ស្នាក់នៅមួយយប់នៅអរិយក្សត្រ ថាតើកន្លែងហ្នឹងគឺជាកន្លែងមួយដែលនៅត្រើយម្ខាងទន្លេ<>ដែលលោកអាចមើលឃើញព្រះបរមរាជវាំងបាននោះ?

**ឆ៖** បាទ នៅខាងក្រៅទន្លេមែន នៅខាងត្រើយម្ខាង គ្រាន់តែថាមើលឃើញ ប៉ុន្តែវាឃ្លាតគ្នាឆ្ងាយ ត្រើយម្ខាងម្នាក់។ សូមបញ្ចប់។

**ស៖** តើនៅពេលនុ៎ង មានអ្នកណាមកប្រាប់លោក អំពីព័ត៌មានមួយចំនួនទាក់ទងទៅនឹងអ្វីដែលកើតឡើងនៅភ្នំពេញ<នៅពេលនោះ>ដែរឬទេ?

[១០:៥២:០០]

**ឆ៖** បាទ ពេលនុ៎ង កើតឡើងហ្នឹងមានតែអ្នកគេរត់ ឃើញតែគេរត់ អង្គភាពផ្សេងៗហ្នឹងរត់គេចគ្រប់តែគ្នាហ្នឹង។ ដល់គេរត់អ៊ីចឹង សភាពការណ៍វាដូចជាច្របូកច្របល់មួយពេលនុ៎ង។ នៅពេលនុ៎ង

គ្មាន មានក្រសួងមន្ទីរខ្លះដែលនៅនុ៎ង គេរត់ មានគេចាប់គេអី គេមកគេប្រាប់អ៊ីចឹង។ សូមចប់ចម្លើយ។

**សៈ** ការចាប់ខ្លួននៅទីក្រុងហ្នឹង តើលោកឮថាគេចាប់ខ្លួនអ្នកណាដែរ?

**ឆៈ** បាទ ខ្ញុំមិនដឹងចាប់អ្នកណាដែរទេ។ គ្រាន់ថាធ្វើការខាងជាប់ឲ្យតែ ធ្វើការខាងភូមិភាគនៅក្នុងក្រុងភ្នំពេញ ភូមិភាគបូព៌ាគឺចាប់ទាំងអស់។ សូមចប់ចម្លើយ។

**សៈ** នៅពេលដែលលោកនៅទីនោះ តើ សោ ភឹម គាត់មានព្យាយាមផ្ញើសារ ឬក៏ផ្ញើព័ត៌មានអីចូលមកទីក្រុងដែរឬទេ?

**ឆៈ** បាទ ផ្ញើទៅពីរដង។ ផ្ញើទៅភ្នំពេញ ឲ្យនីរសារគេយកទៅពីរដង តែគ្មានបានដំណឹងអីទេ។ សូមបញ្ចប់។

**សៈ** តើគាត់ឲ្យនីរសារយកទៅជូនអ្នកណាដែរ?

**ឆៈ** បាទ គាត់ឲ្យនីរសារហ្នឹងយកទៅជូន ១កន្លែងនីរសារដែលស្នាក់នៅ ១កន្លែងក្រុងភ្នំពេញនុ៎ង ឲ្យគេបន្តទៅទៀត ប៉ុន្តែមិនដឹងថាយកទៅកន្លែងណា មានមន្ទីរបន្តបន្ទាប់ទៀត។

[១០:៥៤:២០]

**សៈ** ប៉ុន្តែកាលពីឆ្នាំមុនលោកប្រាប់អ្នកស៊ើបអង្កេត អ្នកមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ <អង់គ្លេស 01353393>, ខ្មែរ <01340588>, បារាំងមានលេខ 01345525។ “នៅពេលដែលគាត់មកដល់ទីនោះគឺគាត់សរសេរលិខិតមួយផ្ញើចូលទៅភ្នំពេញ។ គាត់បានផ្ញើតាមនីរសារ ហើយថា<យើង> រង់ចាំ<សំបុត្រត្រឡប់មកវិញ ហើយ>នីរសារហ្នឹង<បាន>យកសំបុត្រ<ទៅ>ឲ្យ ប៉ុល ពត ហើយគេដេញនីរសារមកវិញ។ គាត់<សរសេរ>សំបុត្រមួយទៀត <>ហើយគេដេញអ្នកហ្នឹងមកទៀត។” តើលោកចាំទេ ថាលោកបានឆ្លើយប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជាកាលពីឆ្នាំមុន ថាសំបុត្រហ្នឹង គេឲ្យយកទៅឲ្យ ប៉ុល ពត នោះ?

**ឆៈ** បាទ អាហ្នឹងច្បាស់ហើយ ថាសំបុត្រគាត់ផ្ញើទៅ ចូលទៅភ្នំពេញហ្នឹង មានតែកម្មាភិបាលដូចជា ប៉ុល ពត អីធ្វើការជាមួយគ្នានឹងគាត់ហ្នឹង។ ចាំអ៊ីចឹងដែរ។ សូមបញ្ចប់យោបល់។

**សៈ** តើលោកចាំទេ ថាក្នុងសំបុត្រហ្នឹង គេសរសេរអំពីអ្វី?

**ឆៈ** បាទ សំបុត្រហ្នឹង យើងម៉េចនឹងដឹងលម្អិត អាការងារគេសរសេរសំបុត្រហ្នឹង។ សរសេរសំបុត្រមានអ្នកណានៅមើល បើខ្ញុំនៅតែខាងក្រៅ។ បាទ សូមបញ្ចប់។

**សៈ** ឆ្នាំមុន លោកបានប្រាប់មជ្ឈមណ្ឌលឯកសារកម្ពុជា គឺនៅទំព័រដដែល។ <>នៅពេល

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដែលគេសួរ<ទាក់ទងនឹង>សំបុត្រហ្នឹង <>លោកឆ្លើយថា "គាត់មកដល់អរិយក្សត្រហើយ ឲ្យសមមិត្តមកយក មកទទួល<គាត់ផង>"។ <>គេសួរលោក<>ថា៖ "<>សំបុត្រហ្នឹង គេសរសេរថាម៉េចដែរ? លោកឆ្លើយថា៖ <នៅក្នុងសំបុត្រគេ>សរសេរដាក់ថា "គាត់មកដល់អរិយក្សត្រហើយ <សូម>ឲ្យសមមិត្តមកយក មកទទួលខ្ញុំ ខ្ញុំមកដល់អរិយក្សត្រហើយ។ មកផ្លូវកាត់ គ្មានតាមផ្លូវសាឡាងណា<ទេ>។ <នេះជាអ្វីដែលខ្ញុំដឹង> ខ្ញុំស្តាប់ឮស្មៀន គេសរសេរហ្នឹង <ហើយ>គាត់ប្រាប់<ខ្ញុំ>។" តើលោកចាំទេ ថាលោកបានស្តាប់ឮស្មៀន នៅពេលដែលស្មៀនហ្នឹង សរសេរតាមអ្វីដែល សោ ភឹម ប្រាប់នោះ?

[១០:៥៧:១៣]

**ឆ៖** សំណួរដូចថា លោកសួរអ៊ីចឹង ធ្វើឲ្យខ្ញុំវិល់នឹកទៅមុខ នឹកទៅក្រោយ ដល់ពេលអ៊ីចឹង ខ្ញុំដូចជាពិបាកនឹងសេចក្តីឆ្លើយទៀត ដល់សំណួរដដែលៗ សួរដដែលៗអ៊ីចឹង ខ្ញុំ ពេលនោះ។ លោកដឹងដែរហើយ ដល់ពេលនេះ ចេះតែសួរជជីកឫសជីកគល់ខ្ញុំ ដល់អ៊ីចឹង ធ្វើឲ្យខ្ញុំវង្វេង ដល់នោះវង្វេងភ្លេច។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី នេះជានីតិវិធីតាមផ្លូវតុលាការ គឺសួរដើម្បីស្វែងរកការពិត។ អ៊ីចឹងហើយបានជាកិច្ចការតុលាការហ្នឹង គឺមានការប្រយ័ត្នប្រយែងក្នុងការរៀបចំសំណួរ ហើយអ្នកស្តាប់ហ្នឹង គឺឲ្យស្តាប់ឲ្យបានហ្មត់ចត់ ហើយសូមឆ្លើយតប ហ្នឹងហើយ។ វាមិនមែនជារឿងសួរដដែលទេ។ វាជារឿងសួរបញ្ជាក់ដើម្បីឲ្យរំលេចឲ្យឃើញច្បាស់លាស់ ថាតើរឿងនុ៎ង វាពិតជាកើតឡើងយ៉ាងដូចម្តេច។ ពីព្រោះលោកបានឆ្លើយម្តងហើយ ដល់ពេលយើងសួរបញ្ជាក់សាឡើងវិញ គឺជាសាធារណៈដែលមានសាធារណជនបានស្តាប់ឮ ទាំងចំពោះមុខ អង្គុយនៅក្នុងសាលសវនាការនៅទីនេះ ក៏ដូចជាតាមប្រព័ន្ធផ្សព្វផ្សាយផ្សេងៗនេះ ជាសាធារណៈ ដើម្បីអង្គជំនុំជម្រះពិចារណានោះ វាត្រឹមត្រូវដែរឬទេ។ វាជៀសវាងការប្រើប្រាស់អត្តនោម័តិ ដែលវាយតម្លៃថាមិនយុត្តិធម៌។ ពីព្រោះសាធារណជនមិនស្តាប់ ឬក៏ធ្វើទៅវាខុសពីការដែលសាក្សីឆ្លើយតប។ ដូច្នេះលោកត្រូវប្រឹងប្រែងប្រយ័ត្ន ស្តាប់សំណួរឲ្យបាន ហើយឆ្លើយតបឲ្យបានត្រឹមត្រូវតាមសំណួរ។ សំណួរ មានសំណួរទូទៅ មានសំណួរអត្ថាធិប្បាយ ហើយមានសំណួរជាក់លាក់។ លោកព្យាយាមឆ្លើយតបនឹងសំណួរ ហើយបើធ្វើមិន សំណួរមិនច្បាស់ទេ សូមលោកសុំឲ្យអ្នកសួរហ្នឹង សួរបញ្ជាក់សាជាថ្មីម្តងទៀត។

[១០:៥៩:១១]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី អ្វីដែលយើងចាប់អារម្មណ៍ គឺកាពិត។ អ្វីដែលខ្ញុំអានឲ្យលោកស្ដាប់ គឺជាអ្វីដែលគេកត់ត្រា ថាជាពាក្យសម្ដីរបស់លោកកាលពីឆ្នាំមុន។ គឺថានៅពេលដែលលោកស្ដាប់ឮស្មៀន<> ស្មៀនប្រាប់<លោក>ថាអ៊ីចឹង <ហើយលោកចាំពាក្យទាំងអស់នោះ> គឺថា សោ ភឹម បានឲ្យសរសេរថា “ឲ្យសមមិត្តមកទទួលយកខ្ញុំ ខ្ញុំមកដល់អរិយក្សត្រហើយ”។ តើលោកចាំថា តើនេះគឺជាអ្វីដែលគេសរសេរនៅក្នុងសំបុត្រនោះ មែនទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ សរសេរ ដល់គាត់មកដល់ហ្នឹង ក៏គាត់មានតែចូលភ្នំពេញ គាត់ថា អ៊ីចឹងមែន។ សូមបញ្ចប់។

**ស៖** អរគុណលោកសាក្សី។ លោកបានប្រាប់អំពីអ្វីដែលកើតឡើងចំពោះក្រុមលោក នៅពេលដែលមានមនុស្សមួយក្រុមមកវាយប្រហារនៅអរិយក្សត្រហ្នឹង។ តើលោកដឹងទេថា ពួកគេនោះជាអ្នកណា? តើពួកគេមកពីកងអ្វី ឬក៏មកពីក្រុមអ្វីដែរ?

**ឆ៖** បាទ ខ្ញុំអត់បានដឹងថា ពួកនុ៎ងជាក្រុមអ្នកណាទេ ហើយអ្នកទេ ពីព្រោះមានប្រដាប់ដោយអាវុធទាំងអស់ ស្លៀកសម្លៀកបំពាក់វាដូចគ្នាទាំងអស់។ គ្រាន់តែមិនដឹងថា មកពីអង្គភាពណា កងណា កងពលអី ស្អីហ្នឹង គឺអត់បានដឹងទេ។ សូមចប់សំណួរ។

[១១:០០:៥៤]

**ស៖** សូមអរគុណ។ លោកបាននិយាយអំពីអ្វីដែលបានកើតឡើងចំពោះលោក លោកថា លោកបានមកជាមួយ សោ ភឹម និងមនុស្ស<>ប្រាំពីរនាក់ទៀត។ អ៊ីចឹងក្នុងចំណោមអ្នកដែលមកជាមួយលោក មកដល់អរិយក្សត្រនេះ តើលោកដឹងថា មានអ្វីកើតឡើងទៅដល់អ្នកទាំងនោះទេ? ហើយលោកធ្លាប់បានជួបអ្នកទាំងនោះឡើវិញទេ?

**ឆ៖** បាទ អ្នកទាំងនោះ ខ្ញុំមិនដែលជួបវិញទេ ហើយពេលដែលខ្ញុំចុះទៅបញ្ចោះកាណូតទៅនុ៎ងវាបែកគ្នាបាត់រហូតតែម្ដង ហើយមិនដែលបានជួបវិញទេ ទាល់នឹងរាល់ថ្ងៃហ្នឹងតែម្ដង។ សូមបញ្ចប់សំណួរ។

**ស៖** ចុះ សោ ភឹម តាមដែលលោកដឹង តើមានអ្វីកើតឡើងចំពោះ សោ ភឹម?

**ឆ៖** បាទ ក្នុងមួយពេលនុ៎ង ទាល់តែខ្ញុំ គេចាប់ខ្ញុំនៅវិហារសួគ៌នុ៎ង បានស្រុកវិហារសួគ៌នុ៎ង គេ

ប្រាប់ខ្ញុំ ថៅហ្វាយស្រុកនុ៎ង។ គេប្រាប់ថា សោ ភឹម ហ្នឹងមិនទាន់ស្លាប់នៅ ទៅដល់កន្លែងស្រីសន្ធរ ហើយ ស្រុកស្រីសន្ធរ បាទ ខ្ញុំឮអ៊ីចឹង។ សូមបញ្ចប់សំណួរ។

**ស៖** តើខ្លួនលោកផ្ទាល់នេះបានជួបនឹង សោ ភឹម ចុងក្រោយបំផុតនៅកន្លែងណា នៅអរិយក្សត្រ ឬនៅកន្លែងណា<ក្នុងពេលដែលរត់គេចខ្លួន>?

**ឆ៖** បាទ ខ្ញុំជួបតែអាធ្វើដំណើរមកហ្នឹង ជួបតែប៉ុណ្ណឹង អាយប់ដែលគេកើតបាតុភាពនុ៎ង បែកគ្នារហូតតែម្តង មានបានជួបទៀតទេ។ សូមចប់។

**ស៖** តើរឿងដែលលោកបានជួបចុងក្រោយហ្នឹង គិតទៅរយៈពេលប៉ុន្មានថ្ងៃក្រោយពេលនោះមក?

[១១:០៣:៣០]

**ឆ៖** ប្រហែលជា ខ្ញុំមិនបានចាំថ្ងៃទេ ប៉ុន្តែប្រហែលជាយូរ ប្រហែលជា១០ថ្ងៃអីជាង ជិតតែនេះដែរហ្នឹង ទម្រាំពេលដែលឮដំណឹងទៅមកថា ស្លាប់ គេចាប់គេអីហ្នឹង ប្រហែលជាជាង១០ថ្ងៃលើ។ ប៉ុន្តែខ្ញុំអាជួបពីមុនមកនុ៎ង ខ្ញុំនៅជាមួយគាត់ហ្នឹង ជួបហ្នឹង ប្រហែលជាកន្លះខែហើយ នៅៗ ប៉ុននៅដំណើរតាំងពីមុនមកនោះ ដែលវេនខ្ញុំត្រូវតាមគាត់នុ៎ង។ សូមចប់សំណួរ។

**ស៖** ចុះតើលោកបានឮថា មានអ្វីកើតឡើងចំពោះ សោ ភឹម ដែរ?

**ឆ៖** ខ្ញុំមិនឮអ្វីទេ មានកើតឡើងដែរ គ្រាន់តែថាឮ ដល់អាពេលខ្ញុំមកហ្នឹង ឮថាតែគេ គាត់សម្លាប់ខ្លួនគាត់ ពេលដែលគេឡោមព័ទ្ធចាប់ ឮតែអ៊ីចឹង។

**ស៖** ចុះតើលោកដឹងថា សាកសពរបស់គាត់ហ្នឹងគេយកទៅណាមកណាដែរ?

**ឆ៖** បាទ សាកសពហ្នឹងខ្ញុំអត់បានដឹង អត់បានឃើញផ្ទាល់ភ្នែកទេ។ ឮតែ ខ្ញុំដើរមកតាមផ្លូវ ខ្ញុំវិលពីនុ៎ងមករហូត តាមផ្លូវគេនិយាយថា គេដាក់រទេះសេះដឹកមកតាមផ្លូវប្រាប់ប្រជាជនថា ខ្មោចក្បត់ជាតិ ក្បត់ជាតិអ៊ីចឹង។ អ្នកស្រុកគេប្រាប់អ៊ីចឹង រហូតមកតាមផ្លូវហ្នឹង។ សូមចប់សំណួរ។

**ស៖** ខ្ញុំសួរលោកអំពីសាកសពរបស់គាត់។ ឆ្នាំទៅនេះលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្មែរ 01340597, បារាំង 01345534 ហើយអង់គ្លេស 01353407។ គេបានសួរលោក៖ "តើ សោ ភឹម ពិតជាស្លាប់នៅមន្ទីរស្រុកនៅ<ព្រែកពោធិ៍>? លោកបានឆ្លើយថា៖ "នៅក្នុង<មន្ទីរស្រុក នៅព្រែកពោធិ៍ ក្នុង>ស្រុកស្រីសន្ធរ នៅកន្លែងនោះគេសម្លាប់គាត់នៅទីនោះ ហើយពីរបីថ្ងៃក្រោយមក ថ្ងៃបន្ទាប់ ឬក៏ពីរថ្ងៃបន្ទាប់មកទៀត ខ្ញុំចាកចេញពីកន្លែងនេះ ខ្ញុំដើរចេញទៅ មានគេនិយាយថា គេបានកាត់

ក្បាលគាត់ ហើយរះពោះរបស់គាត់<រួចដាក់ទឹកកកចូល> ហើយដាក់គាត់ដឹកតាមរទេះសេះ ដើម្បីដឹកគាត់ជុំវិញ ស្រែកប្រាប់ប្រជាជនអំពីព្រឹត្តិការណ៍នេះ។" តើលោកនៅចាំទេថា សាកសពរបស់ សោ ភឹម នេះត្រូវបានគេដឹកតាមរទេះសេះ ហើយនៅពេញភូមិភាគបូព៌ានោះ?

[១១:០៧:១៤]

**ឆ៖** បាទ ខ្ញុំគ្រាន់តែដឹង ហើយឮ ប៉ុន្តែគ្រាន់ថា មើលអត់ឃើញច្បាស់ផ្ទាល់នឹងភ្នែក ខ្ញុំមិនដែលជួប គ្រាន់ថាអ្នកភូមិគេប្រាប់ អ្នកស្រុកគេនិយាយអ៊ីចឹង។ អ្នកភូមិ អ្នកស្អីបានគេដឹង ត្រង់ខ្ញុំៗអត់បានឃើញទេ គ្រាន់តែថាឮ ដឹងឮ គ្រាន់ថាឃើញផ្ទាល់ភ្នែកអត់បានឃើញទេ។

**ស៖** សូមអរគុណចំពោះការបញ្ជាក់បំភ្លឺនេះ។ លោកសាក្សី នៅពេលដែលលោកធ្វើការជាមួយនឹង សោ ភឹម មុនពេលព្រឹត្តិការណ៍នេះកើតឡើង ដែលនាំឱ្យឈានទៅដល់ការស្លាប់ខ្លួននេះ និងឆ្នាំមុនៗនោះទៀត និងពេលដែលលោកឡើងមកភ្នំពេញ តើលោកឡើងមកភ្នំពេញហ្នឹង លោកទៅកន្លែងណាខ្លះ?

**ឆ៖** បាទ ដូចខ្ញុំជម្រាបពីមុនហ្នឹង ខ្ញុំមិនបានដើរដល់កន្លែងណាទេ ខ្ញុំតែត្រឹមកន្លែងវត្តឧណ្ណាលោមហ្នឹង តែត្រឹមហ្នឹងខ្ញុំ។ សូមបញ្ចប់សំណួរ។

**ស៖** តើលោកជូន សោ ភឹម ទៅប្រជុំនៅម្តុំណា?

**ឆ៖** ខ្ញុំសូមឆ្លើយដូចខ្ញុំនិយាយថា តែខ្ញុំមកតែត្រឹមវត្តឧណ្ណាលោមហ្នឹងទេ ត្រង់គាត់ទៅប្រជុំកន្លែងណា ខ្ញុំអត់ដឹងទេ ព្រោះឡានគេមកយកមុខវត្តហ្នឹង។ បាទ សូមបញ្ចប់។

[១១:០៩:០៣]

**ស៖** កាលពីឆ្នាំទៅ ហាក់បីដូចលោកនៅចងចាំច្រើនណាស់ ខាងមជ្ឈមណ្ឌលឯកសារកម្ពុជាសួរលោកគឺERN អង់គ្លេស 01353345, បារាំង 01345496 និងខ្មែរ 01340558។ គេបានសួរលោកថា៖ "តើគាត់មកភ្នំពេញមកធ្វើអ្វី? លោកឆ្លើយថា "គាត់មកប្រជុំ គាត់ចូលរួមប្រជុំនៅព្រះបរមរាជវាំង ប៉ុន្តែប្រជុំអំពីអ្វីយើងមិនដឹងទេ។ នៅពេលដែលទៅដល់ព្រះបរមរាជវាំងហ្នឹង គឺខ្ញុំស្នាក់នៅ<មន្ទីរនីរសារនៅវត្តឧណ្ណាលោម ។ គេសួរលោកថា តើគាត់ចូលរួមប្រជុំនៅឯណា? លោកឆ្លើយថា> គាត់ដើរចូលទៅក្នុងព្រះបរមរាជវាំង។" ហើយក្រោយមកទៀតលោកបានឆ្លើយថា៖ "ខ្ញុំទៅមន្ទីរនីរសារ<នៅវត្តឧណ្ណាលោមដើម្បីសម្រាក> ហើយនៅពេល<ចប់ការប្រជុំ> ពេលខ្លះគាត់ដើររហូតមកដល់វត្តឧណ្ណា-លោមឯណោះ ហើយមានគេទៅយកគាត់មក។ ឯឡាន ប៉ុល ពត វិញគឺថាចូលដល់របងតែម្តង។" តើនេះវាជួយរំឭកដល់ការចងចាំរបស់លោកទេដែលលោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាពី

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ឆ្នាំទៅថា លោកបានជូន សោ ភឹម មកប្រជុំនៅព្រះបរមរាជវាំង?

**ឆ៖** បាទ ហ្នឹងហើយ មកដល់តែត្រឹមរបងហ្នឹង របងវត្តឧណ្ណាលោម ហើយជាប់នឹងរបងវាំងហ្នឹង ដល់ត្រឹមហ្នឹង។ គាត់ដើរចូល ឬក៏ឡានគេមកទទួលត្រឹមហ្នឹងទៅ ខ្ញុំក៏នៅត្រឹមហ្នឹងទៅ។

**ស៖** តើលោកមានបានឃើញមេដឹកនាំណាផ្សេងទៀត ដែលលោកអាចស្គាល់ អាចចំណាំបានទេ ក្រៅពី សោ ភឹម <នៅ>ពេលដែល<>លោកជូនគាត់មកប្រជុំនៅព្រះបរមរាជវាំង?

**ឆ៖** បាទ មិនបានឃើញទេ។ ឧបមាថាមក ៗតែខ្ញុំហ្នឹង មកដល់អាររបង ព្រោះរបងវត្ត ហើយនិងរបងវាំងហ្នឹង វាជាប់គ្នាហ្នឹង ដល់អាត្រឹមហ្នឹង។ សូមចប់សំណួរ។

**ស៖** តើមានពេលណាមួយនោះ សោ ភឹម នៅសម្រាកពេញមួយយប់នៅភ្នំពេញ ហើយលោកត្រឡប់ទៅភូមិភាគបូព៌ាវិញដែរឬទេ?

[១១:១១:៥១]

**ឆ៖** បាទ មានពេលខ្លះដែរ ជួនកាលដែរ។ ជួនកាលមាន ខ្ញុំដូចជួបព្រឹត្តិការណ៍ហ្នឹងម្តង ខ្ញុំជូនគាត់មកដល់ ខ្ញុំទៅវិញ មកដល់មាត់របង ខ្ញុំទៅវិញ មានដែរ។ ហើយដល់រយៈពេលបួនប្រាំថ្ងៃ បានពួកខ្ញុំឡើងមកយក។ សូមចប់សំណួរ។

**ស៖** តើលោកធ្លាប់ដែលជូន សោ ភឹម ចូលរួមប្រជុំក្នុងអង្គប្រជុំណាមួយធំៗ<ដែលមានមនុស្សចូលរួមច្រើននាក់>ដែរឬទេ?

**ឆ៖** បាទ មិនដែលទេ។ មិនដែល ប្រជុំធំ មិនដែលទេ។ សូមចប់។

**ស៖** នៅក្នុងភូមិ<ភាគ>បូព៌ា <នៅពេលដែលលោកនៅជាមួយគាត់> តើ សោ ភឹម ដែល<ធ្លាប់>ឈប់និយាយជាមួយនឹង<ក្រុម>កម្មាភិបាល ឬក៏ឈប់និយាយជាមួយនឹងហ្វូងអ្នកស្រុកអ្នកភូមិដែរឬទេ?

**ឆ៖** បាទ មានដែរ មានឈប់និយាយលេង សួរសុខទុក្ខអីចឹងដែរ មាន។ សូមចប់សំណួរ។

**ស៖** តើ សោ ភឹម និយាយអំពីអ្វីដែរ? តើគាត់និយាយអំពីបដិវត្តន៍ឬ?

**ឆ៖** ខ្ញុំបាទឃើញតែគាត់និយាយតែពីរឿងសួរសុខទុក្ខ សុខសប្បាយ ហើយនិងខំធ្វើការងារ។ មើលកាលនុ៎ង ជួយប្រជាពលរដ្ឋ គ្រាន់ថាធ្វើបង្កបង្កើនផល កាលនុ៎ង គេលើកតម្កើងតែអារឿងបង្កើនផលឲ្យបានសន្ទុះខ្លាំងក្លា តែប៉ុណ្ណឹងបាទ។ ដល់និយាយកិច្ចការអី ដូចថាគ្មានឮទេ។

**ស៖** តើគាត់មានបានប្រាប់ប្រជាជនថា អង្គការគឺជាអ្នកនឹងផ្តល់ -- តើគាត់មាននិយាយថា បើ

ប្រជាជនខំប្រឹងប្រែងធ្វើការ អង្គការនឹងយកចិត្តទុកដាក់ទៅលើពួកគាត់វិញដែរឬទេ?

**ឆ៖** បាទ ត្រង់កន្លែងហ្នឹង គឺគេមាននិយាយគ្រប់តែដំណើរការទាំងអស់ ដែលការងារដែលធ្វើហ្នឹង កន្លែងណាក៏ៗវាមានដែរ អារឿងថា ពេលណាយើងខំសម្បូរហូរហៀរទៅ វាសម្បូរសប្បាយទៅ វាហូបឆ្អែត ស្អីឆ្អែតដូចតែនេះហ្នឹង។ គ្រាន់ថាក្នុងទ្រឹស្តីហ្នឹង គេលើកឡើងក្នុងឯកសារហ្នឹង គឺមានរហូតហ្នឹង។ សូមចប់យោបល់។

[១១:១៥:០១]

**ស៖** នៅក្នុងអង្គប្រជុំទាំងនេះ តើ សោ ភឹម មានបានជំរុញទឹកចិត្តប្រជាជននេះ ថាត្រូវតែស្មោះត្រង់ជាមួយនឹងអង្គការដែរឬទេ?

**ឆ៖** បាទ ខ្ញុំមិនដែលបានឮគាត់ជំរុញអីចឹងទេ។ គ្រាន់តែថា គាត់ ដូចតែនៅជាមួយគាត់ហ្នឹងក៏គេដឹងហើយ ថានៅត្រង់ណាគឺជាមួយមានមេមានកោយត្រង់ណា ក៏គេដូចថា គេស្មោះស្ម័គ្រត្រង់ហ្នឹងហើយ។ បើថាត្រង់ជំរុញ មិនជំរុញ អាហ្នឹងខ្ញុំមិនដែលឮទេ។ សូមចប់បាទសំណួរ។

**ស៖** លោកថា លោកគឺជាសាច់ញាតិរបស់ សោ ភឹម ទោះសាច់ញាតិឆ្ងាយបន្តិចក៏ដោយ លោកគឺជាអ្នកការពារផ្ទាល់របស់គាត់ តើ សោ ភឹម មានដែលគឺថារាប់បញ្ចូលទាំងឈ្មោះលោកមួយផង ដើម្បីចូលរួមនៅក្នុងផែនការធ្វើរដ្ឋប្រហារទម្លាក់<ថ្នាក់ដឹកនាំខ្មែរក្រហម>នោះដែរឬទេ?

**ឆ៖** បាទ មិនដែលទេ ព្រោះពួកខ្ញុំនៅវ័យក្មេងៗ គាត់មិននិយាយការងារនយោបាយ គាត់មិននិយាយទេ។ គាត់និយាយតែពីថាខំរៀនសូត្រ តែប៉ុណ្ណឹង អារឿងថាការងារស្អី គាត់មិននិយាយប្រាប់ទេយើងក្មេង។ សូមបញ្ចប់។

**ស៖** នៅពេលដែលលោកនៅជាមួយនឹង សោ ភឹម នោះ តើ សោ ភឹម ដែលបានធ្វើដំណើរទៅប្រទេសចិនដែរឬទេ? ខ្ញុំមិនសួរពីលោកទេ គឺខ្ញុំសួរអំពីអំឡុងពេលឆ្នាំ១៩៧៦, ៧៧ និង<ដើមឆ្នាំ>៧៨ តើ សោ ភឹម ដែលធ្វើដំណើរទៅប្រទេសចិនដែរឬទេ?

[១១:១៧:០៨]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយ កាលដែលខ្ញុំមកនៅជាមួយគាត់ហ្នឹង ខ្ញុំ គាត់ក៏មិនដែលទៅដែរ តែបើទៅកាលមុនខ្ញុំមកនៅ ប្រហែលជាបានទៅ។ កាលហ្នឹង ក៏ខ្ញុំមិនដឹងដែរជំនាន់ហ្នឹង ប៉ុន្តែខ្ញុំមកនៅហ្នឹងគាត់មិនបានទៅទេ ព្រោះខ្ញុំនៅហ្នឹងវាក្រោយដែរ។ បាទ សូមចប់សំណួរ។

**ស៖** តើ សោ ភឹម គាត់មានបញ្ហារោគស្បែកដែរឬទេ?

01391951



**ឆ៖** បាទ មាន។ មានគាត់កើតរមាស់ រមាស់ស្បែក។ សូមចប់ឃោបល់។

**ស៖** តើ សោ ភឹម ដែលនិយាយអំពីការគំរាមកំហែងពីសំណាក់វៀតណាមនៅក្នុងអង្គប្រជុំណាមួយដែរឬទេ? ដូចជានិយាយទៅកាន់<លោក ឬអ្នកដទៃទៀត ឬទៅកាន់សាធារណជនដែរឬទេ>?

**ឆ៖** បាទ កន្លែងហ្នឹង ខ្ញុំៗមិនដឹងទេ មិនដឹង។ សូមចប់សំណួរ។

**ស៖** នៅក្នុងខែមករា ១៩៧៨ កងទ័ពវៀតណាមបានដកចេញពីប្រទេសកម្ពុជា ក្រោយពីចូលមកកាន់ប្រទេសនេះ នៅពេលដែលវៀតណាមដកចេញទៅវិញលើកនោះ តើគេមានប្រារព្ធពិធីអបអរសាទរអីដែរទេ នៅភូមិភាគបូព៌ានោះ?

**ឆ៖** បាទ ពេលនោះខ្ញុំអត់ដឹងផង ខ្ញុំមិនទាន់បានទៅទេ កន្លែងហ្នឹង។

**ស៖** អំមិញនេះខ្ញុំសួរលោកអំពីខែមករា ១៩៧៨ <លោកក៏នៅទីនោះដែរ> តើ សោ ភឹម ដែលជួបលេខាតំបន់ទាំងឡាយនោះដែរឬទេ?

**ឆ៖** បាទ កាលដែលជំនាន់ហ្នឹងជួប ប៉ុន្តែខ្ញុំមិនសូវស្គាល់គេថាពីណាៗ ប៉ុន្តែជួបកម្មាភិបាល ជួបច្រើន ជួបដែរ ប៉ុន្តែគ្រាន់តែថាខ្ញុំមិនស្គាល់ មិនដឹងតួនាទីស្អី ឋានៈស្អី ព្រោះគេមិននិយាយប្រាប់ខ្ញុំផង។

[១១:១៩:៥០]

**ស៖** តើលោកនៅនឹកឃើញដែរឬទេថា សោ ភឹម នេះគាត់បានផ្តល់ជាព័ត៌មានអ្វីខ្លះទៅដល់អ្នកទាំងនោះ?

**ឆ៖** បាទ ខ្ញុំមិនដឹងច្បាស់ទេអាហ្នឹង ព្រោះវាមិន -- ព្រោះខ្ញុំនៅខាងក្រៅ ពេលដែលជួបកម្មាភិបាលជួបស្អីហ្នឹង ព្រោះខ្ញុំនៅតែការពារខាងក្រៅហ្នឹង។ កម្មាភិបាលដែលចូលទៅកន្លែងក្នុងប្រជុំទៅ គេនិយាយកិច្ចការអី ខ្ញុំអត់បានដឹង ព្រោះខ្ញុំមិនប៉ាន់ឆ្លើយ ពីព្រោះមិនដឹងការពិត។

**ស៖** ខ្ញុំសូមព្យាយាមជួយរំឭកដល់ការចងចាំរបស់លោក។ កាលពីឆ្នាំទៅ លោកបានឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជាគឺ <013533368>*(ស៊ីក)*, ខ្មែរ 01340572, បារាំង 01345510។ លោកបាននិយាយអំពី សោ ភឹម៖ "គាត់បានទៅជួបប្រជុំជាមួយនឹងប្រធានតំបន់។ នៅក្នុងអង្គប្រជុំគាត់ដាក់ផែនការ គឺថាជាផែនការដែលរៀបចំឡើងដោយថ្នាក់លើ គឺថាពួកគេទាំងអស់ត្រូវតែធ្វើអ្វីទៅតាមផែនការរបស់ថ្នាក់លើ។" តើលោកនៅនឹកឃើញទេថា សោ ភឹម ធ្លាប់បានប្រាប់កម្មាភិបាលក៏ដូចជាលេខាស្រុក លេខាតំបន់ថា អ្នកទាំងអស់គ្នាហ្នឹងគឺថាត្រូវតែអនុវត្តតាមផែនការរបស់ថ្នាក់លើ? លោកដែលធ្លាប់ឮគាត់និយាយអីចឹងទេ?

---

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ឆ៖** បាទ ជំនាន់នោះ សូម្បីតែកម្មាភិបាលណា ក្រសួងមន្ទីរណាក៏ដោយ តែធ្វើការពាក់ព័ន្ធគឺផែនការថ្នាក់លើដាក់មក បានប៊ានធ្វើដែរ ទាំងអស់គ្នាហ្នឹង។ មិនមែនថានេះទេ គឺគ្រប់ក្រសួង។ សូមចប់។

[១១:២២:០៥]

**ស៖** លោកបានលើកឡើងនូវចំណុចមួយគួរឲ្យចាប់អារម្មណ៍ ដែលលោកបានឆ្លើយជូនមជ្ឈ-មណ្ឌលឯកសារកម្ពុជាឆ្នាំទៅ គឺអង់គ្លេស 01353377, ខ្មែរ <0134078>*(ស៊ីក)*, បារាំង 01345 516។ លោកសាក្សីអ្វីដែលលោកបានឆ្លើយពីឆ្នាំទៅនោះ៖ “បើសិនណាជាមានប្រធានណាមួយ មានការខ្វះខាតគឺគេ នៅក្នុងស្រុកទាំងនោះ នៅពេលដែលគេបានរំឭកថា ត្រូវតែអនុវត្តផែនការ<>សេដ្ឋកិច្ចនេះឲ្យបានច្បាស់លាស់ បើមិនអ៊ីចឹងទេ ត្រូវតែស្លាប់។” តើលោក<អាចពន្យល់បានទេថា លោកចង់សំដៅទៅលើអ្វីដែលថា> បើសិនណាជាលេខាស្រុកណាមួយមិនបានអនុវត្តតាមទ្រឹស្តី <និង>ផែនការនេះឲ្យបានច្បាស់លាស់ហ្មត់ចត់ទេ គឺថាអាចប្រឈមមុខនឹង<ការ>ស្លាប់ហើយ។ <>

**ឆ៖** ខ្ញុំមិនដែលធ្លាប់ឮទេ គ្រាន់តែថា ផែនការគេដាក់មក គឺរឿងផែនការគេចេះតែថាអ៊ីចឹងហើយ ប៉ុន្តែដល់អ្នកអនុវត្តនោះ វាមិនបានគ្រប់តែផែនការនោះទេ។ ប៉ុន្តែគ្រាន់ទ្រឹស្តីគេត្រូវធ្វើ វាធ្វើអ៊ីចឹងមែន ច្បាប់ សូម្បីតែច្បាប់ឯណាក៏ដោយ ក៏វាត្រូវធ្វើ អាពីលើដាក់មក បានអាក្រោមវាប៊ានធ្វើ។ សូមចប់។

**ស៖** សូមជួយកែតម្រូវ បើខ្ញុំយល់ច្រឡំ។ លោកថា បើសិនណាជាកម្មាភិបាលមូលដ្ឋាននោះអនុវត្តទៅតាមទ្រឹស្តីរបស់ខ្មែរក្រហមឲ្យបានហ្មត់ចត់ <ប្រជាជននឹងមានអីហូបគ្រប់គ្រាន់ ប៉ុន្តែ> បើអនុវត្តមិនបានហ្មត់ចត់ មានការធ្វេសប្រហែស <>កម្មាភិបាលទាំងនោះ អាចប្រឈមនឹងសេចក្តីស្លាប់ហើយ។ លោកឮអ៊ីចឹងទេ?

**ឆ៖** ខ្ញុំមិនដែលឮផង ពេលហ្នឹង។ ខ្ញុំមិនដឹងផង ព្រោះមិនឮ។ សូមបញ្ចប់។

[១១:២៤:៣៣]

**ស៖** សូមអរគុណ។ ខ្ញុំព្យាយាមសួរពាក្យរបស់លោកទេ។ ឥឡូវខ្ញុំយកចំណុចមួយទៀត ដែលលោកឆ្លើយកាលពីឆ្នាំទៅ នៅទំព័រដដែលដែលលោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា។ លោកឆ្លើយថា៖ “នៅពេលនោះ កាលណាគេឃើញអ្នកណាជិះម៉ូតូ ទោះបីអ្នកនោះមាឌតូច <ឬ>មាឌធំអីក៏ដោយ កាលណាប្រជាជនឃើញគឺប្រជាជនខ្លាចណាស់។ អ៊ីចឹងនៅសម័យនោះ <បើទោះជាធ្វើការលំបាក និង

ហត់នឿយយ៉ាងណាក៏ដោយ ពួកគេនៅតែខំធ្វើការបន្តទៀត។ ពួកគេមានការភ័យខ្លាចខ្លាំងណាស់>។" នៅពេលដែលលោកនិយាយថា អ្នកដែលជិះម៉ូតូ លោកសំដៅទៅកម្មាភិបាល ឬក៏លោកនិយាយពីអ្នកណាដែលមានតួនាទីនៅក្នុងរបបខ្មែរក្រហមនោះ?

**ឆ៖** បាទ ខ្ញុំនិយាយកាលនុ៎ង ប្រជាពលរដ្ឋ ប្រជាជនហ្នឹងគឺបាក់ ខ្លាច ខ្លបខ្លាចតែម្តងឲ្យតែឃើញអ្នកដែលមានម៉ូតូ មានឡានជិះ គឺសុទ្ធតែមានអ្នកកាន់អំណាច ពីព្រោះប្រជាពលរដ្ឋគ្នាតែដើរជួបតែ ឮតែចប តែដងរែក បង្គីកាប់គាស់ដីរាល់តែថ្ងៃ បើថាដល់មានអ្នកគេជិះហ្នឹង ពិតជាមានអ្នកកាន់អំណាចហើយ។ បើមិនខ្លាចគេម៉េច ព្រោះគឺខ្លាចតែម្តង ប្រជាពលរដ្ឋ។ បាទ អ៊ីចឹងមែន។

**ស៖** សូមអរគុណ។ តើ ប៉ុល ពត ធ្លាប់បានទៅភូមិភាគបូព៌ាដែរឬទេ នៅពេលដែលលោកធ្វើការនៅទីនោះ?

**ឆ៖** បាទ ដូចតែកាលនុ៎ង ដូចតែមានធ្លាប់ទៅច្រើនណាស់កម្មាភិបាល គ្រាន់តែថាខ្ញុំស្គាល់មិនច្បាស់។ ទាល់តែមានគេអ្នកប្រាប់ថា បានខ្ញុំស្គាល់ ឬក៏គេប្រាប់ឈ្មោះនុ៎ងខុស ក៏ខ្ញុំមិនដឹងរឿងថា អ្នកណាឈ្មោះអីៗទេ ប៉ុន្តែមានទៅកម្មាភិបាល។ សុំចប់។

**ស៖** តើលោកមានទឹកឃើញ<>ដំណើរទស្សកិច្ច<>របស់ ប៉ុល ពត <យ៉ាងហោចណាស់ម្តង> ទៅភូមិភាគបូព៌ាដែរឬទេ?

[១១:២៧:០៨]

**ឆ៖** មាន ប៉ុន្តែគ្រាន់ខ្ញុំចំណាំមិនបានដឹងថា ពេលណា ពេលណា ប៉ុន្តែមានកម្មាភិបាលទៅ ព្រោះកន្លែងធ្វើការគឺមានទៅ។ សុំបញ្ចប់សំណួរ។

**លោក នីកូឡាស គូមជែន៖**

<តើលោកនៅចាំថា-->

**ប្រធានអង្គជំនុំ៖**

សំណួរសួរជាក់លាក់គឺ សំដៅទៅលើ ប៉ុល ពត មិនមែនសួរកម្មាភិបាលទូទៅទេ។ សួរថាជំនាន់នោះ លោកស្គាល់ ប៉ុល ពត ដែរឬទេ? នេះបើចង់បញ្ជាក់បន្ថែម ព្រោះសំណួរអំមិញមិនសួរទេក្នុងន័យអ៊ីចឹង។ ហើយដែលឃើញ ប៉ុល ពត ហ្នឹងទៅធ្វើការងារ ទៅនៅឯភូមិភាគបូព៌ាដែរឬទេ? សួរតែចំពោះ ប៉ុល ពត មួយទេ។

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ដែល ដែលបានទៅ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** នៅពេលហ្នឹង តើគេមានរៀបចំជាក្បួន ជាពិធីធំដុំអី ដើម្បីទទួលស្វាគមន៍ ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ ពេលនុំងមានរៀបចំដែរ ឧទាហរណ៍ថាភ្ញៀវមកមានធ្វើអាហារហូបចុកអីចឹងដែរមាន។

[១១:២៨:៤០]

**ស៖** ចុះ សោ ភឹម មានវត្តមាននៅទីនោះដើម្បីឈរចាំទទួលស្វាគមន៍ ប៉ុល ពត ដែរឬទេ?

**ឆ៖** បាទ ចឹមិនមាន មានៗ។

**ស៖** ខ្ញុំសុំសួរអំពីដំណើររបស់ សោ ភឹម មកកាន់ភ្នំពេញ ដើម្បីដោះស្រាយបញ្ហា។ សាក្សីដែលនឹងចូលខ្លួនមក ដែលមេធាវីបានលើកឡើងនោះគឺ សាក្សី 1070, ERN 01354203, ខ្មែរ 01340501, បារាំង 01348544 សាក្សីរូបនេះបានឆ្លើយ សុំដកស្រង់៖ "ខ្ញុំមិនបានធ្វើអ្វីខុសទេ។ ខ្ញុំនឹងទៅឲ្យដល់កន្លែង ដើម្បីដោះស្រាយបញ្ហា។ សួរ៖ ថាតើទីតាំងណាដែល សោ ភឹម បានធ្វើដំណើរទៅនោះ? ឆ្លើយ៖ គឺថានៅកន្លែងផែនមួយ ប៉ុន្តែគាត់<អត់ទាន់បានទៅដល់កន្លែងហ្នឹង>ទេ ហើយគាត់មិនខ្លាចទេ គាត់នឹង<>ទៅ<រហូតដល់<u>ដឹងពីមូលហេតុពិតប្រាកដ</u>> ពីព្រោះគាត់មិនបានធ្វើអ្វីខុសទេ។" ហើយនៅទំព័របន្ទាប់គេបានសួរសាក្សីថា៖ "សួរ៖ តើគាត់អត់មានបានត្រៀមខ្លួនរត់គេចខ្លួនអីទេឬ? ឆ្លើយ៖ គាត់មិនមានចេតនាគេចខ្លួនអីទេ។ បើសិនណាជាគាត់ចង់គេចខ្លួននោះ ក៏គាត់<អាច>គេចបាន<ដែរ ប៉ុន្តែ> គាត់<មិនមានបំណងចង់>រត់គេចខ្លួន<ទេ>។ <>គាត់និយាយថា គាត់មិនបានធ្វើអ្វីខុស<ទេ បើសិនមិនបានធ្វើខុស តើមានរឿងអ្វីដែលត្រូវខ្លាចនោះ>។" តើលោកនឹកឃើញទេ<>អំពី<>ឥរិយាបថរបស់ <សោ ភឹម នៅពេលដែលគាត់ទៅភ្នំពេញ ដើម្បី>មកជួប ប៉ុល ពត ពីព្រោះគាត់មិនបានធ្វើអ្វីខុសទេ?

[១១:៣០:៥០]

**ឆ៖** កាលនុំងលោកសួរនុំង កាលនុំងដំណើរតាំងពីរៀបចំទៅភ្នំពេញណោះ នៅខាង នៅកន្លែងមុននឹងមកដល់ព្រៃវែងទៀត កាលនុំងគាត់ថា គាត់នឹងមកដោះស្រាយ។ គាត់ថាអីចឹងមែន។ សូមចប់សំណួរ។

**ស៖** មុនពេល សោ ភឹម ធ្វើដំណើរមកភ្នំពេញ តើ សោ ភឹម ខ្លួនគាត់ផ្ទាល់នេះ ធ្លាប់បានចាប់

ខ្លួនកម្មាភិបាលភូមិភាគបូព៌ាខ្លួនឯង ជាកូនចៅខ្លួនឯងហ្នឹង បញ្ជូនមកមជ្ឈិមដែរឬទេ? <តើគាត់សហការក្នុងការចាប់ខ្លួននេះតាំងពីដើមដំបូងដែរឬទេ?>

**ឆ៖** បាទ ខ្ញុំ--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់ឆ្លើយតបសាក្សី!

សូមអញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ពីព្រោះការឆ្លើយជាប់ពាក់ព័ន្ធគឺ សោ ភឹម គាត់គ្រាន់តែជាមេភូមិភាគបូព៌ា ឯមជ្ឈិមវិញជាស្ថាប័នមួយផ្សេង។ សោ ភឹម ខ្លួនគាត់នេះ គឺក៏ជាសមាជិកគណៈអចិន្ត្រៃយ៍ដែរ ព្រោះមានឯកសារមួយ<របស់វៀតណាមបាន>បញ្ជាក់ថាគាត់ជាសមាជិក<ប្រធានគណៈអចិន្ត្រៃយ៍របស់រដ្ឋ>។ <ខ្លួន>គាត់<ផ្ទាល់ជាសមាជិកគណៈមជ្ឈិម> អ៊ីចឹងការញែកឲ្យដាច់ពីគ្នារវាងភូមិភាគបូព៌ា ហើយនិងមជ្ឈិមនេះ <នៅក្នុងបរិបទនេះ គឺ>វាមិន<> ត្រឹមត្រូវទេ។

[១១:៣២:៤៨]

**លោក នីកូឡាស គូមជែន៖**

<សូមអរគុណ> មិនមែនខ្ញុំឆ្លើយទម្លាក់កំហុស ឬក៏ឲ្យជាប់ពាក់ព័ន្ធបែបនេះនោះទេ។ <ខ្ញុំគិតថា ជាការចាំបាច់ដើម្បីបញ្ជាក់ថា យើងពិតជាយល់ស្របជាមួយនឹងលោកមេធាវី ហើយបើសិនជាមាននូវលក្ខខណ្ឌផ្លូវការមួយដែលយើងអាចយកបាន។ យើងរីករាយនឹងធ្វើបែបនោះ។> សោ ភឹម ខ្លួនគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ គាត់ជាមនុស្សម្នាក់សំខាន់ណាស់សម្រាប់មជ្ឈិមនាពេលនោះ។ <ចំណុចនេះយើងមិនមានការជំទាស់ទេ។> សំណួររបស់ខ្ញុំ គ្រាន់តែសួរទៅសាក្សីថាតើ សោ ភឹម មានសហការជាមួយនឹងមជ្ឈិមដើម្បីចាប់កម្មាភិបាលភូមិភាគបូព៌ា<ដែលជាផ្នែកមួយនៃគោលនយោបាយរបស់មជ្ឈិមដែរឬក៏អត់<។ ខ្ញុំពិតមិនចង់សំដៅថា> សោ ភឹម នេះ គឺគាត់<មិនបាន>ធ្វើការជាមួយ ប៉ុល ពត, នួន ជា, ខៀវ សំផន, រស់ ញឹម <ទេ>។ <ពួកគេទាំងអស់នេះធ្វើការជាមួយគ្នា។ នេះគឺជាជំហររបស់យើង។>

**ប្រធានអង្គជំនុំ៖**

បាទ ហើយសំណួរនេះគឺអាចសួរបាន ហើយអង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់របស់មេធាវីការពារក្តីលោក នួន ជា។ សាក្សីឆ្លើយតបនឹងសំណួរដែលសួរឡើងដោយសហព្រះរាជអាជ្ញាអន្តរជាតិដែលសួរលោកចុងក្រោយអម្បាញ់មិញនេះ ប្រសិនបើលោកដឹងសូមលោកឆ្លើយតប។

**លោក ស៊ិន អ៊ឹង៖**

**ស៖** បាទ ក្នុងកិច្ចការហ្នឹងខ្ញុំមិនសូវដឹងទេ។ ខ្ញុំមិនដឹង ខ្ញុំមិនហ៊ានឆ្លើយ ព្រោះមិនដឹង ឆ្លើយបំពានក៏វាខុសឧត្តមគិតខ្លួនឯង។ សូមបញ្ចប់។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** ខ្ញុំចង់ដឹងពីអ្វីដែលលោកបានឮ<ពី>កម្មាភិបាល<ផ្សេងទៀតដែលធ្វើការនៅ>ភូមិភាគបូព៌ានិយាយ នៅទីនោះគឺមានឯកសារមួយ E3/10665 ដែល<អះអាងថា ឈ្មោះ ទាត់ ធឿន>ជាកូន<ចិញ្ចឹម>របស់ រស់ ញឹម <ហើយ>គាត់និយាយអំពី រស់ ញឹម ថាគាត់<ខឹង> –ឈ្មោះ ទាត់ ធឿន នេះ<ណាស់។ នៅម៉ោង ០១:១៦:៥១វិនាទី>៖ “ខ្ញុំ<ពិតជាខឹងគាត់ខ្លាំងមែនទែន គាត់មិនគួរមានគំនិតកំសាក ដែលគួរឱ្យខ្មាសគេខ្លាំងណាស់។> បើសិនណាជាគាត់ក្រោកឈរឡើង ងើបឈរឡើងហើយជំទាស់តវ៉ា នោះគេមិនអាចសម្លាប់មនុស្សដល់រាប់លាននាក់អ៊ីចឹងទេ។ ហើយបើសិនណាជាគាត់ងើបឡើងតស៊ូ គាត់មិនអាចចាប់កូនចៅរបស់គាត់ <រួមទាំងកូនចៅរបស់ខ្ញុំ>ដែល<ខ្ញុំបានបញ្ចូល>ជាសមាជិកបក្សដែរនោះទេ។” តើលោកធ្លាប់ឮកម្មាភិបាលភូមិភាគបូព៌ានិយាយដែរឬទេថា សោ ភឹម នេះគួរណាស់តែងើបឡើងជំទាសតវ៉ា <ជាជាងការសហការដើម្បី>ចាប់ខ្លួនកម្មាភិបាលបូព៌ាតាំងពីដើមដំបូងម្ល៉េះ?

[១១:៣៥:៣១]

**លោក វ៉ិចទ័រ កូប៉េះ៖**

ខ្ញុំសូមឱ្យលោកផ្តល់លេខឯកសារច្បាស់លាស់ <ធ្វើដូច្នេះ ខ្ញុំអាចអានឯកសារហ្នឹងបាន ប៉ុន្តែ> តាមការចាំរបស់ខ្ញុំនេះ <គឺថាគាត់បាន>និយាយអំពី រស់ ញឹម ចាប់កម្មាភិបាលភូមិភាគពាយ័ព្យនោះទេ មិនមាននិយាយអំពីការចាប់ខ្លួនកម្មាភិបាលភូមិភាគបូព៌ាដោយខ្លួនទេ។

**លោក នីកូឡាស គូមជែន៖**

<ខ្ញុំមិនដឹងទេថាវាមិនច្បាស់ ប៉ុន្តែខ្ញុំពិតជាបាននិយាយយ៉ាងច្បាស់ ខ្ញុំក៏បានដាក់ពេលវេលាត្រឹមត្រូវដូចដែលមេធាវីបានធ្វើកាលពីថ្ងៃមុនអ៊ីចឹង វាមានពេលវេលាត្រឹមត្រូវ ដូច្នេះវាច្បាស់ជាងលេខទំព័រ>

ខ្ញុំបានផ្ដល់លេខ E3 <គឺ>10665 ហើយខ្ញុំបានលើកឡើង<ច្បាស់>ហើយ<ថា រស់ ញ៉ឹម នៅ>ភូមិភាគបូព៌ា។ <សូមអភ័យទោស> រស់ ញ៉ឹម នេះមកពីភូមិភាគពាយ័ព្យ<ទេ។> ហើយខ្ញុំសួរថា តើគាត់មានធ្លាប់ឮ ថាមានរឿងរ៉ាវ<ស្រដៀង>អ៊ីចឹងដែរនៅបូព៌ា<ទេ>?

**លោក វ៉ិចទ័រ កូប៉េ៖**

គឺថាលោកបានលើកឡើងពីឯកសារយោង <និងពេលវេលា>ជាច្រើនមកហើយ <យើងពិតជាត្រូវការ>លេខឯកសារយោង<ជាងការបញ្ជាក់ពេលវេលា> ពីព្រោះ<ខ្ញុំជឿថា> តាមដែលលោកនិយាយមក ហាក់បីដូចជាការយោងទៅលើខ្សែអាត់<ចំនួនប្រាំមួយ ហើយម្ដងៗមានការបញ្ជាក់ពេលវេលាខុសៗគ្នា>។ អ៊ីចឹងសូមផ្ដល់លេខយោងផង។

[១១:៣៦:៤៨]

**លោក នីកូឡាស គូមជែន៖**

គឺ លឹមគិន បានសម្ភាសសាក្សីរូបនេះចំនួនពីរដង មានខ្សែអាត់ជាសំឡេងនោះផងដែរ ពីរលើក ERN ជាអង់គ្លេស 01156815។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** លោកសាក្សី តើលោកធ្លាប់ដែលឮកម្មាភិបាលភូមិភាគបូព៌ា និយាយថា សោ ភឹម នេះគឺថាមានការសហការចំពោះការចាប់ខ្លួន តាំងពីលើកដំបូងមកម្ល៉េះ។ ធ្លាប់ដែលឮនិយាយអ៊ីចឹងទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំអត់បានធ្លាប់ឮទេ។ មិនដឹងទេ កិច្ចការហ្នឹង។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោកសហព្រះរាជអាជ្ញាអន្តរជាតិ។ ឥឡូវនេះដល់ពេលសម្រាកថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងមួយកន្លះរសៀល សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលផ្ដល់កន្លែងសម្រាកនៅបន្ទប់រង់ចាំសម្រាប់សាក្សី ដល់សាក្សីរូបនេះ នៅក្នុងអំឡុងពេលសម្រាកថ្ងៃត្រង់ និងឲ្យអញ្ជើញគាត់ រួមទាំងមេធាវីប្រឹក្សាសាក្សីមកកាន់កន្លែងផ្ដល់សក្ខីកម្មក្នុងបន្ទប់សវនាការនេះវិញ នៅវេលាម៉ោងមួយកន្លះ។

ហើយនិងបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនលោក ខៀវ សំផន ត្រឡប់ទៅកាន់បន្ទប់រង់ចាំ

ខាងក្រោមសាលសវនាការនេះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅក្នុងបន្ទប់សវនាការនេះវិញ នៅរសៀលនេះ ឲ្យបានមុនម៉ោងមួយកន្លះ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១១:៣៨ នាទី ដល់ម៉ោង ១៣:៣២ នាទី)*

[១៣:៣២:០៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនការ និងផ្តល់វេទិកាជូនទៅសហព្រះរាជអាជ្ញាអន្តរជាតិ ដើម្បីបន្តការតាំងសំណួរដេញដោលចំពោះសាក្សី។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរពីរបីបន្ថែមទៀត។ ថាតើនៅពេលដែលលោកធ្វើការជាមួយ សោ ភឹម ហ្នឹងនៅភូមិភាគបូព៌ា តើលោកមានបាន<ឃើញ>ទីប្រឹក្សា ឬក៏ជំនួយការពីប្រទេសចិន<>ទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ មិនដែលទេ។

**ស៖** តើលោកធ្លាប់ឃើញភ្ញៀវបរទេសមកពីប្រទេសចិនដែរឬទេ?

**ឆ៖** បាទ ភ្ញៀវបរទេស ខ្ញុំ ពេលដែលខ្ញុំទៅហ្នឹង អត់ដែល អត់ដែលឃើញទេ។

**ស៖** ខ្ញុំនឹងសួរលោកនៅពេលក្រោយបន្តិចទាក់ទងចំណុចនេះ។ នៅក្នុងពេលដែលលោកនិយាយអំពីការចាប់កម្មាភិបាលបូព៌ានោះ តើមានការចាប់ខ្លួនសមាជិកក្រុមគ្រួសារលោកផ្ទាល់ដែរឬទេ?

**ឆ៖** បាទ ក្រុមគ្រួសារខ្ញុំ គ្មានចាប់ទេ ព្រោះខ្ញុំក្រុមគ្រួសារខ្ញុំមានអ្នកណាធ្វើការផង។

**ស៖** ចុះសាច់ញាតិរបស់ សោ ភឹម វិញ តើសាច់ញាតិរបស់ សោ ភឹម មានអ្នកណាម្នាក់ត្រូវគេចាប់ខ្លួនដែរឬទេ?

**ឆ៖** បាទ សាច់ញាតិ សោ ភឹម គេចាប់បាត់ទាំងអស់ ស្លាប់ទាំងអស់។

[១៣:៣៤:៤៩]

**ស៖** លោកនិយាយអំពីកូនពៅរបស់ សោ ភឹម ដែរ <ឈ្មោះថា ណាត> អ៊ីចឹងមែនទេ?

**ឆ៖** បាទ កូនពៅ ធ្លាប់នៅ ខ្ញុំធ្លាប់ជួបនៅហ្នឹងគ្នានៅតូចដែរ។

**ស៖** តើនៅឆ្នាំ៧៧ គាត់មានអាយុប៉ុន្មានឆ្នាំដែរ គឺកូនពៅនោះ?

**ឆ៖** បាទ ប្រហែលជាអាយុ តាមខ្ញុំស្មានមើលប្រហែលជាអាយុ៩ ឬ១០ឆ្នាំប៉ុណ្ណឹង។

**ស៖** តើ ណាត ដែលជាកូនពៅរបស់ សោ ភឹម ហ្នឹងនៅក្នុងគណៈពេទ្យដែរឬទេ?

**ឆ៖** បាទ អត់ទេ។ កូនពៅហ្នឹងគឺនៅរៀននៅសាលាយើងនៅក្នុងកសិដ្ឋានហ្នឹង ជាកុមារដទៃៗទៀត។

**ស៖** ប្រហែលជាលោកអាចជួយយើងបាន ព្រោះមានឯកសារមួយដែលយើងទទួលបានពី ស-២១ គឺខ្ញុំនិយាយយោងទៅលើបញ្ជី ក.ស.ច.ស គឺ E3/10604 គឺនៅលេខ១១.៦៧៦ គឺមានមនុស្សម្នាក់ឈ្មោះ <ប៉ាង> ញ៉ ហៅ ណាត ដែលគេបង្ហាញថាជាសមាជិកគណៈពេទ្យ<នៅភូមិភាគបូព៌ា> ហើយត្រូវជាកូន<ប្រុស>របស់ ភឹម ចូលនៅ ស-២១ <នៅថ្ងៃទី១០> ខែកក្កដា ឆ្នាំ៧៨។ តើលោកស្គាល់ឈ្មោះ <ប៉ាង> ញ៉ នៅគណៈពេទ្យនៃភូមិភាគបូព៌ាដែរឬទេ?

**ឆ៖** ខ្ញុំមិន -- បាទ ខ្ញុំមិនបានស្គាល់ពីត្រកូលពីអីទេ ប៉ុន្តែគ្រាន់តែធ្លាប់បានជួបឈ្មោះ ណាត មួយ ហ្នឹងជាប្រធានពេទ្យភូមិភាគបូព៌ាមែន ឈ្មោះ ណាត ហ្នឹង រត់ទៅជាមួយ ទៅជាប់គុកនៅស្វាយរៀងជាមួយខ្ញុំដែរ។ បាទ ខ្ញុំធ្លាប់ គ្រាន់តែធ្លាប់នេះ ធ្លាប់ឃើញ ដែលជាប់គុកនុ៎ង។ ហើយដល់ក្រោយមក ពេលគេបញ្ជូន ពេលគេរើបែកគុកនោះទៅ ដល់គេបញ្ជូនទៅបែកបាក់គ្នាទៅ បាត់ខ្លួនរហូតមក។

[១៣:៣៨:១៦]

**ស៖** នៅពេលដែលលោកនិយាយពីការដែលលោកជាប់គុកហ្នឹង តើ<រយៈពេលយូរប៉ុន្មាន> ក្រោយពេលដែលលោកធ្វើដំណើរជាមួយ សោ ភឹម ហ្នឹង? តើក្រោយនុ៎ងប៉ុន្មានអាទិត្យ ឬក៏ប៉ុន្មានខែដែរបានទើបលោកជាប់គុក?

**ឆ៖** ខ្ញុំ បាទខ្ញុំវិលពីកន្លែង ពីរត់ពីនេះទៅ ខ្ញុំមិនចំណាំបានដឹងប៉ុន្មានថ្ងៃ ប៉ុន្មានខែទេ ប្រហែលរយៈប្រហែលជាមួយខែអីយ៉ាង ទម្រាំខ្ញុំរត់មកដល់ស្រុកវិញ បានគេចាប់ខ្ញុំដាក់គុក។ វាចំណាំអត់បាន។

**ស៖** នៅពេលដែលលោកជាប់គុកហ្នឹង តើវានៅក្នុងខែតែមួយក្នុងពេលដែលលោកទៅភ្នំពេញជាមួយ សោ ភឹម ឬក៏នៅក្នុងរយៈពេលត្រឹមតែប៉ុន្មានថ្ងៃ ឬក៏អាចថាដល់សប្ដាហ៍ដែរឬទេ?

01391960



**ឆ៖** បាទ ប្រហែលជាយូរដែរ ព្រោះតាមខ្ញុំវានៅភ្លេចភ្លាំងខ្លះ ព្រោះខ្ញុំថា ប្រហែលជាខ្ញុំមួយទៅភ្នំពេញ ហើយខ្ញុំហ្នឹងមកហ្នឹង វាជាប់ ទម្រាំនឹងមក ខ្ញុំរត់មកនៅរកាឃ្មួចក្បែរស្នួងហ្នឹងវាជាប់១០ថ្ងៃជាង ហើយទម្រាំខ្ញុំធ្វើដំណើរដើរតាមនុំង វារយៈពេលជាងមួយអាទិត្យហើយ បានទម្រាំដល់ស្រុក។ គិតទៅវាយូរដែរ ប្រហែលជាជាប់ជិត១ខែដែរ បានមកដល់ស្រុក បានខ្ញុំជាប់គុក។

**ស៖** សូមអរគុណ។ ហើយបន្ទាប់មកទៀត លោកជាប់គុកនៅទីនោះរាប់ខែ អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំជាប់ប្រហែលជា១ខែ ឬ១ខែជាងទេ បានគេវាយចូលកន្លែងគុកហ្នឹង ខាងកងទ័ពវៀតណាមវាយចូលទៅហ្នឹង ខ្ញុំក៏រត់ខ្លួន រួចខ្លួនពេលនុំងទៅ។

[១៣:៤០:៤៨]

**ស៖** តើគុកដែលលោកជាប់ហ្នឹងនៅម្តុំណាដែរ?

**ឆ៖** បាទ នៅវត្ត គេហៅវត្តក្តីរំដួល ក្បែរមាត់ទន្លេស្វាយរៀងដែរ ខាងជើងក្រុងស្វាយរៀង។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ដែរ ដែលជាប់គុកជាមួយលោកនៅទីនោះ?

**ឆ៖** បាទ ខ្ញុំមិនរាប់ចំនួនមិនអស់ទេ គ្រាន់តែប្រហែលជា ជាប់នុំងប្រហែលជា២០០ជាងយ៉ាងកន្លែងគុកនោះ។

**ស៖** នៅពេលដែលគេចាប់ខ្លួនលោកហ្នឹង តើលោកលាក់អត្តសញ្ញាណរបស់ខ្លួន ឬមួយក៏លោកប្រាប់គេ ថាលោកជាអង្គរក្ស ឬក៏ជាអ្នកការពាររបស់ សោ ភឹម?

**ឆ៖** បាទ ពេលនោះខ្ញុំលាក់ ខ្ញុំថាខ្ញុំនៅកន្លែងកសិដ្ឋាន កន្លែងចម្ការអីហ្នឹង ខ្ញុំលាក់ខ្លួនដែរ តែនឹកខ្ញុំស្មានថា បើរយៈពេលយូរបន្តិច ក៏មិនរួចខ្លួនដែរ បើនៅតែស្លាប់ទាំងអស់ហ្នឹង អ្នកជាប់គុកនោះ។ សូមចប់យោបល់។

**ស៖** តើលោកមានដឹងថា មានអ្នកទោសណានៅទីនោះ ត្រូវបានគេសម្លាប់ដែរឬទេ?

**ឆ៖** បាទ មួយពេលនុំងគឺខ្ញុំអត់បានដឹងទេ ព្រោះគេវាយចំកន្លែងគុកហ្នឹង--

**ប្រធានអង្គជំនុំ៖**

កុំអាលទាន់! កុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកស្រីមេធាវី អង់តា ហ្គិសសេ!

[១៣:៤២:៥៦]

**កញ្ញា អង់តា ហ្គិសសេ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំអន្តរាគមន៍នៅក្នុងដំណាក់កាលនេះ ដើម្បីជំទាស់ទៅនឹងសំណួរទី១ របស់សហព្រះរាជអាជ្ញា ដែលពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់សាក្សី ហើយសហព្រះរាជាអាជ្ញាគាត់បានសួរសំណួរពាក់ព័ន្ធនឹងវត្តមួយ ជាគុកដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿងទេ។ ដូច្នេះខ្ញុំសូមជំទាស់ទៅលើការសួរត្រង់ចំណុចនេះ លោកប្រធាន។

**លោក នីកូឡាស គូមជែន៖**

លោក លោកស្រីចៅក្រម សាក្សីនេះត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម ទាក់ទងទៅនឹងការបោសសម្អាត គឺការបោសសម្អាតនៅភូមិភាគបូព៌ា។ ហើយខ្ញុំនឹងសួរគាត់អំពីមនុស្សដែលជាប់គុកហ្នឹង ហើយនិងថាតើមានអ្វីកើតឡើងចំពោះអ្នកទោសទាំងអស់នោះ។ សាក្សីត្រូវបានកោះហៅ ដោយសារតែសំណើរបស់មេធាវីការពារក្តី។ ដូច្នេះខ្ញុំគិតថា សំណួររបស់ខ្ញុំទាក់ទងនឹងការបោសសម្អាតហ្នឹង គឺវាមានភាពពាក់ព័ន្ធ។

**កញ្ញា អង់តា ហ្គីសសេ៖**

<ខ្ញុំហាក់ដូចជាមិនគិតថា> សាក្សី<ត្រូវបាន>ហៅមកនិយាយអំពីការបោសសម្អាតដែលមិនស្ថិតនៅក្នុងវិសាលភាពនៃសំណុំរឿង <គឺយើងមានដីការសម្រេចបំបែកនីតិវិធី>។ <>អ៊ីចឹងមេធាវីការពារក្តី នួន ជា ចង់កោះហៅគាត់មក ដើម្បីមកនិយាយអំពីបញ្ហាជម្លោះប្រដាប់អាវុធ និងបញ្ហាផ្ទៃក្នុងដែលអាចកើតមាននៅក្នុងភូមិភាគបូព៌ា ជាពិសេសបញ្ហារួមគំនិតក្បត់។ អ៊ីចឹងហើយបានគេដាក់ឈ្មោះគាត់នៅក្នុងបញ្ជីសាក្សីនោះ។ ហើយឥឡូវសហព្រះរាជអាជ្ញាមកនិយាយថា យើង<មិន>អាចនិយាយ<អំពី>ការបោសសម្អាត ដែលមិនស្ថិតនៅក្នុងដីកាសម្រេចបំបែកនីតិវិធី<វិញ>។ អ៊ីចឹងការ<ធ្វើបែបនេះគឺ>ជាការបំប្លែង<>ខ្លឹមសារ <និង>ភស្តុតាងនៅចំពោះមុខអង្គជំនុំជម្រះ។ ដូច្នេះខ្ញុំសូម<ជំទាស់និង>សង្កត់ធ្ងន់ម្តងទៀតថា អ្វីៗដែលគាត់សួរនេះ គឺមិនស្ថិតនៅក្នុងក្របខ័ណ្ឌនៃ<ភស្តុតាងដែលបានប្រមូលទុកនៅក្នុង>ដីកា<សម្រេច>បំបែកនីតិវិធី<>នោះទេ<>។ <ដូច្នេះ វាអាស្រ័យទៅលើអង្គជំនុំជម្រះក្នុងការសម្រេច។>

[១៣:៤៥:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ដោយសារមានការពាក់ព័ន្ធនឹងន័យនៃការបោសសម្អាតភូមិភាគបូព៌ា ដែលជាអង្គហេតុដែលចោទប្រកាន់ដែលត្រូវពិភាក្សា ត្រូវធ្វើដាក់ជាអង្គហេតុនៅក្នុង០០២/០២។ ដូច្នេះសំណួរនេះអាច

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ស្តួរបាន ពីព្រោះវាជាបច្ច័យ ជាទំនាក់ទំនងដែលពាក់ព័ន្ធជាមួយនឹងរឿងអង្គហេតុបោសសម្អាត។ ដូច្នេះ អង្គជំនុំជម្រះបដិសេធនូវសេចក្តីជំទាស់នេះ។ ហើយសាក្សី សូមឆ្លើយតបនឹងសំណួរដែលសួរឡើង ដោយសហព្រះរាជអាជ្ញាអន្តរជាតិដែលបានសួរលោកចុងក្រោយអម្បាញ់មិញនេះ បើលោកចងចាំ។ បើ លោកមិនចាំទេ សូមឱ្យលោក គាត់សួរលោកសាជាថ្មីម្តងទៀត។

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ សូមលោកបន្ថែមសំណួរទៀត ខ្ញុំមិនបានចាំអំមិញ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** បាទ មិនអីទេ។ ខ្ញុំចង់សួរថាតើលោកបានឃើញមានមនុស្សណានៅក្នុងគុកត្រូវបានគេ សម្លាប់ ឬក៏លោកជឿជាក់ថា ពួកគាត់ត្រូវបានគេសម្លាប់ ឬក៏បាត់ខ្លួនដែរឬទេ?

[១៣:៤៦:២២]

**ឆ៖** បាទ មួយពេលនុ៎ងខ្ញុំអត់មានបានឃើញទេ គ្រាន់ថាមួយពេលដែលគេផ្តោងដាក់ចំកន្លែង គុកមួយយប់ចង់ទល់ភ្លឺហ្នឹង ព្រលឹមឡើងមនុស្សរត់បាត់ទាំងអស់គ្នាតែម្តង។ មានឃើញអ្នកណាស្លាប់ មួយទេ។ សូមចប់សំណួរ។

**ស៖** មនុស្សដែលនៅក្នុងគុកជាមួយលោកហ្នឹង ថាតើពួកគាត់អះអាងថាពួកគាត់ជាកម្មករធម្មតា ឬមួយក៏ថាពួកគាត់ជា<យោធាកងពលភូមិភាគបូព៌ា ឬ>ស្រុក ឬក៏មកពីថ្នាក់តំបន់នៅភូមិភាគបូព៌ា ដែរ?

**ឆ៖** បាទ អ្នកដែលទៅកន្លែងជាប់រៀនសូត្រជាមួយខ្ញុំហ្នឹង គឺសុទ្ធតែអ្នកនៅ ខ្លះនៅក្រសួង យោធា ខ្លះនៅខាងមន្ទីរ ក្រសួងគ្រប់កន្លែង កន្លែងកសិដ្ឋាននៅឈរនៅកន្លែង ខ្លះនៅភូមិភាគ ខ្លះនៅតំបន់ ដល់វិលមកស្រុកកំណើតវិញទៅ គេប្រមូលទាំងអស់។ សូមចប់។

**ស៖** នៅពេលដែល -- គឺថាមុនពេល <ឬក្រោយមក នៅពេលដែល>លោកជាប់គុក ថាតើ លោកបានឃើញការសម្លាប់កម្មាភិបាលភូមិភាគបូព៌ា ឬក៏យោធាភូមិភាគបូព៌ាដោយពួកខាង<មជ្ឈិម> ឬក៏ពួកនិរតីអីដែរឬទេ?

**ឆ៖** បាទ ពេលដែលខ្ញុំ មុនខ្ញុំជាប់គុកហ្នឹង គេសម្លាប់ គេមិនដែលឲ្យយើងឃើញទេ វាគ្រាន់ថា បើបាត់ខ្លួនទៅ បាត់តែម្តង គេថាទៅរៀនៗបាត់តែម្តង បើថាសម្លាប់ឲ្យឃើញផ្ទាល់ភ្នែក មិនដែលឃើញ ទេ។ សូមបញ្ចប់។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ស៖** ខ្ញុំជឿថា <លោកបាននិយាយថា> នៅក្នុងផ្នែកការពារហ្នឹង គឺមានមនុស្ស៦០នាក់ <រាប់បញ្ចូលទាំងអ្នកមកជួយការងារផ្សេងៗទៀត> តើលោកដឹងថាពួកគាត់ប៉ុន្មាននាក់ដែលនៅរស់រានមានជីវិតក្រោយឆ្នាំ៧៨នោះដែរទេ?

[១៣:៤៩:០៧]

**ឆ៖** បាទ ក្នុងចំនួន៦០នាក់ហ្នឹង តាមខ្ញុំបានជួបហ្នឹង ជួបនៅតែក្មេងៗតូចៗនោះ ប្រហែលបួនប្រាំនាក់ដែរ ជួបនៅរស់ហ្នឹង។ ហើយក្រៅពីហ្នឹង រត់បែកខ្ញុំ ខ្លះគេទៅ រត់ទៅយៀកណាម ខ្លះគេទៅឯណាឯណីបាត់អស់ទៅ ពេលហ្នឹង។ នៅរស់ ឃើញនៅរស់ នៅវិលមកស្រុក អ្នកនៅក្មេងៗឥឡូវធំ ចាស់ដែរហើយឥឡូវ នៅពីរបីនាក់ដែរ។ សូមបញ្ចប់។

**ស៖** តើលោកធ្លាប់ឃើញ ឬក៏ធ្លាប់ជួបនូវទីវាលពិឃាដ គឺកន្លែង<ដាក់សាកសពយោធា ឬកម្មាភិបាលភូមិភាគបូព៌ា បន្ទាប់ពីគេបានសម្លាប់ហើយ>ដែរឬទេ នៅពេលនៅក្នុងសម័យនោះ?

**ឆ៖** បាទ មិនដែលឃើញកន្លែងនោះទេ ខ្ញុំមិនបានទៅដល់ជួបកន្លែងដែលពិឃាដនោះផង។

**ស៖** តើលោកដឹងទេ ថាមានអ្វីកើតឡើងចំពោះប្រពន្ធ សោ ភឹម <ហៅ យាយការ៉ូ ដែរឬទេ>?

**ឆ៖** ចំពោះប្រពន្ធ សោ ភឹម ខ្ញុំអត់បានដឹងផង ព្រោះគាត់នៅកន្លែងផ្សេង ពេលខ្ញុំនៅកន្លែងផ្សេង ខ្ញុំអត់ដឹងផង។

**ស៖** មុនពេលដែល សោ ភឹម ធ្វើដំណើរទៅភ្នំពេញ ហើយគាត់សម្លាប់ខ្លួន គឺថាមុនពេលហ្នឹង តើលោកធ្លាប់ឃើញគេចាប់ខ្លួនមនុស្ស ហើយយកទៅភ្នំពេញទេ?

**ឆ៖** បាទ ខ្ញុំ មុននឹងខ្ញុំមិនដែលឃើញផង គេចាប់មិនដឹងជា ដល់មិនដែលឃើញអ៊ីចឹង មិនដឹងមិនហ៊ាននិយាយ ព្រោះមិនឃើញ មិនដែលឃើញមែន។

**ស៖** តើលោកធ្លាប់ឃើញសន្តិសុខមកពី<មជ្ឈិម>មកភូមិភាគបូព៌ាដើម្បីចាប់មនុស្សដែរឬទេ?

**ប្រធានអង្គជំនុំ៖**

មកពីកណ្តាលអីគេកណ្តាលហ្នឹង? មកពីភូមិភាគកណ្តាល ឬក៏មកពីកណ្តាល? កណ្តាល អត់យល់ទេ ខ្មែរហ្នឹង វាមិនយល់ទេ។

[១៣:៥២:១៦]

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អរគុណ។ តើលោកធ្លាប់ឃើញមនុស្សមកពីភ្នំពេញ មកដឹកជញ្ជូនកម្មាភិបាលយកទៅ

ភ្នំពេញទេ គឺបានន័យថាមកចាប់ខ្លួនយកទៅភ្នំពេញទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ខ្ញុំមិនដែលបានឃើញផ្ទាល់ភ្នែកទេ ពីព្រោះបើសិនណាជាគេមកចាប់ ក៏មិនមែនទាល់តែមកចាប់កន្លែងខ្ញុំតែម្តង បានខ្ញុំឃើញមាន។ បើថាខ្ញុំ បើខ្ញុំនៅកន្លែងនៅតែកន្លែង ពីព្រោះមិនបានសម័យនោះមិនមែនបានដើររហេតរហូតទេ។ បើថានៅកន្លែងណាកន្លែងហ្នឹង បើថាធ្វើការទៅណាមកណា ទាល់តែមានការបញ្ជា ឬក៏មានផែនការអីទៅបានទៅ។ បើថាឲ្យដើរឃើញ ដើរនេះទៅ អត់មានដើរបានទេជំនាន់ហ្នឹង។ សូមបញ្ចប់យោបល់។

**ស៖** តើលោកធ្លាប់ឃើញគេចាប់ខ្លួនជនជាតិវៀតណាម ហើយត្រូវបានកងទ័ពខ្មែរឃុំខ្លួនដែរឬទេ <មិនថាកម្លាំងភូមិភាគបូព៌ា ឬក៏កម្លាំងផ្សេងទៀតទេ> ដូច្នេះខ្ញុំចង់សួរថាតើលោកធ្លាប់ឃើញគេចាប់ខ្លួនកងទ័ព ឬក៏ជនស៊ីវិលវៀតណាមទេ?

**ឆ៖** បាទ មិនដែលឃើញទេ ព្រោះប្រទេសដោយឡែកដោយគ្នា មករឹតតែលែងឃើញហើយ។ សូមបញ្ចប់សំណួរ។

[១៣:៥៤:០០]

**ស៖** តើលោកធ្លាប់ឃើញវីដេអូ ដែលគេនិយាយអំពីចម្លើយសារភាពរបស់ជនជាតិវៀតណាម ដែលត្រូវគេចាប់ខ្លួនទេ?

**ឆ៖** បាទ មិនដែលឃើញទេ ជំនាន់នោះគ្មានវីដេអូ គ្មានស្អីផង តែវិទ្យុគ្មានស្តាប់ផង។ មិនដែលឃើញផង។ សូមបញ្ចប់។

**ស៖** ខ្ញុំចង់សួរលោកបន្ថែមទៀត ទាក់ទងទៅនឹងការដែល នួន ជា ចុះទៅភូមិភាគបូព៌ា។ ថាតើត្រឹមត្រូវទេ ដែលគាត់ស្នាក់នៅក្នុងមន្ទីរការពារនៅស្វូងនោះ តើត្រឹមត្រូវទេ?

**ឆ៖** បាទ សំណួរនេះខ្ញុំដូច គាត់យល់ន័យថា ត្រឹមត្រូវ មិនត្រឹមត្រូវម៉េច ខ្ញុំអត់យល់ន័យហ្នឹងផង។ មិនដឹងឆ្លើយថាម៉េច បើគាត់ថាចុះទៅហើយ មិនត្រឹមត្រូវ ត្រឹមត្រូវ ខ្ញុំមិនដឹងថាន័យ គាត់សំណួរសួរសំដៅលើអីផង។

**ប្រធានអង្គជំនុំ៖**

នួន ជា ដែលពេលទៅ ៗធ្វើការនៅភូមិភាគបូព៌ាហ្នឹង តើគាត់ទៅស្នាក់នៅមន្ទីរកងការពារនោះដែរឬទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ បើថាគាត់ស្នាក់នៅ គាត់មានទៅ មានទៅស្នាក់នៅនុ៎ងដែរ។

**សួរដោយលោក នីកូឡាស គូមជែន៖**

**ស៖** អ៊ីចឹងមានន័យថា នួន ជា ធ្លាប់ទៅសម្រាកនៅមន្ទីរការពាររបស់ សោ ភឹម តើអ៊ីចឹងមែនទេ? គឺបានន័យថា គាត់ទៅនៅកន្លែងអង្គរក្សរបស់ សោ ភឹម។ តើអ៊ីចឹងមែនទេ?

**ឆ៖** បាទៗ។

[១៣:៥៦:១១]

**ស៖** តើលោកចាំទេថា នួន ជា គាត់មានធ្លាប់ឡើងថ្លែងសុន្ទរកថាអ្វីដែរឬទេ នៅពេលនោះ?

**ឆ៖** បាទ មិនដែលឃើញផង មិនដែលឃើញឡើងថ្លែងអីទេ។

**ស៖** លោកសាក្សី នៅក្នុងការសម្ភាសកាលពីឆ្នាំមុនរបស់លោក ខ្ញុំដូចជាមិនយល់អ្វីដែលលោកឆ្លើយ ដូច្នេះខ្ញុំនឹងអានឲ្យលោកស្ដាប់ ហើយសូមឲ្យលោកបកស្រាយ។ គឺលោកនិយាយអំពីពេលវេលាមួយ ដែលលោកធ្វើដំណើរទៅភ្នំពេញជាមួយ សោ ភឹម គឺអង់គ្លេសមានលេខ <01353391>*(ស៊ីក),* ខ្មែរមានលេខ 01340587 និងបារាំងមានលេខ 01345525។ គេសួរលោកអំពីការធ្វើដំណើរ ដែលថាពេលធ្វើដំណើរហ្នឹងយកកាំភ្លើងតាមខ្លួន ហើយនិងការស្លៀកពាក់របស់ សោ ភឹម។ លោកក៏និយាយអំពីមនុស្សម្នាក់ឈ្មោះថា ភី គឺលោកនិយាយថា៖ "គាត់ពាក់ខោ<ចង្កេះកៅស៊ូពណ៌>ខ្មៅ ហើយមានស្ពាយកាំភ្លើងនៅខ្នង ហើយពេលយប់ ខ្ញុំយកកាំភ្លើងនោះទុក ហើយគាត់ទារយកកាំភ្លើងនុ៎ង ប៉ុន្តែខ្ញុំមិនឲ្យគាត់វិញ។ ហើយ<>គាត់សួរថា តើយកកាំភ្លើងហ្នឹងទៅណា ឲ្យខ្ញុំមក ប៉ុន្តែខ្ញុំមិនឲ្យ។ ខ្ញុំនឹកឃើញថាគាត់ហត់។ ចុះដើរទៅបន្តិច គេចាប់<គាត់>នៅមុខ<យើង>ហ្នឹង។ <គាត់ត្រូវគេចងបិទភ្នែក ហើយគេវ៉ៃ ហើយ> គេចាប់<គាត់>យប់ហ្នឹង។ <>បន្ទាប់<មក> គេបាញ់<សម្លាប់គាត់។> ខ្ញុំទៅឃាត់<ពួកវាដែរ ប៉ុន្តែ>តាហ្នឹង<ស្រែក>ថា ឥឡូវចេញពីផ្ទះហ្នឹង<ភ្លាម>។" ដូច្នេះមើលទៅតាមអ្វីដែលខ្ញុំអានហ្នឹង គឺថាខ្ញុំស្ដាប់ទៅដូចជាច្របូកច្របល់ណាស់។ តើវាធ្វើឲ្យលោកនឹកឃើញអ្វីដែលលោកឆ្លើយដូចដែលខ្ញុំអានឲ្យលោកស្ដាប់ហ្នឹងទេ?

[១៣:៥៨:១២]

**ឆ៖** បាទ មកពីអ្នកសរសេរនុ៎ងមិនច្បាស់លាស់។ ខ្ញុំឆ្លើយតាមលំដាប់លំដោយដែរ តែដល់លោកសរសេរ ហើយលោកបកចុះបកឡើងយកចំណុចហ្នឹង ខ្ញុំក៏វាក់ដែរ ពេលដែលថាកន្លែងដែលគេ

បាញ់ប្រតប់ប្រតាយនុ៎ង។ ពេលដែលគាត់ ដែលគេបាញ់ហ្នឹង ខ្ញុំក៏ថយមកក្រោយ ខ្ញុំនិយាយឲ្យច្បាស់លាស់ ថយមកខាងក្រោយ ពីកន្លែងគេចាប់ប្រតប់ប្រតាយ ថយមកក្រោយវិញ មករកកន្លែងផ្ទះដេកហ្នឹងវិញ។ ផ្ទះបាញ់វាមានពីរសាបីសា នៅក្នុងមួយយប់នុ៎ង។ ដល់ពេលថយមកវិញហ្នឹង គាត់ឈ្មោះ ភី ដែលខ្ញុំ គាត់សំណួរអំមិញថា និយាយ ភី ហ្នឹងគឺក្មេងកុមារមួយដែលចុះតាមជាមួយខ្ញុំហ្នឹង ជាសម្រាប់ហុចយួរកន្ត្រកឲ្យគាត់ យួរទឹក កាន់កែវទឹក កែវអី។ វា ភី ហ្នឹងមែន។ សូមចប់សំណួរ។

**សៈ** អ៊ីចឹងមានន័យថា សោ ភឹម ឲ្យលោកកាន់កាំភ្លើងរបស់គាត់។ តើអ៊ីចឹងមែនទេ?

**ឆៈ** បាទ ពេលដែលភ័យប្រតប់ប្រតាយកាំភ្លើងគាត់មិនដែលសូវកាន់នឹងខ្លួនទេ គាត់នៅ ភី នុ៎ង កាន់នៅក្នុងកន្ត្រក ភី នុ៎ង។ ហើយដល់ពេលនេះទៅ ខ្ញុំក៏ជួយយួរកន្ត្រកអី វាហ្នឹងរត់ថយមកក្រោយវិញ។ កាំភ្លើងអាហ្នឹង វាអ៊ីចឹងទេ។

**សៈ** នៅក្នុងផ្នែកដែលខ្ញុំអានដែលថាគេចាប់នៅមុខហ្នឹង <ដូច្នេះ>តើអ្នកដែលគេចាប់ចងមុខហ្នឹង <គឺ>ជា សោ ភឹម ឬក៏អ្នកណា?

[១៤:០១:២៩]

**ឆៈ** បាទ អ្នកដែលគេចាប់ហ្នឹងគឺ អ្នកដែលចេញពីភ្នំពេញមក ហើយមកជាក្រសួងមន្ទីរដែរ តែខ្ញុំមិនសូវស្គាល់គេ។ គេមកជួយការពារនៅជាមួយគ្នា ពេលយប់ហ្នឹង។ ដល់ពេលបណ្ដើរគ្នាចេញពីផ្ទះហ្នឹងទៅថា ការជួយការពារទៅដល់ខាងមុខហ្នឹង គេចាប់អ្នកហ្នឹងនៅខាងមុខហ្នឹង។ តែមិនស្គាល់ឈ្មោះគេទេ ព្រោះក្រសួងនៅដោយឡែកដោយគ្នា គ្រាន់ភូមិភាគបូព៌ាដែរ។ សូមចប់យោបល់ប៉ុណ្ណេះ។

**សៈ** អ៊ីចឹងអ្នក<>បូព៌ាម្នាក់<ផ្សេងទៀត ប៉ុន្តែគាត់មកពីភ្នំពេញ> ដែលឈរយាមកាមជាមួយលោកហ្នឹង ក៏ត្រូវបានគេចាប់ខ្លួន ហើយបាញ់សម្លាប់ចោលទៅ។ អ៊ីចឹងមែនទេ?

**ឆៈ** មួយពេលនុ៎ង ចាប់ហ្នឹង ពេលដែលយប់ ប៉ុន្តែបាញ់ មិនដឹងអាអ្នកចាប់នុ៎ងបាញ់មិនដឹង ក៏បាញ់ត្រូវគ្រាប់គ្នាឯងហ្នឹងក៏មិនដឹង ព្រោះពេលនុ៎ងដោះរួចខ្លួនម្នាក់ ម្ខាងៗ ពេលគេស្រែកសន្ទាប់ឲ្យលើកដៃលើកអីទៅ ក៏បាញ់ឈ្មុលទាំងអស់គ្នាទៅ ទាំងសងខាង ប៉ុន្តែមិនដឹងត្រូវគ្រាប់ខាងណា។

**សៈ** តើរឿងរ៉ាវនេះ កើតឡើងនៅអរិយក្សត្រឬ?

**ឆៈ** បាទ នៅអរិយក្សត្រ។

**សៈ** បាទ អរិយក្សត្រ អរគុណច្រើន។ ខ្ញុំសុំសួរលោកមួយសំណួរពាក់ព័ន្ធទៅនឹងសក្ខីកម្មរបស់សាក្សីម្នាក់ដែលបានជម្រាបជូនតុលាការគឺ សក្ខីកម្មរបស់ មាស <សឿន> E3/5531 ត្រង់ចម្លើយ

លេខ៦២។ <ដំបូង> តើលោកស្គាល់ មាស <សឿន> ទេ លោកសាក្សី?

**ឆ៖** បាទ ខ្ញុំអត់ស្គាល់ទេ។

**ស៖** គាត់បាននិយាយថា គាត់ទទួលលិខិតពី សោ ភឹម នៅថ្ងៃទី២៥ ឧសភា ១៩៧៨។ ហើយតាមរយៈ<អតីត>អ្នកបើកបរឡានឲ្យ សោ ភឹម <ឈ្មោះ សម។> លិខិតនេះសរសេរថា "ទៅសមមិត្ត ស <និង សឿន រោងជាងក្រឡឹង> សុំត្រៀម<កម្លាំងដើម្បីការពារកុំឲ្យគេចាប់កម្លាំងរបស់យើង> ពីព្រោះ<តាមការប៉ាន់ស្មានរបស់យើង នឹង>មានរដ្ឋប្រហារដែលដឹកនាំដោយ សុន សេន ដើម្បីទម្លាក់លេខា និងអនុលេខាបក្សហើយ។" តើលោកធ្លាប់ឮសួរ សោ ភឹម និយាយាថា ការចាប់ខ្លួនទាំងនេះ គឺជារដ្ឋប្រហារដឹកនាំដោយ សុន សេន ហើយ គឺជារដ្ឋប្រហារដឹកនាំដោយ សុន សេន ប្រឆាំងនឹង ប៉ុល ពត និង នួន ជា ហើយ? លោកធ្លាប់ឮ សោ ភឹម និយាយអ៊ីចឹងទេ?

[១៤:០៥:១៤]

**ឆ៖** បាទ ខ្ញុំមិនដែលធ្លាប់ឮទេ រឿងកិច្ចការអ៊ីចឹងៗ។ សូមចប់។

**ស៖** សាក្សីបានឆ្លើយ<បន្ត>នៅក្នុងចម្លើយដែរថា <មេរបស់គាត់ ប្រាប់គាត់ថា>៖ "គាត់<បាន>ទទួលលិខិត<មួយ>ពី សោ ភឹម។ ហើយ សោ ភឹម បាននិយាយថា គាត់នឹងទៅភ្នំពេញដើម្បីទៅពិភាក្សាគ្នាអំពីបញ្ហានេះ ព្រោះគាត់ស្តាប់តាមវិទ្យុថា ប៉ុល ពត និង នួន ជា នឹងទៅជួបមេបក្សកុម្មុយនីស្ត<>ភូមា នៅព្រលានយន្តហោះពោធិ៍ចិនតុង។" តើលោកធ្លាប់ឮ សោ ភឹម និយាយអំពីកិច្ច -- គាត់ថាឡើងទៅប្រជុំជាមួយនឹង ប៉ុល ពត និង នួន ជា ដែរឬទេ ពីព្រោះពួកគាត់ទាំងពីរហ្នឹងមកជួបមេបក្សកុម្មុយនីស្តភូមា នៅព្រលានយន្តហោះ?

**ឆ៖** បាទ ខ្ញុំមិនដែលឮទេ ពីព្រោះខ្ញុំការពារ ក៏គាត់ ទាល់តែគាត់ ដូចគាត់ទៅណាមួយ គ្រាន់តែប្រាប់ថាជូនទៅនុ៎ង ទៅចំណុចនុ៎ងអ៊ីចឹង។ បើថាគាត់និយាយពីស្អីៗ គាត់មិនដែលនិយាយប្រាប់យើងទេ។

**ស៖** សៀវភៅមួយទៀត ដែលខ្ញុំសូមលើកមកសួរលោក គឺសៀវភៅរបស់ ស្ទីហ្វិន ម័ររីស <ដែលជាអ្នកប្រវត្តិសាស្ត្រជនជាតិអូស្ត្រាលី គឺឯកសារលេខ> E3/7338។ ខ្ញុំសូមសួរលោកអំពីអ្វីដែលគាត់បានសរសេរក្នុងសៀវភៅរបស់គាត់ <ជាភាសាអង់គ្លេស> មិនមានភាសាខ្មែរ <ឬ>បារាំងទេ គឺ01001773។ <គាត់និយាយថា៖> "ជនជនរងគ្រោះមួយ <នៅក្នុងផែនការបោសសម្អាតជនក្បត់របស់ ប៉ុល ពត> គឺ<> សោ ភឹម <ដែល>ធ្វើបាន<ធ្វើ>អត្តឃាត<ខ្លួនឯង ហើយ> សោ ភឹម នេះ

គឺជាលេខាភូមិភាគបូព៌ា<នៃបក្សកុម្មុយនីស្តកម្ពុជា និង>ជាសមាជិក<គណៈមជ្ឈិមបក្សអចិន្ត្រៃយ៍>ដែរ<។ គាត់ធ្លាប់ជាអ្នកការពារដ៏មុតស្រួចប្រឆាំងនឹង>ការវាយ<ប្រហាររបស់វៀតណាម>។” តើលោកធ្លាប់ឮ សោ ភឹម និយាយអំពីការការពារខ្លួនទប់ស្កាត់ជាមួយនឹងការវាយប្រហារពីសំណាក់ប្រទេសវៀតណាមដែរឬទេ?

[១៤:០៧:៥១]

**ឆ៖** បាទ មិនដែលធ្លាប់ឮទេ។ ខ្ញុំ ដូចខ្ញុំនិយាយថា ការពារបានត្រឹមតែមួយការពារហ្នឹង បញ្ជូនទៅណេះទៅណោះនុ៎ង គ្រាន់តែមើលផ្លូវ បើថានិយាយកិច្ចការស្អីហ្នឹង មិនសូវដឹងទេ។

**លោក នីកូឡាស គូមជែន៖**

លោកប្រធាន ខ្ញុំអស់សំណួរហើយ ហើយសូមប្រគល់វេទិកានេះជូនទៅជូនសហមេធាវីនាំមុខ។

**ប្រធានអង្គជំនុំ៖**

បាទ អញ្ជើញសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

**លោក ពេជ អង្គ៖**

បាទ សូមគោរពលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម និងភាគី។

**ការតាំងសំណួរដោយសហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

**សួរដោយលោក ពេជ អង្គ៖**

**ស៖** សូមគោរពលោកសាក្សី។ ខ្ញុំមានសំណួរមួយចំនួនតូចសម្រាប់សួរលោក។ លោកមានដឹងទេថា នៅពេលដែលនៅ លោកនៅកំពង់ចាម ដែលលោកការពារលោក សោ ភឹម ថាតើលោកមានបានជួប មានចូលរួមនៅក្នុងឱកាសណាដែលលោក សោ ភឹម ដឹកនាំអង្គប្រជុំអ្វីមួយនៅខេត្តកំពង់ចាមដែរទេ?

**លោក ស៊ិន អ៊ុំង៖**

**ឆ៖** បាទ ខ្ញុំមិនដែលបានជួបកន្លែងអង្គប្រជុំនោះទេ នៅអង្កាល់ដែលខ្ញុំទៅហ្នឹង។

[១៤:០៩:២៤]

**ស៖** ហើយអ៊ីចឹងលោកមានដែលឃើញ ឬក៏ថាបានចូលរួម ឬក៏បានដឹងឮអំពីការរៀបការអ្វីមួយនៅទីនោះដែរទេ នៅភូមិភាគបូព៌ាហ្នឹង?

**ឆ៖** បាទ មិនដែលឃើញទេ។

**ស៖** បាទនៅក្នុងឯកសារមួយដែលជាឯកសាររបស់ខាង ឌី.ស៊ី.ខេម ខាងមជ្ឈមណ្ឌលឯកសារកម្ពុជា មានលេខឯកសារ E3/10714, ERN ជាភាសាខ្មែរ 01327932។ សូមទោសលោកប្រធាន ខ្ញុំអត់មាន ERN ជាភាសាបារាំង និងអង់គ្លេសទេ។ នៅក្នុងនោះគេសរសេរថា គេសរសេរ គេស្រង់ចម្លើយពីលោក គេសរសេរថា៖ "សោ ភឹម បានប្រជុំជាមួយគណៈតំបន់ និងបានណែនាំពីផែនការដែលថ្នាក់លើដាក់មកធ្វើ។" អ៊ីចឹងខ្ញុំចង់សួរបញ្ជាក់លោកម្តងទៀត ថាតើលោកមានបានដឹងថា លោក សោ ភឹម ធ្លាប់បានប្រជុំជាមួយគណៈតំបន់ ឬក៏ប្រជុំពីថ្នាក់ក្រោមបង្គាប់ដែលនិយាយអំពីផែនការទទួលពីថ្នាក់លើមកដែរឬទេលោក?

**ឆ៖** បាទ ខ្ញុំក្នុងកន្លែងដាក់ផែនការផែនអីហ្នឹង វាជាក្រសួងត្រួតបន្តៗគ្នា។ បើថាទៅប្រជុំដាក់ផែនការតែម្តង ដូចខ្ញុំមិនដែលជួបប្រទះទេ។ គ្រាន់តែផែនការគេធ្វើជាឯកសារឯកអីទៅតែម្តង។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកមេធាវី វ៉ិទ័រ កូប៉េ!

[១៤:១១:៣២]

**លោក វ៉ិចទ័រ កូប៉េ៖**

បាទ លោកប្រធាន ខ្ញុំសូមជំទាស់ដូចពីខាងដើមអ៊ីចឹង គឺ<ជំទាស់ទៅនឹង> សហព្រះរាជអាជ្ញា <ដែល>បានឆ្លើយតបថា បានយល់ស្របជាមួយមេធាវីការពារក្តីថា សោ ភឹម ហ្នឹងគឺជាថ្នាក់លើហើយ។ អ៊ីចឹងមិនចាំបាច់ញែកឲ្យដាច់ពីគ្នារវាងថ្នាក់លើ ហើយនិង សោ ភឹម នោះទេ <ដូច្នេះសំណួរដែលសហមេធាវីនាំមុខ គឺមិនត្រឹមត្រូវទេ។>

**លោក នីកូឡាស គូមជែន៖**

ខ្ញុំមិនយល់ការជំទាស់នេះទេ។ ជាការពិតហើយ សោ ភឹម គឺជាថ្នាក់ដឹកនាំភូមិភាគ អាចនិយាយបានថា គាត់ហ្នឹងត្រូវតែអនុវត្តសេចក្តីសម្រេចរបស់គណៈអចិន្ត្រៃយ៍។ ការពិតហើយ គាត់គឺជាផ្នែកមួយនៃគណៈអចិន្ត្រៃយ៍ ប៉ុន្តែវាខុសគ្នា<នៅត្រង់ សោ ភឹម និយាយថា៖ "អនុវត្តការសម្រេចរបស់ថ្នាក់តំបន់ ឬថ្នាក់ភូមិភាគ ឬក៏ថ្នាក់ស្រុក។"> បញ្ហានោះ ថាតើដូចសាក្សីបញ្ជាក់ខាងដើមថា សោ ភឹម បានប្រាប់លេខាតំបន់ទាំងអស់ហ្នឹងថា ត្រូវតែអនុវត្តនូវសេចក្តីសម្រេចរបស់ថ្នាក់លើ – <សេចក្តីសម្រេចរបស់អង្គការ>។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្ដីជំទាស់។ សំណួរនេះអាចសួរបាន ហើយអង្គជំនុំជម្រះក៏ត្រូវការស្ដាប់ចម្លើយតបរបស់សាក្សីទៅនឹងសំណួរនេះដែរ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** បាទ ខ្ញុំសូមបញ្ជាក់សាជាថ្មី ERN ចំណុចដែលខ្ញុំបានលើកសួរអម្បាញ់មិញគឺ ERN ជាភាសាខ្មែរ 01327932 ម្ដងទៀត 01327932, ជាភាសាអង់គ្លេសគឺ ERN 01338184 អត់មាន ERN ជាភាសាបារាំងទេ។ អ៊ីចឹងលោកសាក្សី តើលោកអាចបញ្ជាក់បានទេ លោកមានបានដឹងពីឱកាសណាដែលលោក សោ ភឹម បានណែនាំទៅដល់អ្នកដែលនៅក្រោមបង្គាប់របស់គាត់នៅក្នុងភូមិភាគអំពីផែនការថ្នាក់លើដែរឬទេ? ឬក៏ថាការណែនាំហ្នឹងមានទម្រង់ជាបែបអីផ្សេងក្រៅពីការប្រជុំផ្ទាល់ដែរឬទេ?

[១៤:១៣:៥១]

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** តាមខ្ញុំប៉ាន់ស្មានដឹងហ្នឹង បើថាប្រជុំបើកនិយាយប្រកាសហ្នឹង ដូចជាអត់មានទេ ក្រែងតែគាត់ចុះទៅតាមតំបន់ ចូលជួបតាមតំបន់ៗហ្នឹង ក្រែងគាត់ប្រាប់ផែនការ អាពេលចុះទៅនុ៎ង ខ្ញុំក៏មិនបានស្ដាប់គាត់ដែរ ពីព្រោះខ្ញុំគ្រាន់តែទៅ ខ្ញុំនៅតែខាងក្រៅ។ បើថាឲ្យឮផ្ទាល់ត្រចៀក វាអត់ឮផែនការប្រកាសនោះផង។

**ប្រធានអង្គជំនុំ៖**

លោកសាក្សី រំឭកម្ដងទៀត ក្នុងករណីលោកសាក្សីមិនដឹង ឬក៏មានភាពស្រពេចស្រពិល គឺលោកសាក្សីឆ្លើយថា មិនដឹង វាជាការស្រេច។ ចៀសវាងការឆ្លើយដែលមិនច្បាស់លាស់ ហើយភាពមិនដឹង ដឹង ឬក៏មិនដឹងហ្នឹង គឺពិបាកញែក។ ហើយការមិនដឹង ឬក៏មិនដឹងស្រពេចស្រពិល ស្មើនឹងមិនដឹង។ យើងរំឭករួចហើយកាលពីព្រឹកមិញ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកសាក្សី តាមដែលលោកដឹង ហើយដែលលោកស្គាល់លោក សោ ភឹម លោកអាចនិយាយថា គាត់ជាមនុស្សយ៉ាងដូចម្ដេចដែរលោក? ថាតើលោក សោ ភឹម ជាមនុស្សដែលគោរពតាមថ្នាក់លើដែរឬទេ?

[១៤:១៥:១៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញលោកមេធាវី វ៉ិចទ័រ កូប៉េ!

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ពីព្រោះថាអត់មានអ្នកណាជាមេ ជាចៅហ្វាយរបស់ សោ ភឹម ទៀតទេ។

**លោក នីកូឡាស គូមជែន៖**

សំណុំរឿងបង្ហាញខុសពីនេះ។ នៅក្នុង<រដ្ឋធម្មនុញ្ញនៃ>សម័យកម្ពុជាប្រជាធិបតេយ្យ ប៉ុល ពត មានតួនាទីជានាយករដ្ឋមន្ត្រី ហើយ សោ ភឹម ហ្នឹងជាការពិតថាគាត់ជាសមាជិកគណៈអចិន្ត្រៃយ៍ ប៉ុន្តែ <> មិនមែនជាមនុស្សដែលមានលំដាប់លេខ១ <នៅក្នុងរបបនោះទេ។ ហើយខ្ញុំគិតថា យើងទាំងអស់គ្នា និងមេធាវីការពារក្តីបានយល់ស្របលើចំណុចនេះ។> នៅក្នុងរបបនោះទេ គឺថាគាត់ស្ថិតនៅក្រោម ប៉ុល ពត និង នួន ជា ទេ។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជាការយល់ឃើញ<ថ្មី>របស់សហព្រះរាជអាជ្ញាទេ។ ខ្ញុំយល់ឃើញថា សាលក្រមរបស់អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ច្បាស់រួចហើយ គឺសូមដកស្រង់៖ និយាយអំពី "<សហ>ឧក្រិដ្ឋកម្មរួម" អ៊ីចឹងវាគ្មានអ្វីត្រូវញែកឲ្យដាច់ពីគ្នា ឲ្យឃើញអ្នកណាលេខ១ អ្នកណាលេខ២ ហើយអ្នកណាមានអំណាចលេខប៉ុន្មានបន្តបន្ទាប់នោះទៀតទេ។ <គ្រប់សមាជិកនៃគណៈអចិន្ត្រៃយ៍ គឺមានអំណាចស្មើគ្នាទាំងអស់។ តាមពិតទៅ គណៈមជ្ឈិមបក្សដែលកាន់អំណាច> ដូច្នេះវា<មិន>ត្រឹមត្រូវ<ទេ>ដែល <>និយាយ<>ថា<> ប៉ុល ពត និង នួន ជា មានឋានន្តរសក្តិ<>ខ្ពស់ជាង សោ ភឹម <>។<>

[១៤:១៦:៥៥]

**លោក នីកូឡាស គូមជែន៖**

ខ្ញុំ<គិត>ថា មេធាវីការពារក្តី<>យល់<កន្លងមក>ថា នួន ជា <>មានឋានៈលេខ២<នៅក្នុងរបបហ្នឹង។ ខ្ញុំមិនមានការដកស្រង់នៅក្នុងដៃទេ ប៉ុន្តែខ្ញុំគិតថា នេះជាតួនាទីរបស់មេដឹកនាំទាំងអស់នេះ> ជាច្រើនឆ្នាំហើយ <ដែលពួកគាត់មិនបានបដិសេធចំពោះរឿងនេះទេ។ បើសិន>ទទួលស្គាល់ថា នួន ជា គឺលេខ២ <អ៊ីចឹងយើងដឹងគ្រប់គ្នាហើយថា នរណាលេខ១ ហើយអ្នកផ្សេងទៀតប្រាកដជានៅក្រោម

គាត់ហើយ>។

**លោក វ៉ិចទ័រ កូប៉េ៖**

នេះជារចនាសម្ព័ន្ធនៃអំណាច។ អ្វីដែលយើង<តែងតែទទួលស្គាល់នោះ> គឺថា នួន ជា ជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា និងជាប្រធានសភា<>។ <យើង>មិនដែលនិយាយថា គាត់មានអំណាចណាខ្ពស់ជាង ឬក៏ធំជាង វស់ ញឹម ឬ សោ ភឹម ទេ។

**ចៅក្រម ក្លូឌា ហ្វេនស៍៖**

លោកបាននិយាយ ចង់និយាយថា ចង់និយាយថា រាល់សមាជិកសហឧក្រិដ្ឋកម្មរួមត្រូវតែមានឋានៈដូចគ្នា ឬក៏យ៉ាងម៉េច?

**លោក វ៉ិចទ័រ កូប៉េ៖**

ត្រឹមត្រូវហើយ។ គ្មានភស្តុតាងណាមួយបញ្ជាក់ថា ប៉ុល ពត និង នួន ជា នោះមានពាក់ព័ន្ធទៅនឹងឋានានុក្រមនេះ គ្មានអំណាចណាដែលខ្ពស់ជាង សោ ភឹម នោះទេ <ឬសមាជិកផ្សេងទៀតនៅក្នុងគណៈអចិន្ត្រៃយ៍ទេ។ មិនមានកន្លែងណាមួយនៅក្នុងឯកសារ<របស់បក្សកុម្មុយនីស្តកម្ពុជា> ឬក៏<លក្ខន្តិកៈរបស់បក្សកុម្មុយនីស្តកម្ពុជា ឬក៏ឯកសាររបស់រដ្ឋាភិបាលណាមួយ>បែងចែកឲ្យច្បាស់អំពីរចនាសម្ព័ន្ធអំណាចនេះទេ។ <ខ្ញុំគិតថា សូម្បីឋានៈក្នុងសភា ក៏មិនមានដែរ។>

[១៤:១៨:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះបដិសេធសេចក្ដីជំទាស់នេះ ហើយសំណួរនេះអាចសួរបាន សាក្សីឆ្លើយតបនឹងសំណួរ។

**សួរដោយលោក ពេជ អង្គ៖**

**ស៖** លោកសាក្សីថា តើលោកនៅចាំសំណួរខ្ញុំទេ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ភ្លេចបាត់ហើយអំមិញ សូមបញ្ជាក់ម្ដងទៀត។

**ស៖** លោកសាក្សីតាមដែលលោកស្គាល់លោក សោ ភឹម តើលោក សោ ភឹម ជាអ្នក ជាមនុស្សយ៉ាងដូចម្ដេចដែរ? ថាតើគាត់ជាមនុស្សដែលគោរពតាមការណែនាំរបស់បក្ស ឬក៏មជ្ឈិមបក្ស ឬក៏របស់គណៈអចិន្ត្រៃយ៍របស់បក្សដែរឬទេ?

**ឆ៖** បាទ ជំនាន់នុ៎ងខ្ញុំដូចជាមិនចេះវែស្មានមនុស្សទេ គ្រាន់ថាការងារមានគោរពនាទី តួនាទី នាទី សូម្បីថ្នាក់ណាក៏ដោយ ក្រសួង មន្ទីរ ឬក៏សមាជិក បុគ្គលិកណាក៏ដោយតែដាក់ផែនការមកធ្វើគឺធ្វើហើយ បើមិនធ្វើវាខុសខ្លួន។ ដល់អ៊ីចឹងថ្នាក់ណាក៏ត្រូវធ្វើដែរ សូម្បីប្រជាជនក៏អ៊ីចឹងដែរ តែគេឲ្យធ្វើៗ បើគេ យើងមិនធ្វើ ថាបានសេចក្ដីថាយើងប្រឆាំង។ ខ្ញុំបើថាឲ្យប៉ាន់ស្មានថារបៀបណាៗ ខ្ញុំមិនចេះ អត់ចេះវែតម្លៃ អត់ចេះនេះផងជំនាន់នោះ។

[១៤:១៩:៤៣]

**ស៖** អ៊ីចឹងតាមដែលលោកស្គាល់លោក សោ ភឹម តើលោកមានដែលមានពេលណាមួយលោកឮ លោក សោ ភឹម និយាយអ្វីដែលប៉ះពាល់ទៅដល់គណៈអចិន្ត្រៃយ៍ ឬក៏បក្ស ឬក៏មជ្ឈិមអីដែរទេ?

**ឆ៖** បាទ មិនដែលឮទេ មិនដែលឮ។ អាពាក្យពិភាក្សាហ្នឹង គាត់ម៉េចនឹងនិយាយឲ្យយើងឮ ព្រោះយើងជាអង្គរក្ស។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ថាតើគាត់បង្ហាញអំពីការគោរពរបស់គាត់ចំពោះថ្នាក់លើ ឬក៏ថាថ្នាក់មជ្ឈិម ថ្នាក់អចិន្ត្រៃយ៍ដែរទេ? ការគោរព គាត់បង្ហាញរាល់ដង -- ដែលថាលោកឃើញគាត់ហ្នឹង លោកឃើញគាត់បង្ហាញពីការគោរព ការស្ដាប់តាមការណែនាំពីថ្នាក់លើដែរទេ?

**ឆ៖** ត្រង់កន្លែងហ្នឹង ខ្ញុំដូចជាមិនយល់សំណួរ យល់ន័យសោះអារឿងគោរព ៗផែនការហ្នឹង វាដូចតែខ្ញុំថា តាមន័យខ្ញុំយល់ ដូចខ្ញុំឆ្លើយអម្បាញ់មិញហ្នឹង គ្រាន់តែថា ផែនការដាក់មកធ្វើ បើមិនធ្វើ សូម្បីប្រជាពលរដ្ឋក៏ជំនាន់នុ៎ងក៏ដោយ បើថាគេដាក់មកហើយមិនធ្វើ គឺបានសេចក្ដីថាយើងប្រឆាំងពេលនុ៎ង។ ហើយបើថាគាត់សួរថា បែបណា បែបណាហ្នឹង ខ្ញុំដូចអត់យល់ត្រង់ហ្នឹងផង។

**ស៖** អ៊ីចឹងលោកមានដែលឃើញលោក សោ ភឹម ប្រឆាំងទៅនឹងសេចក្ដីសម្រេចថ្នាក់លើដែរឬទេ?

**ឆ៖** បាទ ត្រង់ហ្នឹង ខ្ញុំមិនដែលឃើញទេ មិនដែលឃើញប្រឆាំង ឬស្អីទេ។

**លោក ពេជ អង្គ៖**

អ៊ីចឹងអរគុណច្រើនលោកសាក្សី ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** បាទ អរគុណ។ ហើយយើងមានសំណួរបន្តិចបន្តួចចង់សួរលោកបញ្ជាក់បន្ថែម។ ហើយ

ទី១ គឺលោកបានឆ្លើយរួចហើយ គ្រាន់តែយើងចង់បញ្ជាក់ឲ្យបានច្បាស់លាស់ថា ពេលវេលាដែល និងទីកន្លែងដែលលោកឮថា សោ ភឹម បានផ្តាំផ្ញើជាមួយនឹង ហេង សំរិន ថាគាត់នឹងទៅធ្វើការដោះស្រាយនៅជាមួយនឹងនៅភ្នំពេញ ហើយប្រសិនបើគាត់បាត់ដំណឹងគាត់ក្នុងរយៈពេលមួយសប្តាហ៍ ឲ្យប្រមែប្រមូលកម្លាំងសេសសល់ចូលព្រៃដើម្បីតស៊ូនោះ តើគាត់និយាយហ្នឹង និយាយគ្នាពិភាក្សាគ្នានៅទីកន្លែងណា? ហើយនៅវេលាម៉ោងប៉ុន្មានដែរ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** បាទ ពេលនុំងគឺគាត់នៅក្រុងព្រៃវែង រៀប ខ្ញុំរៀបឡើង គាត់ក៏រៀបលាគ្នាចុះមក ឡើងឡានហ្នឹង។ នៅប្រហែលវេលាខ្ញុំស្មានពេលនុំង វាមេឃវាស្រអាប់ ហើយគ្មានម៉ោងគ្មានអីផង ខ្ញុំស្មានប្រហែលជាម៉ោងបីល្ងាច ពេលនុំង។ មានម៉ោង មាននាឡិកាឯណាពាក់ជំនាន់នុំង។

[១៤:២៣:០៨]

**ស៖** អ៊ីចឹងក្រោយពេលនិយាយបញ្ហាហ្នឹងភ្លាម គឺលោក សោ ភឹម ហើយនិងក្រុមរបស់លោកដែលជាកងការងារហ្នឹង ចេញដំណើរមកភ្លាម ពីក្រុងព្រៃវែងមកកាន់ដល់អរិយក្សត្រហ្នឹងតែម្តង មកទិសដៅមកសំដៅទីក្រុងភ្នំពេញតែម្តង មែនទេ?

**ឆ៖** បាទ ពេលនុំងគ្រាន់តែនិយាយរៀបចុះពីឡាន រើតុហ្នឹង បានខ្ញុំឮ ខ្ញុំចូលទៅយកប្រមូលដបទឹក ហើយនិងកែវទឹកហ្នឹង ឮគាត់និយាយផ្តែផ្តាំគ្នាតែប៉ុណ្ណឹង ហើយៗចុះឡើងឡានមកតែម្តង ទៅ ឡើងទៅស្វាយអន្ទរ ឡើងទៅបត់តាមព្រៃខ្លា ព្រៃញ្ញោហ្នឹង។

**ស៖** បាទ អរគុណ។ ហើយយានជំនិះដែលធ្វើដំណើរមកហ្នឹង គឺមានៗប៉ុន្មានគ្រឿង មានតែមួយគ្រឿង ឬក៏មានពីរគ្រឿង ឬក៏មានច្រើនគ្រឿង?

**ឆ៖** បាទ យានជំនិះជិះមកមានតែពីរគ្រឿងហ្នឹង អាឡានអាហ្ស៊ីប កាលនុំងអត់ មានតែដំបូលក្រណាស់ កង់បួនតូចៗជំនាន់តាំងពីជំនាន់អាមេរិកាំងម្លេះ រថយន្តនោះ។

**ស៖** ហ្ស៊ីបទាំងពីរគ្រឿង ឬក៏យ៉ាងម៉េច?

**ឆ៖** បាទ អាហ្ស៊ីបទាំងពីរគ្រឿង។

**ស៖** លោកនៅចាំអ្នកបើកបរហ្ស៊ីបទាំងពីរគ្រឿងនៅខណៈនោះ ដែលធ្វើដំណើរពីព្រៃវែងមកដល់អរិយក្សត្រ ដែលសំដៅមកក្រុងភ្នំពេញនោះ? តើអ្នកបើកបររថយន្តនោះ លោកស្គាល់ឈ្មោះអ្នកទាំងពីរនាក់នោះដែរឬទេ?

[១៤:២៥:១២]

**ឆ៖** បាទ ខ្ញុំស្គាល់ ព្រោះអ្នកបរឡាននោះ ក៏ពួកនៅមកការពារជាមួយខ្ញុំហ្នឹងដែរ។ មួយឈ្មោះ គឹម មួយឈ្មោះ ម៉េង។

**ស៖** បាទ អរគុណ។ ហើយលោកដឹងដំណឹង ឬទទួលព័ត៌មានអំពីជោគវាសនាអ្នកបើកបររថយន្តទាំងពីរនាក់នោះដែរឬទេ? តើជោគវាសនាគាត់យ៉ាងម៉េចដែរ?

**ឆ៖** បាទ ខ្ញុំមានឮដំណឹងអីបន្តិចទេ ប្រហែលជាស្លាប់បាត់អស់រលីងហើយ គ្មាននៅទេ ព្រោះតែកុងឡានហ្នឹងនៅ ទៅជាមួយជាប់នឹងគាត់ហ្នឹងហើយ។ សូមបញ្ចប់ហើយ។

**ស៖** បាទ អរគុណ។ ហើយចុះខណៈពេលដែលលោកទទួលបានព័ត៌មានពីជោគវាសនារបស់លោក សោ ភឹម ដែលថាព័ត៌មានពីកងទ័ពនៅព្រែកពោធិ៍ថាបាន គាត់ធ្វើអត្តឃាតនោះ តើលោកបានដឹងព័ត៌មានពីជោគវាសនាអ្នកផ្សេងទៀតក្រៅពីលោកនោះដែរឬទេ? ក្រៅពីអ្នកតែកុងឡានពីរនាក់នោះ តើអ្នកផ្សេងទៀតហ្នឹង មានជោគវាសនាយ៉ាងម៉េច? លោកបានទទួលព័ត៌មាននោះដែរឬទេ?

**ឆ៖** បាទ ព័ត៌មានជោគវាសនាអ្នកទាំងអស់នោះ បែបខ្ញុំមិនបានដឹងឮទេ។ គ្រាន់តែដឹងថា គេចាប់ទាំងអស់នៅកន្លែងនុ៎ង។ ថារស់ បែបមិន ៗឮ លេចដំណឹងថានៅរស់ទេ។

**ស៖** បាទ អរគុណ។ ហើយយើងសួរមួយទៀត រឿងពាក់ព័ន្ធនឹងបុគ្គលមួយចំនួននៅភូមិភាគបូព៌ា។ ហើយលោកស្គាល់ លោកខស្សាហ៍ដើរជាមួយនឹង សោ ភឹម តាមឯកសារគឺលោកទៅស្ទើរតែគ្រប់ភូមិភាគ -- គ្រប់តំបន់ដែលចំណុះឲ្យភូមិភាគបូព៌ា សំណួរសួរថា តើលោកបានដែលទៅតំបន់២៤ដែរឬទេ?

[១៤:២៧:៣៥]

**ឆ៖** បាទ ខ្ញុំសូមឆ្លើយចម្លើយ តំបន់ កាលនោះខ្ញុំវានៅមិនចាំ មិនស្គាល់ដឹងភូមិសាស្ត្រទេ តែតំបន់នោះ ខ្ញុំធ្លាប់ទៅច្រើនតំបន់ ប៉ុន្តែមិនដឹងតំបន់ណា គេបែងចែក២៤ តំបន់ណា២៣ ប៉ុន្តែទៅ។ ធ្លាប់ទៅតាមគាត់ដែរ ប៉ុន្តែគ្រាន់មិនស្គាល់ថាកន្លែង តំបន់ហ្នឹង គេឈ្មោះអី តំបន់នេះស្អីទេ។

**ស៖** បាទ អរគុណ។ ហើយក្នុងចំណោមតំបន់ទាំងឡាយដែលលោកទៅចំណុះភូមិភាគបូព៌ាដែលលោកបានទៅជាមួយនឹង សោ ភឹម ទៅការពារគាត់នោះ តើលោកស្គាល់ប្រធានតំបន់ ឬក៏អនុប្រធានតំបន់ណាមួយនៃតំបន់ភូមិភាគបូព៌ានោះដែរឬទេ?

**ឆ៖** បាទ ខ្ញុំធ្លាប់ស្គាល់ឈ្មោះ ដោយសារ គឹម តៃកុងឡាននោះប្រាប់ ថាយើងមកតំបន់ គឺមាន

ស្គាល់តំបន់ឈ្មោះ ឈាន មួយ មេតំបន់ ហើយនិងឈ្មោះ ចាន់ ហុង -- ចាន់ សេងហុង អ៊ីចឹងមួយ។ មានស្គាល់ឈ្មោះពីរនាក់ហ្នឹង។ អាហ្នឹងឈ្មោះ ឈាន ហ្នឹង តែពីរហ្នឹង។

**ស៖** កាលនោះឈ្មោះ ឈាន ហ្នឹងលោកដឹងថា គាត់ដែលថាស្គាល់នោះ តើគាត់ជាលេខាតំបន់ណានៃភូមិភាគបូព៌ា?

**ឆ៖** មកទាល់ពេលឥឡូវហ្នឹង ខ្ញុំភ្លេចហើយ តំបន់ដែល ឈាន ឈរជើងហ្នឹងនៅម្តុំខាងជើងក្រុងព្រៃវែង ខាងក្រុងព្រៃវែងហ្នឹង។ ម្តុំអស់ហ្នឹង ប៉ុន្តែមិនដឹង ខ្ញុំវាភ្លេច មិនដឹងគេបែងចែកទៅតំបន់ស្អីតំបន់ស្អី ព្រោះគេបែងចែកទៅតាមស្រុក ហើយខ្ញុំ ទើបនឹងមកអ៊ីចឹង ម៉េចនឹងស្គាល់ភូមិសាស្ត្រអស់។ សូមបញ្ចប់។

[១៤:២៩:៥០]

**ស៖** ហើយលោកដឹងថា ឈ្មោះ ឈាន ហ្នឹងដែលជាប្រធានតំបន់នុ៎ង គឺគាត់នៅរស់រានមានជីវិត ឬក៏ដែលជួបគាត់ទេ ឥឡូវនេះ តាំងពីលោកក្រោយរំដោះឆ្នាំ១៩៧៩?

**ឆ៖** បាទ មិនដែលឃើញទេ ប្រហែលជាស្លាប់បាត់ហើយ ជំនាន់នុ៎ង ព្រោះឥឡូវមិនដែលឃើញមុខ ហើយមិនដែលលេចឮផង។

**ស៖** បាទ អរគុណ។ ហើយសូមបញ្ជាក់រំឭកលោកម្តងទៀត ថាលោកមិនច្បាស់ទេ គឺឆ្លើយថាមិនដឹងទេ។ ជៀសវាងឆ្លើយឲ្យមានភាពស្រពេចស្រពិល នៅក្នុងការចម្លើយរបស់លោក។ ហើយចុះលោកៗ សេងហុង អំមិញ ភូមិភាគ។ លោកចាំទេថា លោក សេងហុង ហ្នឹងគាត់កាន់នៅលេខាតំបន់ណានៃភូមិភាគបូព៌ា?

**ឆ៖** បាទ កាលដែលខ្ញុំមកហ្នឹង ជួបគាត់នៅតំបន់ភ្នំឈើកាច់យើង ឈើកាច់ព្រៃវែងនេះ គាត់នៅម្តុំខាងកើតភ្នំឈើកាច់ហ្នឹង មន្ទីរគាត់ហ្នឹង ប៉ុន្តែមិនដឹងមន្ទីរគេនៅកន្លែងណាខ្លះទេ ប៉ុន្តែគ្រាន់ខ្ញុំមកជួបគាត់នៅត្រង់នុ៎ង។

**ស៖** ហើយគាត់មានឋានៈ ដែលលោកជួបហ្នឹង គាត់មានឋានៈជាលេខា ឬក៏មានតួនាទីអីដែលលោកដឹងច្បាស់លាស់ថា គាត់មានតួនាទីអី? លេខា ឬក៏អនុលេខា ឬក៏ជាសមាជិកតំបន់?

**ឆ៖** ត្រង់កន្លែងនុ៎ង ខ្ញុំមិនច្បាស់ទេ ព្រោះមិនដឹងលេខាមិនដឹង ប្រធានក៏មិនដឹងដែរ ព្រោះខ្ញុំគ្រាន់ថា គាត់នៅតំបន់នុ៎ងតែម្តង។ ទាល់តែមានគេប្រាប់ខ្ញុំថា បានៗខ្ញុំដឹង។ បាទ សូមបញ្ចប់សំណួរ។

[១៤:៣២:០៧]

**សះ** បាទ អរគុណ។ ហើយលោកដឹងថា នៅភូមិភាគបូព៌ាហ្នឹង អ្នកដែលបន្ទាប់ពី សោ ភឹម មក មានអ្នកណាខ្លះទេ នៅភូមិភាគ នៅភូមិភាគបូព៌ា?

**ឆះ** បាទ រឿងបន្ទាប់ហ្នឹង ខ្ញុំមិនដឹងអ្នកណាតួនាទីស្អីទេ ប៉ុន្តែគ្រាន់តែថាដឹង អនុប្រធានមន្ទីរមួយនៅក្បែរខ្ញុំហ្នឹង គាត់ជាអនុតាន៎ុង ប៉ុន្តែគាត់អនុប្រធានក្ដោបក្ដាប់មន្ទីរមិនដឹង ក៏អនុប្រធានក្ដោបក្ដាប់ខាងកិច្ចការភូមិភាគក៏មិនដឹងដែរ ប៉ុន្តែដឹងថា គាត់នៅក្នុងមន្ទីរនោះ។

**សះ** បាទ អរគុណ។ ហើយចុះលោកដែលស្គាល់តំបន់២១ដែរទេ?

**ឆះ** បាទ ខ្ញុំ ឥឡូវខ្ញុំភ្លេចអស់ហើយតំបន់ មិនដឹងគេបែងចែកទៅណាទៅណី ខ្ញុំជំនាន់នោះ ឥឡូវវាភ្លេចហើយទាល់ឥឡូវ ប៉ុន្តែធ្លាប់ដើរតាមតំបន់ ប៉ុន្តែឥឡូវមិនដឹងថា តំបន់ណា២១កាលន៎ុងឥឡូវ ទាល់ឥឡូវវាយូរពេក។

**សះ** បាទ ហើយលោកអាចបញ្ជាក់បានដែរទេ នៅទីតាំងដោយលោកប្រើថា ជាសេនាធិការភូមិភាគ។ តើសេនាធិការភូមិភាគហ្នឹង នៅទីតាំងនៅៗពិតប្រាកដនៅកន្លែងណា?

**ឆះ** ខ្ញុំកន្លែង កន្លែងទីតាំងសេនាធិការភូមិភាគហ្នឹង ខ្ញុំមិនដែលបានទៅចូលទេ ប៉ុន្តែគ្រាន់តែឮអ្នកដែលនៅសេនាធិការហ្នឹង គេមកដល់កន្លែងខ្ញុំហ្នឹង ខ្ញុំសួរគេថា នៅឯណា ថានៅសេនាធិការ។ សេនាធិការហ្នឹងនៅកន្លែង០៩ ប៉ុន្តែមិនដឹង០៩ហ្នឹង ស្ថិតនៅកន្លែងណា។ នៅខាងជើងថ្នល់ជាតិមិនដឹង នៅខាងណាមិនដឹងទេ ខ្ញុំព្រោះខ្ញុំមិនដែលបានទៅកន្លែងន៎ុង។

**សះ** ចុះលោកដឹងថា សោ ភឹម គាត់ឧស្សាហ៍ទៅទី មន្ទីរសេនាធិការភូមិភាគបូព៌ាញឹកញាប់ដែរឬទេ?

[១៤:៣៥:០៨]

**ឆះ** បាទ ពេលន៎ុង គាត់មិនដែលទៅទេ កាលខ្ញុំទៅនៅ ក្រែងតែមុនៗហ្នឹងទេ។ បើពេលខ្ញុំទៅនៅជាមួយគាត់ន៎ុង គាត់មិនដែលទៅទេ មានពីសេនាធិការគេមក។ មានរឿងអីវ៉ាវអី មានតែសំបុត្រស្នាមន៎ុងទៅ ពេលនោះ។ សុំចប់ហើយ។

**សះ** ហើយលោកដែលស្គាល់មន្ទីរសន្តិសុខភូមិភាគបូព៌ាដែរទេ?

**ឆះ** មន្ទីរសន្តិសុខបូព៌ាមិនដឹងស្ថិតនៅកន្លែងណាទេ ប៉ុន្តែគ្រាន់តែថា ឮគេប្រាប់ខ្ញុំថា កន្លែងថាគ្នាឯងនិយាយលេងប្រាប់ថា បើអ្នែងធ្វើខុសអី ប្រយ័ត្នបញ្ជូនទៅដាក់គុកអី អាគ្នាយើង បុគ្គលិកមួយគ្នាហ្នឹង និយាយលេងហ្នឹង។ ខ្ញុំសួរ គុកនៅណា? ឮគេប្រាប់ថា នៅស្រែស្ដែ គេថាអ៊ីចឹង។ បើថាឲ្យខ្ញុំទៅ

ដល់ ខ្ញុំមិនដែលបានទៅផង។

**ស៖** ហើយលោកដែលឮថា អ្នកណាជាអ្នកធ្វើប្រធានមន្ទីរសន្តិសុខស្រែស្ដែនុ៎ងទេ?

**ឆ៖** ខ្ញុំមិនឮច្បាស់ទេ ប៉ុន្តែគ្រាន់តែថា អ្នកដែលគេបុគ្គលិកប្រឡែងគ្នាជាមួយខ្ញុំ វាជន្លហ្នឹង គេរកនេះហ្នឹង គេអាចបានដឹងខ្លះយ៉ាង បានគេថា ឈ្មោះកន្លែង បងតែន អ៊ីចេះ។ គេថាអ៊ីចឹង ប្រយ័ត្នយកអ្វែងទៅដាក់ បងតែន អ៊ីចឹង។ ឮឈ្មោះអ៊ីចឹង។

**ស៖** អរគុណ។ ហើយសម័យមានជម្លោះជាមួយវៀតណាម តើលោកដែលបានទៅសមរភូមិប្រយុទ្ធជាមួយនឹងវៀតណាមដែរឬទេ ពេលដែលវៀតណាមចូលមកដល់ទឹកដីកម្ពុជា?

**ឆ៖** បាទ ជំនាន់នុ៎ងខ្ញុំមិនដែលបានទៅទេ នៅតែខាងក្រោយនេះ មិនដែលបានទៅដល់នុ៎ងផង។ សុំចប់។

[១៤:៣៧:៣៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាបន្តទៅនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី – លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍។ សុំអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

បាទ សូមអរគុណ លោកប្រធាន។ ខ្ញុំមានសំណួរមួយសួរទៅសាក្សី។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** លោកសាក្សី កាលពីព្រឹកមិញគេសួរទាក់ទងទៅនឹងលេខាកងពលទី៥ គឺមនុស្សម្នាក់ឈ្មោះ អេង គឹម។ អ៊ីចឹងខ្ញុំចង់សួរលោកថា តើ អេង គឹម ហ្នឹងគាត់ជាអនុប្រធានកងពលលេខ៤ នៅពេលដែល ហេង សំរិន ធ្វើជាប្រធានកងពលនោះ? តើលោកពិតជាបាននិយាយអ៊ីចឹងមែនទេ ព្រឹកមិញ?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ព្រឹកមិញខ្ញុំដូចជាមិនបានថា ហេង គឹម កងពលលេខ៤ទេ។ ខ្ញុំគ្រាន់ថា លោក ហេង សំរិន គឺកងពលលេខ៥ -- កងពលលេខ៤ ហើយថា ហេង គឹម មិនមែនកងពលលេខ៤ទេ។ ដូចមិនបាននិយាយព្រឹកមិញថា ដូចមិនបាននិយាយថា ហេង គឹម កងពលលេខ៤ទេ។ គ្រាន់ថា លោក ហេង សំរិន ជំនាន់នុ៎ង។ ខ្ញុំដឹងតែប៉ុណ្ណឹង។

**ប្រធានអង្គជំនុំ៖**

លោកចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ហេង គីម មិនមែន អេង ទេ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

**ស៖** ខ្ញុំសុំអភ័យទោស ដោយសារខ្ញុំ<និយាយ>អត់<>ច្បាស់ជាភាសាខ្មែរ។ តាមលោកនិយាយពីព្រឹកមិញហ្នឹង <>តើ<លោក>ដឹងថា <>មានរឿងអីកើតឡើងចំពោះ <ហេង គីម>? គេចាប់គាត់ ឬក៏យ៉ាងម៉េច?

**លោក ស៊ិន អ៊ឹង៖**

**ឆ៖** ខ្ញុំបាទមិនបានឃើញច្បាស់ទេ គ្រាន់ថាអារឿងចាប់ មិនចាប់ ខ្ញុំមិនបានឃើញផ្ទាល់ភ្នែកទេ ហើយ ហេង គីម ហ្នឹង ក៏មិនបានជួបគាត់ផង។ គ្រាន់តែឮតែឈ្មោះ ប៉ុន្តែមុខមាត់ មិនដឹងដូចម៉េច។ សូមបញ្ចប់។

[១៤:៤០:៣១]

**ស៖** តើលោកមានធ្លាប់ឮ គេនិយាយថា គាត់ហ្នឹងត្រូវបានគេចាប់ខ្លួនដែរឬទេ? ហើយបើបានឮគេនិយាយថា គាត់ត្រូវបានគេចាប់ខ្លួនហ្នឹង គាត់ត្រូវបានគេចាប់ខ្លួននៅពេលណាដែរ?

**ឆ៖** បាទ ឮគេចាប់ខ្លួនហ្នឹង អាពេល ត្រង់ថាគេចាប់ខ្លួន ដូចខ្ញុំឆ្លើយអំមិញ ថាខ្ញុំមិនបានឃើញទេ ខ្ញុំមិនដឹងទេ។ តែបើថា បើសិនណាជាគេចាប់ខ្លួន ចាប់អាពេលគេចាប់បន្តបន្ទាប់ហ្នឹង ប៉ុន្តែមិនដឹងពេលថ្មើរណា ថ្មើរណា ក៏ខ្ញុំមិនបានដឹងដែរ ព្រោះកាលនុ៎ង ភ័យរត់តែរួចខ្លួនម្នាក់ៗហ្នឹង។

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៍៖**

ខ្ញុំចោទសំណួរនេះសួរទៅលោកនោះ ពីព្រោះកាលព្រឹកមិញនោះ ដូចមានគេនិយាយថា គីម ហ្នឹង ទំនងជាអ្នកដែលរាយការណ៍ទៅមជ្ឈិមអំពី<ផែនការ>ក្បត់របស់ ហេង សំរិន ក៏ប៉ុន្តែនៅក្នុងសំណុំរឿងយើងនេះ មានឯកសារមួយចំនួនដែលមានឈ្មោះ ហេង គីម <ឬ យ៉េង គីម>។ ប៉ុន្តែថាគាត់ទំនងជាត្រូវបានឃុំខ្លួននៅមន្ទីរស-២១ នៅក្នុងបញ្ជីអ្នកទោសមន្ទីរស-២១ នៅលេខរៀង១៩៨៩ ចូលថ្ងៃទី០៥ មិថុនា ឆ្នាំ១៩៧៨។ ខ្ញុំសូមបញ្ជាក់ផងដែរ ថាឈ្មោះ ហេង គីម នេះមាននៅឯកសារ E3/1957, <E3/1959>, <E3/1960> ហើយនិង E3/2014 ហើយនិង E3/2187។ <ខ្ញុំលើកឡើងនេះដើម្បីបញ្ជាក់ថា>ប្រតិចារឹក<គឺមានពេញលេញ>។

ខ្ញុំអស់សំណួរហើយលោកប្រធាន។ សូមអរគុណ។

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

[១៤:៤២:៥៥]

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំសូមលើកឡើងដើម្បីជាកំណត់ត្រាប្រតិចារឹក លោកប្រធាន។ គឺតាមពិតទៅ មានអនុប្រធានពីរ <នៅក្នុងកងពលលេខ៤។> ឯកសារ <E3/1568>, អង់គ្លេសមានលេខ <00651892>, បារាំងមានលេខ <007433667 ដែលកិច្ចសម្ភាសន៍របស់ ប៉ែន យៀរនិន ជាមួយនឹងលោក ហេង សំរិន ខ្ញុំសូមដកស្រង់> គឺបានសរសេរថា<>៖ "គឹម គឺជាអនុប្រធានកងពលទី៤ មិនច្បាស់ទេ ថានៅពេលក្រោយ នៅពេលដែលកងពលទី៥ ត្រូវបានបង្កើតឡើង គឹម បានក្លាយទៅជាប្រធានកងពលទី៥ មិនច្បាស់។" ដូច្នេះហើយខ្ញុំគិតថា គឹម គឺជាមេបញ្ជាការរង<នៃកងពលទី៤> ហើយត្រូវបានចាប់ខ្លួន គឺ <ខ្ញុំយោងទៅលើឯកសារដែលបានបង្ហាញនៅថ្ងៃព្រហស្បតិ៍ គឺ> ឯកសារ<>E3/2014 <គឺត្រូវបានចាប់ខ្លួននៅថ្ងៃជាមួយនឹង ប្រាក់ ជឿក> ប៉ុន្តែយ៉ាងក៏ដោយ ដូចដែល ហេង សំរិន បានបញ្ជាក់អ៊ីចឹង គឺមានមេបញ្ជាការរងមួយទៀត របស់កងពលលេខ៤។ ហើយក្នុងការឯកសារហ្នឹង គឺសុទ្ធតែមានដាក់ពាក្យមួយថា "មិនច្បាស់ៗ"។

[១៤:៤៤:៣៩]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

ខ្ញុំបង្កើតសំណួរទាំងអស់នេះ គ្រាន់តែថា លោកក៏បាននិយាយពាក់ព័ន្ធនឹង គឹម នេះដែរ។ អ៊ីចឹងហើយបានខ្ញុំចោទសំណួរទាំងអស់នេះ ដើម្បីបន្ថែមបំពេញពីលើអ្វីដែលលោកសួរ កាលពីព្រឹកមិញនេះ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ឥឡូវនេះដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅរហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

អញ្ជើញៗ!

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន មុននឹងសម្រាក <>ក្រុម<មេធាវី>ខាងយើងនេះ អត់មានសំណួរ<ដើម្បីចោទសួរសាក្សីទៀត>ទេ។ អ៊ីចឹងប្រហែលជាអស់លោក លោកស្រីចៅក្រម អាចឲ្យគាត់ទៅផ្ទះវិញបាន លោកប្រធាន។

[១៤:៤៥:២៧]

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

**ប្រធានអង្គជំនុំ៖**

បាទ អរគុណនូវព័ត៌មានដ៏ល្អនេះ។ បាទ អង្គជំនុំជម្រះសូមអរគុណលោក ស៊ិន អ៊ឹង សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីរហូតដល់ពេលនេះ ដល់ទីបញ្ចប់ហើយ ហើយសក្ខីកម្មរបស់លោក នឹងអាចរួមវិភាគទានក្នុងការស្វែងរកការពិតក្នុងរឿងក្ដីនេះ។ ឥឡូវហ្នឹង វត្តមានរបស់លោកនៅ អ.វ.ត.ក នេះ លែងមានភាពចាំបាច់ទៀតហើយ លោកអាចវិលកាន់ ទៅកាន់លំនៅដ្ឋានរបស់លោក ឬក៏គោលដៅណាដែលលោកមានបំណងចង់ទៅបានហើយ។ សូមលោកមានសុខភាពល្អ ជួបតែសំណាងល្អ បានសេចក្ដីសុខ សេចក្ដីចម្រើន។

ហើយមន្ត្រី -- អង្គជំនុំជម្រះក៏សូមអរគុណផងដែរ លោកស្រី សុក សុជាតា មេធាវីប្រឹក្សាសាក្សី ឥឡូវនេះលោកស្រីអាចសម្រាកបានហើយ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយផ្ដល់កន្លែងសម្រាក -- សម្របសម្រួលជាមួយបុគ្គលិកអង្គភាពគាំពារសាក្សី និង អ្នកជំនាញ ក្នុងការជូនលោក ស៊ិន អ៊ឹង វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់ ឬក៏គោលដៅណាដែលគាត់មានបំណងចង់ទៅបានហើយ។

ហើយសវនាការជាបន្តទៅទៀតនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការផ្ដើមស្ដាប់សក្ខីកម្មសាក្សី 2-TCW-1060។ ហើយឥឡូវនេះ ដល់ពេលសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

*(សវនាការសម្រាកពីម៉ោង ១៤:៤៦ នាទី ដល់ម៉ោង ១៥:០៣ នាទី)*

[១៥:០៣:៥៧]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ ហើយសវនាការជាបន្តទៅនេះ អង្គជំនុំជម្រះធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-1060។ ហើយមុនស្ដាប់សក្ខីកម្មសាក្សីរូបនេះ អង្គជំនុំជម្រះចេញសេចក្ដីសម្រេចផ្ទាល់មាត់លើសំណើសុំរបស់មេធាវីការពារក្ដី នួន ជា ដែលបានសុំបន្ថែមពេលវេលាសម្រាប់ស្ដាប់សក្ខីកម្មសាក្សី 1069 និង 1070។ ហើយក្រោយពីស្ដាប់នូវសក្ខីកម្មសាក្សី 1069 ស៊ិន អ៊ឹង ចប់ គឺអង្គជំនុំជម្រះសម្រេចថា អង្គជំនុំជម្រះតម្កល់រក្សាទុកនូវសេចក្ដីសម្រេចរបស់ខ្លួន

*ប្រតិចារឹកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារឹកក្នុងភាសាទាំងបី។ ប្រតិចារឹកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារឹកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

ដដែល គឺការស្តាប់សក្ខីកម្មសាក្សី 2-TCW-1070 គឺកំណត់ពេលវេលាតែមួយថ្ងៃទេ គឺភាគីសហព្រះរាជអាជ្ញារួមទាំងសហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីពីរវគ្គនៃថ្ងៃសវនាការ ហើយភាគីការពារក្តីទាំងពីរក្រុម ពីរវគ្គនៃថ្ងៃសវនាការ។

បាទ តទៅនេះស្តាប់សក្ខីកម្មសាក្សី 2-TCW-1060 មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីមកកាន់កន្លែងផ្តល់សក្ខីកម្មក្នុងបន្ទប់សវនាការ។

*(សាក្សីចូលក្នុងបន្ទប់សវនាការ)*

[១៥:០៦:២២]

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** សួស្តីលោកសាក្សី ថាតើលោកឈ្មោះអី?

**លោក នួន ត្រិច៖**

**ឆ៖** ខ្ញុំឈ្មោះ នួន ត្រិច។

**ស៖** នួន ត្រិច ឬក៏ ទេស ត្រិច?

**ឆ៖** ឈ្មោះ នួន ត្រិច។

**ស៖** បាទ អរគុណ។ ហើយលោកប្រើប្រាស់ឈ្មោះនៅក្នុងអត្តសញ្ញាណរបស់លោក លោកប្រើឈ្មោះអីសព្វថ្ងៃនេះ ឈ្មោះផ្លូវការ ដូចនៅក្នុងអត្តសញ្ញាណប័ណ្ណ ឬក៏ឯកសារផ្សេងៗ?

**ឆ៖** ឈ្មោះ នួន ត្រិច ដែរ ក្នុងអត្តសញ្ញាណប័ណ្ណ។

**ស៖** បាទ អរគុណ។ ហើយក្រៅពីឈ្មោះ ត្រិច ហ្នឹង តើលោកមានដែលប្រើឈ្មោះអីផ្សេងទៀតទេដែរឬទេ?

**ឆ៖** ជំនាន់សម័យ ប៉ុល ពត ខ្ញុំឈ្មោះ ភ័ក្ត។

**ស៖** ចុះមានឱកាសណាមួយលោកប្រើឈ្មោះ អុល ហៅថា អុល ដែរឬទេ?

**ឆ៖** អុល ឈ្មោះក្នុងបញ្ជីជាតិ ជីតាខ្ញុំដាក់។

[១៥:០៧:៥៩]

**ស៖** ហើយបញ្ជីជាតិ ឬសំបុត្រកំណើតហ្នឹង ឥឡូវគេលែងប្រើហើយមែនទេ?

**ឆ៖** គេលែងប្រើហើយបញ្ជីជាតិអង្កាល់រីកហ្នឹង បញ្ជីជាតិឈ្មោះពីសង្គម ឈ្មោះ អុល ហ្នឹង

01391983


នោះ។

**ស៖** បាទ អរគុណ។ ហើយចុះត្រកូល "ទេស" ហ្នឹង ត្រកូលអ្នកណាគេ? ឈ្មោះឪពុក ឬក៏ឈ្មោះជីតារបស់លោក?

**ឆ៖** ឈ្មោះឪពុក អ៎! ឈ្មោះជីតា "ទេស" ហ្នឹង។

**ស៖** ចុះ "នួន" ឈ្មោះនរណាគេ?

**ឆ៖** "នួន" ឪពុក។

**ស៖** បាទ អរគុណ។ ហើយលោក នួន ត្រិច តើលោកកើតនៅថ្ងៃខែឆ្នាំណា? លោកចាំទេ?

**ឆ៖** អត់ចាំដែរទេបង។

**ស៖** ឆ្នាំនេះលោកអាយុប៉ុន្មានហើយ?

**ឆ៖** ឆ្នាំហ្នឹង ៦៣ឆ្នាំហើយ។

**ស៖** អរគុណ។ ហើយទីកន្លែងកំណើតរបស់លោកនៅទីកន្លែងណា?

**ឆ៖** នៅភូមិត្រពាំងឈូក ឃុំមេសរជ្រៃ ស្រុកស្ទឹងត្រង់។

**ស៖** ចុះទីលំនៅបច្ចុប្បន្ននេះ តើលោករស់នៅទីកន្លែងណា?

[១៥:០៩:៣៤]

**ឆ៖** នៅភូមិត្រពាំងឈូក ស្រុកស្ទឹងត្រង់ហ្នឹងដែរ។

**ស៖** ស្រុកស្ទឹងត្រង់ហ្នឹង នៅក្នុងខេត្តអីគេឥឡូវនេះ?

**ឆ៖** ក្នុងខេត្តកំពង់ចាម។

**ស៖** បាទ អរគុណ។ ហើយឪពុកបង្កើតរបស់លោកឈ្មោះអី? ហើយម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអី?

**ឆ៖** ឪពុកបង្កើតឈ្មោះ នួន, ម្ដាយបង្កើតឈ្មោះ រីន។

**ស៖** ចុះប្រពន្ធរបស់លោកឈ្មោះអី? ហើយលោកមានកូនប៉ុន្មាននាក់?

**ឆ៖** ប្រពន្ធខ្ញុំបាទឈ្មោះ សុខ លាង, កូនមានបីនាក់ ឈ្មោះ សុខ ម៉េន, ឈ្មោះ សុខ ឃី, ឈ្មោះ ស្រីអូន។

**ស៖** លោក ត្រិច តើលោកតាមដែលលោកដឹង តើលោកមានជាប់ចំណងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទទាំងពីររូប លោក នួន ជា និងលោក ខៀវ សំផន និងបុគ្គលទាំងឡាយ

ត្រូវបានទទួលយកជាភាគីដើមបណ្ដឹងរដ្ឋប្បវេណីក្នុងរឿងក្ដីនេះដែរឬទេ?

**ធ៖** អត់មានទេបង។

**ស៖** អរគុណ។ តើលោកបានធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែករួចហើយឬនៅ មុននឹងចូលមកចំពោះមុខអង្គជំនុំជម្រះនាពេលនេះ?

[១៥:១១:០៨]

**ធ៖** បាទ មានស្បថរួចហើយ។

**ស៖** តទៅនេះ យើងប្រាប់អំពីសិទ្ធិ និងករណីយកិច្ចដល់លោកក្នុងឋានៈលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ លោក ត្រិច ក្នុងឋានៈលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការចំពោះមុខអង្គជំនុំជម្រះនេះ លោកអាចបដិសេធក្នុងការឆ្លើយតបនូវសំណួរ ឬការធ្វើអត្ថាធិប្បាយរៀបរាប់ណា ដែលនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។

អំពីករណីយកិច្ច ក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតបរាល់សំណួរទាំងឡាយដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក ឡើកលែងតែសំណួរណានាំឲ្យចម្លើយតបរបស់លោក ឬការរៀបរាប់អត្ថាធិប្បាយរបស់លោកនាំឲ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចយើងប្រាប់អំពីសិទ្ធិរួចហើយអម្បាញ់មិញនេះ។ ហើយក្នុងឋានៈលោកជាសាក្សី ត្រូវតែឆ្លើយតែការណ៍ណាដែលពិត ដែលបានដឹង បានឮ បានឃើញ បានចងចាំ ឬធ្លាប់មានបទពិសោធន៍ជួបប្រទះ ឬបានធ្វើការសង្កេតដោយផ្ទាល់នូវព្រឹត្តិហេតុ ហេតុការណ៍ទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរ ដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសួរចំពោះលោក។

ហើយតើរយៈពេលកន្លងមក លោកធ្លាប់បានផ្ដល់សក្ខីកម្ម ឬក៏ផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតនៃការិយាល័យសហចៅក្រមស៊ើបអង្កេត នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជានេះដែរឬទេ?

**ធ៖** មានគេទៅសួរដល់ផ្ទះខ្ញុំបាទ ខាងតុលាការជំនុំជម្រះហ្នឹងទៅសួរដល់ផ្ទះខ្ញុំបាទ។

**ស៖** អរគុណ។ ហើយអង្កាល់សួរហ្នឹងប៉ុន្មានដងដែរ? លោកផ្ដល់សក្ខីកម្មប៉ុន្មានដង?

[១៥:១២:៥៥]

**ធ៖** ឃើញគេទៅសួរខ្ញុំបាទហ្នឹងពីរដង ទៅដល់ផ្ទះ។

**ស៖** ពីរដងហ្នឹង លោកដឹងទេថាភាគីណា -- អ្នកណាគេទៅពីណាទៅ ដែលសួរលោកហ្នឹង?

01391985



ទៅពី ជាអ្នកស៊ើបអង្កេតសាលាជម្រះក្ដីនេះ ឬក៏ទៅពីស្ថាប័នផ្សេង ទៅពីអង្គភាពផ្សេង?

**ឆ៖** ឃើញគេទៅស៊ើបហ្នឹង ខាងស្ថាប័នស៊ើបសួរ ខាងពីស្ថាប័នខ្មែរក្រហមជំនាន់ពីប្រជាជាតិមកហ្នឹង ទៅរហូតដល់ផ្ទះខ្ញុំហ្នឹង។

**ស៖** បាទ អរគុណ។ ហើយមុនចូលមកចំពោះមុខអង្គជំនុំជម្រះនេះ តើលោកបានពិនិត្យមើល ឬក៏បានអាននូវកំណត់ហេតុដែលលោកផ្ដល់សក្ខីកម្មជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុន ដើម្បីរំឭកការចងចាំដែរឬទេ?

**ឆ៖** បាទ ខ្ញុំចងចាំខ្លះ ភ្លេចខ្លះ ព្រោះយូរហើយ នៅចាំមិនបានអស់ទេបង។

**ស៖** បាទ ហើយតាមសមត្ថភាពដែលលោកអាចដឹងបាន តើលោកអាចបញ្ជាក់ដែរទេថាកំណត់ហេតុដែលស្ដាប់សក្ខីកម្ម ដែលលោកបានអានដើម្បីរំឭកការចងចាំហ្នឹង គឺវាពិតជាត្រឹមត្រូវ សមស្របស៊ីសង្វាក់គ្នាទៅនឹងចម្លើយដែលលោកបានផ្ដល់កិច្ចសម្ភាសន៍ជាមួយនឹងអ្នកស៊ើបអង្កេតកាលពីពេលមុន នៅនឹងផ្ទះរបស់លោកនោះដែរឬទេ?

**ឆ៖** ខ្ញុំនឹងឆ្លើយតាមដែលគេទៅស៊ើបការណ៍ដល់ផ្ទះយើងខ្ញុំហ្នឹង ខ្ញុំនឹងឆ្លើយតាមហ្នឹង តែមិនអាចចាំបានអស់ទេ ចាំខ្លះភ្លេចខ្លះ។

[១៥:១៤:៥៤]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយតាម ក្នុងការសួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះផ្ដល់វេទិកាជូនទៅសហមេធាវីការពារក្ដី នួន ជា ដើម្បីសួរដេញដោលសាក្សីរូបនេះ មុនភាគីដទៃទៀតនៃរឿងក្ដី។ ហើយសហមេធាវីទាំងពីរក្រុមមានរយៈពេលពីរវគ្គនៃថ្ងៃសវនាការក្នុងការសួរដេញដោលសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក វ៉ិចទ័រ កូប៉េ៖**

សូមអរគុណលោកប្រធាន។

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** សូមជម្រាបសួរលោកសាក្សី ខ្ញុំមានសំណួរមួយចំនួនដើម្បីសួរលោកនៅពេលនេះ។ គឺថាខ្ញុំនឹងបន្តសួររហូតទៅដល់ម៉ោងបួន ហើយប្រហែលជាអាចបន្តទៅដល់ថ្ងៃពុធព្រឹកទៀត។ ដូច្នេះឥឡូវខ្ញុំ

ចាប់ផ្ដើមសួរលោក នូវសំណួរដំបូងរបស់ខ្ញុំ គឺលោកបានបញ្ជាក់ថា លោកបានផ្ដល់ចម្លើយដល់អ្នកស៊ើបអង្កេតរបស់តុលាការនេះ។ តើលោកមានបានផ្ដល់ចម្លើយប៉ុន្មានឆ្នាំមុន ជាមួយអ្នកស៊ើបអង្កេតមកពីអង្គការមួយដែលមានឈ្មោះថា មជ្ឈមណ្ឌលឯកសារកម្ពុជាដែរឬទេ?

**លោក នួន គ្រិច ៖**

**ឆ៖** បាន ដែរ។ តែគេទៅធ្វើដល់ផ្ទះហ្នឹង ខ្ញុំបានឆ្លើយដែរ។

[១៥:១៦:៣១]

**ស៖** ខ្ញុំនិយាយទៅលើការសម្ភាសជាមួយមជ្ឈមណ្ឌលឯកសារកម្ពុជា និងកំណត់ហេតុស្ដាប់ចម្លើយរបស់លោកទាំងពីរនេះ។ តើលោកអាចប្រាប់តុលាការបានទេថា មុនពេលរំដោះភ្នំពេញថ្ងៃទី១៧ មេសា ៧៥ហ្នឹង តើលោកធ្វើអ្វី? លោកនៅកន្លែងណា? ហើយលោកមានតួនាទីអ្វីដែរ?

**ឆ៖** រំដោះឆ្នាំ៧៥ហ្នឹង ខ្ញុំនៅធ្វើពេទ្យនៅសេនាធិការភូមិភាគ៣០៤។

**ស៖** តើលោកចាប់ផ្ដើមធ្វើការជាពេទ្យនៅ<មន្ទីរពេទ្យ>៣០៤ហ្នឹងនៅពេលណាដែរ?

**ឆ៖** ខ្ញុំធ្វើការពេទ្យនៅវរៈ៣១៤ហ្នឹង ខ្ញុំចូលវ៉ៃជំនាន់ហ្នឹងខាងខ្មែរក្រហមហ្នឹង ចូលវ៉ៃដាច់ភ្នំពេញឆ្នាំ៧៥ ខ្ញុំក៏ ៧៦នោះ ក៏គេដកខ្ញុំទៅចូលធ្វើខាងពេទ្យ ខាងវរៈ៣១៤ ខាងព្យាបាលខាងទ័ព។

**ស៖** មុនថ្ងៃ១៧ មេសា <ឆ្នាំ១៩៧៥> គឺថាលោកជាពេទ្យ តើលោកមានទទួលការបណ្ដុះបណ្ដាលដើម្បីក្លាយជាពេទ្យដែរឬទេ នៅពេលដែលលោកស្នាក់នៅក្នុងស្រុកចំការលើនោះ?

**ឆ៖** ជំនាន់នោះខ្ញុំនៅស្រុកចំការលើនោះ ខ្ញុំនៅពេទ្យស្រុកហ្នឹង ខ្ញុំព្យាបាលខាងប្រជាពលរដ្ឋនៅក្នុងស្រុកចំការលើហ្នឹង។ ដល់ពេលឆ្នាំ៧៥ហ្នឹង ក៏គេដកមកខាងពេទ្យសេនាធិការភូមិភាគ។ ដល់វ៉ៃដាច់ភ្នំពេញ គេដកចូលមកពេទ្យយើងព្រះកេតុមាលា គេហៅនៅភ្នំពេញហ្នឹងគេហៅពេទ្យ ព-៩៩។ ហើយដល់ក្រោយមក បានគេដកពីពេទ្យ ព-៩៩ ហ្នឹងទៅពេទ្យយោធា វរសេនាតូច៣១៤ កងពល៣១០។

**ស៖** ឥឡូវនេះ យើងជជែកមុនឆ្នាំ៧៥ មុនខែមេសា ៧៥ បន្តិច។ ខ្ញុំចង់សួរថាតើលោកទទួលការបណ្ដុះបណ្ដាលផ្នែកពេទ្យហ្នឹង បណ្ដុះបណ្ដាលអ្វីខ្លះ ឬក៏បណ្ដុះបណ្ដាលជំនាញអ្វីខ្លះ ពេលដែលលោកនៅស្រុកចំការលើនោះ?

[១៥:១៩:៥៦]

**ឆ៖** ដូចអត់មានបណ្ដុះបណ្ដាលអីទេ។ ចូលទៅហ្នឹង គឺព្យាបាល ធ្វើរៀនបណ្ដើរ ព្យាបាលបណ្ដើរ បច្ចេកទេសរៀនជាក់ស្ដែងបណ្ដើរ។

ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។

**ស៖** លោកនិយាយថា លោកព្យាបាលជនស៊ីវិល ប៉ុន្តែខ្ញុំចង់សួរថា លោកបានព្យាបាលទាហាន ដែលទទួលរងរបួសក្នុងសមរភូមិដែរឬទេ? គឺបានន័យថា ទាហាន ឬក៏កងទ័ពដែលវាយជាមួយពួក លន់ នល់ មុនឆ្នាំ៧៥នោះ?

**ឆ៖** ជំនាន់មុន៧៥ហ្នឹង ខ្ញុំអត់បានព្យាបាលទេ ជំនាន់មុន៧៥ហ្នឹង ខ្ញុំចូលធ្វើទ័ពដែលគេចាប់ឲ្យធ្វើទ័ពជំនាន់ឆ្នាំ១៩៧៣ហ្នឹង គេឲ្យៗខ្ញុំហ្នឹង យុទ្ធជនហ្នឹង គេឲ្យទៅរៀនវគ្គ។ បើអ្នកណាឆ្លើយថា យុទ្ធជនជាកម្លាំងសមរភូមិមុខ ហ្នឹងបានឆ្លើយត្រូវ។ បើអ្នកណាថា ឆ្លើយជាសមរភូមិក្រោយ គឺថាអត់មាន អត់មានឆ្លើយត្រូវទេ។ អ៊ីចឹងគេចាប់ឲ្យធ្វើទ័ព ជំនាន់១៩៧៣ហ្នឹង។

**ស៖** នៅពេលដែលលោកក្លាយជាកងទ័ពហ្នឹង តើលោកនៅក្នុងកងពលលេខប៉ុន្មានដែរ? គឺថា នៅខាងឧត្តរដែលលោកធ្លាប់ធ្វើការហ្នឹង នៅក្នុងកងពលលេខប៉ុន្មានដែរ?

**ឆ៖** កាលខ្ញុំទៅធ្វើទ័ពនៅជំនាន់នុ៎ង នៅទ័ពភូមិភាគ តែវរសេនាធំ ខ្ញុំអត់ចាំដែរវឹកហ្នឹង ព្រោះទៅហ្នឹង កាលវឹកហ្នឹង ខ្ញុំនៅវ័យក្មេង នៅអាយុ១៥ឆ្នាំ អត់ចាំផង។

**ស៖** នៅពេលដែលលោកជាយុទ្ធជន គឺនៅមុនឆ្នាំ៧៥នុ៎ង តើ អឿន គឺជាមេបញ្ជាការជាន់ខ្ពស់ ឬក៏មេបញ្ជាការខ្ពស់បំផុត <នៅក្នុងកងវរសេនាធំ ឬកងពល>ដែលលោកធ្វើការ<>មែនទេ?

[១៥:២២:៣៤]

**ឆ៖** អឿន ហ្នឹងប្រធានកងពល៣១០។ វឿន អនុប្រធានកងពល៣១០។

**ស៖** តើ អឿន នៅជាមេបញ្ជាការលោករហូត គឺថាតាំងពីមុនបង្កើតកងពល៣១០ រហូតដល់បង្កើតកងពល៣១០ហ្នឹងមែនទេ? តើ អឿន ហ្នឹងជាមេបញ្ជាការរបស់លោករហូតមកមែនទេ?

**ឆ៖** ខ្ញុំទើបនឹងគេដកមកធ្វើពេទ្យវរៈ៣១៤ហ្នឹង ខ្ញុំទើបធ្វើកូនចៅគាត់។ ពីមុនមកខ្ញុំអត់បានក្តាប់បានដែរ ព្រោះវាយចូលភ្នំពេញហ្នឹង កាលវឹកហ្នឹង ខ្ញុំនៅជាពេទ្យឡើយទេ។ ទើបដល់ពេលចូលភ្នំពេញហើយ បានខ្ញុំដកមកចូលខាងពេទ្យវរៈ ខាងកងទ័ពវិញ។

**ស៖** អរគុណ។ ឥឡូវនេះ ខ្ញុំសូមបន្តទៅជជែកអំពីពេលវេលាក្រោយថ្ងៃ១៧ មេសា ៧៥វិញ គឺថាលោកមាន -- នៅក្នុងអំឡុងពេលមួយនោះ លោកចាប់ផ្តើមធ្វើការនៅមន្ទីរពេទ្យសេនាធិការ គឺថា លោកប្រើប្រាស់ឈ្មោះ ដែលគេហៅឈ្មោះបច្ចុប្បន្នហ្នឹង គឺមន្ទីរពេទ្យព្រះកេតុមាលា។ នៅពេលដែលលោកធ្វើការនៅមន្ទីរពេទ្យនោះ តើនៅពេលនោះ គេហៅមន្ទីរពេទ្យ ព-៩៩ មែនទេ?

**ឆ៖** បាទៗ ពេលនុ៎ង គេដាក់ឈ្មោះមន្ទីរពេទ្យ ព-៩៩។

**ស៖** តើមន្ទីរពេទ្យហ្នឹង ស្ថិតនៅក្រោមកងពល៣១០មែនទេ?

**ឆ៖** បាទ មន្ទីរពេទ្យហ្នឹង ក្រោមការកងពល៣១០។ ប្រធានកងពលឈ្មោះ អឿន ហ្នឹង។

**ស៖** តើលោកដឹងថា ព-៩៨ ហ្នឹងគឺនៅពេលដំបូងគេហៅថា ព-៩៧ ឬក៏ព-៩៨ មុនពេលដែលគេប្តូរឈ្មោះទៅព-៩៨ តើលោកដឹងអំពីឈ្មោះនេះទេ?

[១៥:២៥:៤០]

**ឆ៖** ពីមុនគេដាក់ព-៤៩ អត់ព-៤៧ពីមុន បានក្រោយមកដាក់ព-៩៨។

**ស៖** តើលោកអាចរៀបរាប់អំពីការងាររបស់លោកនៅព-៩៨ បានទេ? តើលោកធ្វើការអ្វីដែរ? តើភារកិច្ចប្រចាំថ្ងៃរបស់លោកហ្នឹងគឺបំពេញការងារអ្វី?

**ឆ៖** ជំនាន់នុ៎ងខ្ញុំនៅខាងពេទ្យហ្នឹង ខាងព្យាបាលជំងឺ លាងរបួសអី អង្គាល់ទាហានជំនាន់នុ៎ងគេវ៉ៃដាច់ទាហាន លន់ នល់ ព្រោះអ្នកជំងឺរបួសច្រើន ហើយក៏លាងរបួសទៅ ព្យាបាលជំងឺអ្នកគ្រុនចាញ់អីចឹង។

**ស៖** ប្រសិនបើខ្ញុំយល់មិនខុសទេ គឺលោកធ្វើការប្រហែលជាមួយឆ្នាំនៅក្នុងមន្ទីរពេទ្យព-៩៨។ ហើយនេះក៏ជាអ្វីដែលលោកឆ្លើយនៅក្នុងកំណត់ហេតុស្តាប់ចម្លើយ E3/7877 អង់គ្លេសមានលេខ <00346978>, ខ្មែរមានលេខ <00342436>, បារាំង <00411784>។ តើលោកធ្វើការប្រហែលមួយឆ្នាំនៅមន្ទីរពេទ្យហ្នឹងរហូតដល់ពេលដែលគេចាប់ខ្លួនលោកមែនទេ? ខ្ញុំនឹងនិយាយអំពីការចាប់ខ្លួននៅពេលមុខបន្តិចទៀតនេះ ប៉ុន្តែខ្ញុំចង់សួរថាតើលោកធ្វើការរយៈពេលមួយឆ្នាំនៅព-៩៨ គឺធ្វើការរហូតដល់ពេលដែលគេចាប់ខ្លួនលោកនុ៎ងមែនទេ?

**ឆ៖** ខ្ញុំធ្វើការហ្នឹងបានជិតមួយឆ្នាំ ក៏គេផ្លាស់ឲ្យមកធ្វើពេទ្យនៅវរសេនាតូច៣១៤ ក៏បានគេចាប់ខ្លួន។ គេថាខ្ញុំហ្នឹងមាន ជំនាន់ហ្នឹងគេថា ខាងភូមិភាគឧត្តរហ្នឹង គេថា កងពល៣១០ហ្នឹងក្បត់។ ក៏គេត្រូវថា ចាប់ខ្លួនជាប់ជនក្បត់ ដូចថាខ្ញុំហ្នឹងជាប់ជាអ្នកជនក្បត់តាមគេដែរ។ តែខ្ញុំអត់មានដឹងទេ ព្រោះកាលវីកហ្នឹងនៅក្មេង មានដឹងថាក្បត់ មិនក្បត់អីទេ។ គេ ក៏គេចាប់ខ្លួនមកដែរ។

[១៥:២៨:៤៧]

**ស៖** ខ្ញុំយល់អំពីចំណុចនេះលោក។ ប៉ុន្តែខ្ញុំដូចជាមិនច្បាស់ នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក គឺនៅទំព័រដដែលដូចដែលខ្ញុំនិយាយមុននេះ គឺលោកបានឆ្លើយដូចតទៅនេះ ហើយខ្ញុំសូមអាននូវចម្លើយរបស់លោកឡើងវិញ។ “សំណួរ៖ តើលោកធ្វើការនៅ<មន្ទីរពេទ្យ ព-៩៨>រយៈពេល

ប៉ុន្មានដែរ? លោកឆ្លើយថា៖ ខ្ញុំធ្វើការនៅពេទ្យនោះជិតមួយឆ្នាំ គឺរហូតដល់ឆ្នាំ<១៩៧៧>។ ក្រោយមកទើបផ្លាស់ទៅកងវរសេនាតូច៣១៤ ជាភស្តុភាររបស់កងពល៣១០។ ខ្ញុំនៅប្រចាំការនៅជិតអង់តែនទូរទស្សន៍នៅទៅទួលគោក។" ខ្ញុំយល់ថា ចម្លើយហ្នឹងគឺបានន័យថា លោកផ្ទេរ លោកផ្លាស់ទៅកងវរសេនាតូច៣១៤ ដែលជាភស្តុភាររបស់កងពល៣១០។ តើវាជាការយល់ច្រឡំឬទេ ថាតើនៅពេលដែលលោកទៅកងវរសេនាតូច៣១៤ហ្នឹង លោកនៅធ្វើជាពេទ្យដដែល ឬមួយក៏យ៉ាងម៉េច?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំទាន់អាលឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ខេល លីសាក់៖**

សូមអរគុណលោកប្រធាន។ កិច្ចសម្ភាសន៍ដែលខ្ញុំមាន E3/7877 គឺថាគាត់ធ្វើការនៅ ព-៩៩ ប្រហែលមួយឆ្នាំ រហូតដល់ឆ្នាំ៧៦ មិនមែន៧៧។ ដូច្នេះខ្ញុំគិតថា វាមានភាពយប់ច្រឡំ។

**លោក វ៉ិចទ័រ កូប៉េ៖**

ខ្ញុំក៏អានថា ៧៦ ដែរ។

[១៥:៣០:២៤]

**លោក ខេល លីសាក់៖**

ប៉ុន្តែអំមិញ លោកអាន៧៧។

**លោក វ៉ិចទ័រ កូប៉េ៖**

អ៊ីចឹងប្រហែលជាខ្ញុំខុសហើយ សូមទោស។

**សួរដោយលោក វ៉ិចទ័រ កូប៉េ៖**

**ស៖** លោកសាក្សី គឺកងវរសេនាតូច៣១៤ហ្នឹង ថាតើលោកធ្វើការនៅ៣១៤ ជាពេទ្យដដែល ឬមួយក៏យ៉ាងម៉េចដែរ ព្រោះថា៣១៤ហ្នឹងគឺជាភស្តុភាររបស់កងពល៣១០នោះ?

**លោក នួន គ្រិច៖**

**ឆ៖** ខ្ញុំមកនៅវរសេនាតូច៣១៤ហ្នឹង ខ្ញុំធ្វើពេទ្យដដែល ប្រចាំភស្តុភារកងពល៣១០ហ្នឹង។

**ស៖** តើលោកអាចពន្យល់បានទេថា ហេតុអ្វីបានជាភស្តុភាររបស់កងពល៣១០ បែរជាត្រូវការពេទ្យទៅវិញ?

ឆ៖ ភស្តុភារ៣១០ហ្នឹង គឺខ្វះបុគ្គលិកពេទ្យ ដល់អ៊ីចឹងគេត្រូវឲ្យដកចេញពីកងពលពេទ្យ នៅយើង ព-៩៩ ហ្នឹង មកតាមកងពល -- វរៈ៣១៤ហ្នឹង ព្រោះតាមភស្តុភារហ្នឹង គឺខ្វះបុគ្គលិកពេទ្យ។

សៈ តើលោកចាំទេថា លោកធ្វើការនៅវរសេនាតូច៣១៤ ជាភស្តុភារកងពល៣១០ហ្នឹង តើលោកនៅទីនោះប៉ុន្មានខែ ឬក៏ប៉ុន្មានអាទិត្យដែរ មុនពេលដែលគេចាប់ខ្លួនលោកនោះ?

[១៥:៣២:៣១]

ឆ៖ ខ្ញុំនៅប្រហែលជិតមួយឆ្នាំ។ មកដល់១៩៧៧ បានគេចាប់មេៗ បានគេហៅខ្ញុំនេះ ចាប់ខ្លួនដែរ។

សៈ ឥឡូវនេះខ្ញុំសួរលោកអ៊ីចេះវិញ តើលោកនៅវរសេនាតូច៣១៤ រយៈពេលប៉ុន្មានខែដែរ មុនពេលដែល អឿន ដែលជាមេបញ្ជាការហ្នឹង ត្រូវបានគេចាប់ខ្លួន?

ឆ៖ នៅជាប់មួយឆ្នាំដែរ បង។ មួយឆ្នាំហ្នឹង បានគេថា កងពល៣១០ហ្នឹង គេថាក្បត់ ថាក្បត់ហ្នឹង ប្រុងថាផ្ទុះវ៉ៃទីក្រុងភ្នំពេញ។ ហើយក៏កងពល៣១០ហ្នឹង គេចាប់បណ្ដើរៗ ចាប់តាំង ចាប់មេ ចាប់វរសេនាតូច ចាប់វរសេនាធំ ចាប់កងធំ កងតូចហ្នឹងបណ្ដើរៗ។

សៈ ឥឡូវនេះខ្ញុំនឹងសួរអំពីទីតាំងៗផ្សេងមួយចំនួន។ ព-៩៩ គឺឥឡូវហ្នឹង គេហៅថាជាមន្ទីរព្រះកេតុមាលា តើលោកដឹងទេថា មន្ទីរពេទ្យ ព-៩៩ហ្នឹង មានទីតាំងនៅកន្លែងណាដែរ? ឧទាហរណ៍ថា ផៀបជាមួយនឹងវត្តភ្នំ ឬក៏ផៀបជាមួយនឹងមន្ទីរពេទ្យកាល់ម៉ែត ឬក៏ផៀបជាមួយអង់តែនទូរទស្សន៍ទួលគោកហ្នឹង តើលោកអាចប្រាប់ពីទីតាំងរបស់ពេទ្យ ព-៩៩ ហ្នឹងបានទេ?

ឆ៖ ទីតាំងព-៩៩ហ្នឹង បើខ្ញុំដឹង ថានៅព្រះកេតុមាលាហ្នឹង អាហ្នឹងទីតាំង ព្រោះកន្លែងហ្នឹង គេដាក់មន្ទីរពេទ្យព-៩៩ ព្រះកេតុមាលាហ្នឹង។

សៈ ខ្ញុំយល់។ អ៊ីចឹងបានន័យថា ពេទ្យនុំងនៅជិតវត្តភ្នំពេញមែនទេ? ហើយក៏នៅជិតបញ្ជាការកងពលដែរមែនទេ?

ឆ៖ បាទ នៅជិតវត្តភ្នំ ហើយបញ្ជាការកងពលនុំង ប្រធានកងពល៣១០ហ្នឹង នៅត្រង់ជិតវត្តស្រះចក នៅក្បែរមន្ទីរពេទ្យហ្នឹងដែរ។

[១៥:៣៥:៤៦]

សៈ តើពេទ្យហ្នឹង នៅជិតមន្ទីរពេទ្យកាល់ម៉ែតដែរ អត់ទេ?

ឆ៖ មន្ទីរពេទ្យហ្នឹងជិតវត្តភ្នំ ជាប់វត្តភ្នំហ្នឹង។

**សៈ** និយាយជាទូទៅ គឺពេទ្យកាល់ម៉ែត ពេទ្យព្រះកេតុមាលា និងវត្តភ្នំហ្នឹងគឺនៅក្នុង គឺថានៅក្នុងតំបន់ហ្នឹង មានបញ្ជាការដ្ឋានរបស់កងពល៣១០ អ៊ីចឹងមែនទេ?

**ឆៈ** ជំនាន់នុ៎ង ពេទ្យកាល់ម៉ែត គេដាក់មន្ទីរពេទ្យកុមារ។ ហើយបើមន្ទីរពេទ្យខាង ព-៩៨ ព្រះកេតុមាលាហ្នឹង គេដាក់ខាងពេទ្យទាហាន។

**សៈ** ប៉ុន្តែថាតើបរិវេណរបស់ ឬក៏ទីតាំងរបស់កងពល៣១០ហ្នឹង តើតំបន់ដែលមានពេទ្យកាល់ម៉ែត មានពេទ្យព្រះកេតុមាលាជាដើមហ្នឹង គឺជាមូលដ្ឋានរបស់កងពល៣១០ មែនទេ?

**ឆៈ** វាចែកដាច់ពីគ្នា គ្រាន់តែថា វានៅក្នុងតំបន់កងពល៣១០ តែគេចែកដាច់។ បើពេទ្យកាល់ម៉ែត គេដាក់ពេទ្យកុមារ អត់មាននៅក្នុងក្រសួងពេលទាហានទេ បាទបង។

**សៈ** ឥឡូវនេះខ្ញុំសួរលោកឱ្យច្បាស់បន្តិចតែម្តងទៅ គឺខ្ញុំចង់និយាយអំពីការប្រជុំមួយដែលលោកបានចូលរួមនៅសាលារៀនមួយដែលនៅក្បែរវត្តភ្នំ គឺការប្រជុំហ្នឹង មានការចូលរួមពីកម្មាភិបាល ហើយនិងយុទ្ធជនទាំងអស់មកពីកងពល៣១០។ តើលោកអាចពន្យល់បានទេ ថាតើសាលាហ្នឹងគឺនៅកន្លែងណាដែរ? លោកអាចបញ្ជាក់ឱ្យបានច្បាស់បន្តិចទេ ពីសាលាមួយក្បែរវត្តភ្នំហ្នឹង?

[១៥:៣៨:២០]

**ឆៈ** សាលាហ្នឹង ខ្ញុំនៅជាប់វត្តភ្នំហ្នឹង ខាងជើងវត្តភ្នំហ្នឹង ខ្ញុំទើបនឹងគេចាប់ប្រធានកងពលហើយទេ បានគេហៅមកខាងនុ៎ង ជំនាន់នុ៎ង ភាគខាងជើងកងពល៥០២ហ្នឹង គេមកក្តាប់ហើយ។ ដល់មកក្តាប់ហើយគេហៅប្រជុំ គេថា មេកងពលខ្ញុំក្បត់ហើយ គេចាប់ហើយ អ៊ីចឹងសមមិត្តទាំងអស់ត្រូវដឹងថាប្រធានកងពលហ្នឹង ត្រូវចាប់ហើយ។ អ៊ីចឹងទើបនឹងចូលប្រជុំថ្ងៃនុ៎ង បានខ្ញុំដឹងថា សាលាហ្នឹងមាននៅខាងជើងវត្តភ្នំហ្នឹង។ ខ្ញុំមិនដែលចូលដែរ ទើបនឹងគេហៅប្រាប់ហ្នឹង។

**សៈ** ខ្ញុំនឹងសួរអំពីសាលាហ្នឹង នៅពេលក្រោយបន្តិចទៀតនេះ។ ប៉ុន្តែឥឡូវនេះ ខ្ញុំចង់សួរលោកពីទីតាំងមួយទៀត គឺថា លោកបានក្លាយជាផ្នែកមួយរបស់កងវរសេនាតូច៣១៤ ជាភស្តុភាររបស់កងពល៣១០។ នៅក្នុងកំណត់ហេតុរបស់លោក លោកបាននិយាយថា គឺនៅជិតអង់តែនទូរទស្សន៍នៅទួលគោក។ ដូច្នេះ តើលោកអាចប្រាប់បានទេថា អង់តែនទូរទស្សន៍នៅទួលគោកហ្នឹង នៅកន្លែងណាឱ្យបានច្បាស់លាស់?

**ឆៈ** ខ្ញុំរឹកហ្នឹង ខ្ញុំនៅចល័ត កាលជំនាន់ខ្ញុំគេដកទៅធ្វើពេទ្យវរសេនាតូច៣១៤ហ្នឹង គឺទៅព្យាបាលទ័ព ស្ទូងស្រូវនៅកប់ស្រូវ នៅបឹងបាយ៉ាប នៅទួលសង្កែ អ៊ីចឹងដើរ គេឱ្យកង់មួយជិះដើរព្យាបាល។

សៈ តើពីវត្តភ្នំទៅអង់តែនទូរទស្សន៍ទួលគោកហ្នឹង វាមាចម្ងាយប្រហែលប៉ុន្មានដែរ?

ឆៈ អត់បានដឹងដែរ អត់ដឹងជាគីឡូដែរ អត់បាន។

[១៥:៤០:៣៨]

សៈ ប្រសិនបើលោកជិះម៉ូតូពីវត្តភ្នំទៅអង់តែនទូរទស្សន៍ទួលគោកហ្នឹង វាចំណាយពេលប្រហែលប៉ុន្មានដែរ?

ឆៈ ជំនាន់នុ៎ង ខ្ញុំអត់មានម៉ូតូជិះផង មានតែកង់ អត់ដឹងគីឡូផង។

សៈ នៅពេលដែលលោកនិយាយ នៅពេលដែលលោកហៅថា "អង់តែនទូរទស្សន៍ទួលគោក" ហ្នឹង តើវាជាស្ថានីយ៍វិទ្យុហ្នឹងមែនទេ?

ឆៈ អង់តែនទូរទស្សន៍ហ្នឹង ជំនាន់នុ៎ងឮតែ ជំនាន់ពី ជំនាន់សម្តេចសីហនុមក គេថាអង់តែនទូរទស្សន៍ ហៅតៗគ្នាមក។ ខ្ញុំចូលមកភ្នំពេញអត់សូវស្គាល់ដែរ ឮគេថាអង់តែនទូរទស្សន៍ អង់តែនទូរទស្សន៍ នឹងគេទៅ។

សៈ នៅពេលដែលលោកនៅខាងភស្តុភារ ដែលប្រចាំការនៅជិតអង់តែនទូរទស្សន៍នៅទួលគោក តើលោកនៅជិតស្ថានីយ៍វិទ្យុទូរទស្សន៍ភ្នំពេញហ្នឹងមែនទេ?

ឆៈ ខ្ញុំនៅ ឈរនៅជិតទូរទស្សន៍អង់តែនទូរទស្សន៍ហ្នឹង។

សៈ តើអ្នកណាជាអ្នកគ្រប់គ្រងទៅលើស្ថានីយ៍វិទ្យុទូរទស្សន៍នៅទួលគោកហ្នឹង? តើវានៅក្រោមកងពល៣១០ ដែរមែនទេ?

ឆៈ ជំនាន់នុ៎ងទូរទស្សន៍ហ្នឹងគេអត់មានប្រើផង ដូចអត់មានឃើញពីណាក្តាប់អង់តែនទូរទស្សន៍ហ្នឹងផង គ្រាន់តែថានៅក្នុងក្រោមការ កន្លែងកងពល៣១០ហ្នឹងនៅ ស្នាក់នៅកាន់មួយកន្លែងហ្នឹង។

សៈ <ស្ថានីយ៍ទូរទស្សន៍មិនដំណើរការទេ ប៉ុន្តែ>កន្លែងហ្នឹងគឺគេសម្រាប់ដំណើរការវិទ្យុ<អ៊ីចឹងមែនទេ>?

[១៥:៤៣:២៦]

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយតប!

អញ្ជើញសហព្រះរាជអាជ្ញារងអន្តរជាតិ!

**លោក ឌេល លីសាក់៖**

សូមអរគុណលោកប្រធាន។ មេធាវីកំពុងតែព្យាយាមសួរនាំមុខសាក្សី ៗបានប្រាប់ហើយថា ជាអង់តែនទូរទស្សន៍ គ្មានអ្នកណាដឹងថាវាជាអង់តែនវិទ្យុអ្វីអីនោះទេ។ ឥឡូវនេះគាត់កំពុងតែសួរហាក់បីដូចជានាំមុខសាក្សីហើយ។ បើសិនណាជាគាត់មានព័ត៌មានមកសួរតទល់ អានោះជារឿងមួយផ្សេង។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** ខ្ញុំសួរម្តងទៀតឲ្យបានជាក់ច្បាស់។ លោកសាក្សី លោកនិយាយអំពីអង់តែនទូរទស្សន៍នៅទួលគោក ដែលជាកន្លែងភស្តុភាររបស់អង្គភាពលោក។ លោកដឹងដែរ លោកដឹងថាគេមានប្រើប្រាស់វាហ្នឹងសម្រាប់វិទ្យុផង ឬក៏យ៉ាងណា?

**លោក នួន ត្រិច៖**

**ឆ៖** ជំនាន់ហ្នឹងកន្លែងអង់តែនទូរទស្សន៍ហ្នឹងគេអត់ដាក់ទូរទស្សន៍ទេ គេដាក់នារីកាត់ដេរកងពលនៅចំកន្លែងហ្នឹង។

**ស៖** ដូច្នេះមិនមែនជាអត់តែនសម្រាប់ផ្សាយវិទ្យុនោះទេ <តើត្រឹមត្រូវដែរឬទេ?> អ៊ីចឹងអង់-តែនផ្សាយវិទ្យុ <នៅភ្នំពេញ> គឺថានៅកន្លែងផ្សេងមែនទេ?

**ឆ៖** កន្លែងផ្សាយទូរទស្សន៍ហ្នឹងនៅកន្លែងផ្សេង ខ្ញុំអត់ដឹងដែរ មិនដឹងគេដាក់ត្រង់ណាដែរ។

[១៥:៤៥:១១]

**ប្រធានអង្គជំនុំ៖**

កន្លែងផ្សាយវិទ្យុ ផ្សាយរ៉ាដ្យូ ខ្មែរហៅវិទ្យុ ប៉ុស្តិ៍វិទ្យុហ្នឹង ជំនាន់នោះនៅកន្លែងណា?

**លោក នួន ត្រិច៖**

**ឆ៖** ប៉ុស្តិ៍វិទ្យុជំនាន់នុ៎ង គេដាក់ៗនៅស្ទឹងមានជ័យ។ ទាស់ខ្ញុំមិនដែលទៅឃើញដែរ ឮតែគេថានៅស្ទឹងមានជ័យ អត់ឃើញដែរ។

**សួរដោយលោក វ៉ិចទ័រ កូប៉េះ៖**

**ស៖** មុនពេលខ្ញុំចូលសួរអំពីការចាប់ខ្លួនលោក ខ្ញុំសូមសួរលោកអំពីអង្គប្រជុំមួយដែលលោកបានរៀបរាប់ថា ដែលលោកបានរៀបរាប់នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោកនោះគឺអង្គប្រជុំដែលបានបើកនៅក្នុងសាលាមួយក្បែរវត្តភ្នំ។ តើលោកអាចជម្រាបជូនអង្គជំនុំជម្រះបន្តិចបានទេថា នៅក្នុងអង្គប្រជុំនេះ លោកបានស្តាប់ឮអ្វីខ្លះដែរ អំពីការចាប់ខ្លួនមេបញ្ជាការ<កងពល>របស់លោក ឈ្មោះ

*ប្រតិចារិកដែលត្រូវបានកែតម្រូវ៖ អត្ថបទនៅក្នុងចន្លោះសញ្ញា (<) និង (>) ត្រូវបានកែតម្រូវ ដើម្បីធានាឲ្យមានភាពស្របគ្នារវាងប្រតិចារិកក្នុងភាសាទាំងបី។ ប្រតិចារិកត្រូវបានកែតម្រូវ ផ្អែកទៅលើភាសាដើមដែលមាននៅក្នុងខ្សែអាត់សំឡេង។ ប្រតិចារិកដែលត្រូវបានកែតម្រូវទាំងនេះអាចខុសពីការបកប្រែផ្ទាល់មាត់នៅក្នុងទូបកប្រែ និងទូបកប្រែបន្ត។*

អឿន នោះ?

**ឆ៖** ថ្ងៃនុ៎ង គេឲ្យមិត្តៗមកប្រជុំនៅកន្លែងហ្នឹងទាំងអស់ មួយវរៈ ហើយនិងវរសេនាតូច៣១៤ ហើយនិងវរសេនាធំ ខ្ញុំមិនចាំដែរ ទាល់មកត្រង់ហ្នឹងច្រើន ពេញកន្លែងហ្នឹង។ គេថា ប្រកាស គេថា "សូមសមមិត្តទាំងអស់កុំភ្ញាក់ផ្អើល ព្រោះមេរបស់សមមិត្តត្រូវក្បត់ហើយ ឥឡូវគេចាប់ហើយ សូមសមមិត្តនៅស្ងៀមស្ងាត់ កុំមានផ្ទុះកាំភ្លើងអី"។

**ស៖** តើលោកចាំទេ មានវត្តមានអ្នកដែលចូលរួមនោះប៉ុន្មាននាក់ដែរ?

[១៥:៤៧:២៤]

**ឆ៖** ជំនាន់នុ៎ងឃើញចូលរួម ខ្ញុំអត់ចាំដែរ ព្រោះការរឹកហ្នឹង ខ្ញុំនៅអង្គុយក្រោយ ព្រោះខ្ញុំនៅក្រោយគេ មើលមិនច្បាស់ដែរ នៅអង្គុយក្រោយគេ ព្រោះខ្ញុំក្មេង គេឲ្យអង្គុយក្រោយ គេធំៗគេឲ្យអង្គុយមុខ។ ជំនាន់ហ្នឹងខ្ញុំនៅអាយុប្រហែលប្រាំបី ប្រាំបួនដណ្ដប់។

**ស៖** តើលោកមានបានស្ដាប់ឮគេចាក់ខ្សែអាត់ឲ្យស្ដាប់ដែរទេ?

**ឆ៖** ជំនាន់នុ៎ង ប្រធានកងពលខាង៥០២ ខាងនីរតីហ្នឹង គេចាប់មេខ្ញុំហ្នឹង ថាប្រធានកងពល៣១០ហ្នឹង ឈ្មោះ អឿន ហ្នឹងគេចាក់ខ្សែអាត់សំឡេង អឿន ហ្នឹងឲ្យស្ដាប់ ថាប្រុងផ្ទុះវ៉ៃភ្នំពេញហ្នឹង ឮសំឡេង អឿន ហ្នឹងនិយាយនៅក្នុងខ្សែអាត់ហ្នឹង។ ហើយខ្ញុំក៏អង្គុយស្ដាប់ហ្នឹងទៅ តែតាំងពីនុ៎ងមក មកទាល់ឥឡូវហ្នឹង ក៏ខ្ញុំភ្លេចអស់ខ្លះ ច្រើនដែរ មិនមែនបាននិយាយអស់ ព្រោះភ្លេចច្រើន។

**ស៖** តើលោកដឹងទេ នៅក្នុងកិច្ចប្រជុំនុ៎ង គេមានលើកឈ្មោះ កុយ ធួន យកមកនិយាយដែរទេ?

**ឆ៖** គេលើកដែរ តែខ្ញុំអត់បានទៅចាប់ភ្លឹកអី ព្រោះគិតតែពីរឿងនៅក្នុងពលហ្នឹងគេប្រុងថាចាប់មេហើយ ភ័យខ្លួន ខ្លាចគេចាប់បន្តទៀត អត់សូវមានយកចិត្តទុកដាក់អី។

**ស៖** តើលោកនៅនឹកឃើញថា កុយ ធួន, អឿន និងអ្នកដទៃទៀត បានធ្វើអ្វីដែរទេ? តើនៅក្នុងកិច្ចប្រជុំហ្នឹង គេមាននិយាយលម្អិតថា អឿន, កុយ ធួន និងអ្នកដទៃទៀតហ្នឹង បានធ្វើអ្វីខ្លះដែរទេ?

**ឆ៖** ជំនាន់នុ៎ងដែរ ទាស់ខ្ញុំភ្លេចទៅ ព្រោះអត់ចាំ ព្រោះពីនុ៎ងមកឥឡូវភ្លេចអស់ហើយ។

**ស៖** ខ្ញុំត្រឡប់មកសួរអំពីប្រធានបទនេះឡើងវិញ ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំសូមចូលនិយាយអំពីការចាប់ខ្លួនលោកផ្ទាល់តែម្ដង។ តើគេចាប់ខ្លួនលោកហ្នឹងក្រោយកិច្ចប្រជុំនៅក្នុងសាលារៀនដែលលោកបានស្ដាប់ខ្សែអាត់នោះ ឬក៏ការចាប់ខ្លួនលោកហ្នឹង គឺចាប់មុនខ្លួនមុនកិច្ចប្រជុំនេះ?

[១៥:៥០:៣០]

**ធ៖** បាទ គេឲ្យទៅកន្លែងមន្ទីររៀងៗខ្លួន គេថា “កុំឲ្យមានការភ្ញាក់ផ្អើល អ៊ីចឹងទៅកន្លែងធ្វើការងាររៀងៗខ្លួន សមមិត្តអញ្ជើញទៅរៀងៗខ្លួន”។ ហើយក៏ទៅ ទៅកន្លែងខ្ញុំហ្នឹងវិញ ក៏គេចាប់ផ្តើមចាប់មេខ្ញុំបណ្តើរ ហើយក៏ខ្ញុំក៏អត់បានចាប់ភ្លឹក ថាអ្នែគេចាប់ទៅណាដែរ គេថា ដកផ្លាស់ទៅធ្វើការនៅខាងថ្មីទៀត។ ហើយខ្ញុំក៏មិនបានចាប់ភ្លឹកដែរ ស្មានតែមេខ្ញុំផ្លាស់តទៅទៀត។ ហើយក៏បន្ទាប់មក ក៏បានគេចាប់ស្មៀន ចាប់ហៅខ្ញុំទៅដែរ ហៅទៅដល់កន្លែងមន្ទីរការិយាល័យគុកហ្នឹង ឈ្មោះ អុល។ ហើយក៏ខ្ញុំអត់ចាប់ភ្លឹកថា គេយកមកកន្លែងគុកទេ គេថា គេដកខ្ញុំមកធ្វើពេទ្យប្រចាំព្យាបាលខាងអន្តរជាតិ។

**ស៖** បើខ្ញុំយល់មិនច្រឡំទេ គឺថាលោក ក្រោយកិច្ចប្រជុំនេះ គេបាននាំខ្លួនលោក គឺយកមកកាន់ <មន្ទីរគុក> គឺថាក្រោយពេលគេចាក់ខ្សែអាត់ឲ្យលោកស្តាប់ហើយ។ អ៊ីចឹងលោកដឹងទេ ការចាប់ខ្លួនលោកនេះ បើប្រៀបធៀបទៅនឹងកិច្ចប្រជុំហ្នឹងវាមានរយៈពេលប៉ុន្មានមក ទើបគេបញ្ជូនលោកមក?

**ធ៖** ប្រហែលជាប់កន្លះខែដែរ។ គេធ្វើអត់ឲ្យដឹងខ្លួន។ គេចាប់បណ្តើរៗ កងពលហ្នឹង គេចាប់បណ្តើរៗ ខ្ញុំក៏ស្មានតែគេផ្លាស់ទៅនៅវរៈនេះ វរៈនោះ អត់មានថា គេចាប់ខ្លួនយកទៅដាក់គុកដាក់អីទេ។ ហើយខ្ញុំក៏គេចាប់មក កន្លែងហ្នឹង ក៏អត់មានចាប់ភ្លឹកថា គេចាប់មកដែរ ស្មានតែគេផ្លាស់មកដែរ។

[១៥:៥២:៤៦]

**ស៖** ខ្ញុំសូមលើកយកកំណត់ហេតុស្តាប់ចម្លើយរបស់លោកមកសួរលោកគឺ ឯកសារE3/7877 លោកប្រធាន ERN <អង់គ្លេស> គឺ 00346979, ខ្មែរ 00342437, បារាំង 00411785។ នេះគឺអ្វីដែលលោកបានឆ្លើយ ហើយខ្ញុំនឹងសួរលោកបន្តបន្ទាប់មកទៀត។ លោកបានឆ្លើយថា៖ “ខ្ញុំក៏ត្រូវបានគេចាប់ខ្លួន។ បងនឹម ដែលជាអនុប្រធាន ថាមានគេហៅទូរស័ព្ទមកភ្នំពេញ តម្រូវឲ្យខ្ញុំត្រូវផ្លាស់ប្តូរទីកន្លែងមកធ្វើការនៅភ្នំពេញ។ នៅពេលនោះខ្ញុំនៅឯអន្លង់ក្ងាន<។> កាលហ្នឹងមានឡានឃ្លុបបិទជិត គឺឡានបួនគុណាបួនរបស់អាមេរិកាំងហ្នឹង មិនមានស្លាកលេខទេ <មកយកយើងទៅ>។ ពេលឡើងលើឡាន គេមិនបានចងខ្ញុំទេ។ ពេលទៅដល់បឹងបាយ៉ាបនេះ ឡានបានដឹក<>បន្ថែម<បុរស>ពីរនាក់ទៀត។” តើលោកនៅចាំទេ ថាលោកបានឆ្លើយអ៊ីចឹងទៅមន្ត្រីស៊ើបអង្កេតរបស់តុលាការនេះ?

**ធ៖** ពេលនុំង ខ្ញុំមកហ្នឹង គេដាក់មកហ្នឹងក៏មកហ្នឹងក៏ ជិះឡានមកហ្នឹង គេយកមកដាក់ហ្នឹងក៏គេយកទុកចោលហ្នឹងទៅ ក៏គេអត់មានថា ប្រើធ្វើអីៗ គេ ហើយក៏ខ្ញុំអត់ចាប់ភ្លឹកថា គេយកមកកន្លែងគុកអីដែរ ខ្ញុំក៏អត់មាន គេមិនទាន់បញ្ចូលទេ គ្រាន់គេយកមកឲ្យចាំមើលសង្កេតយើង។ ហើយខ្ញុំក៏មិនដឹងដែរ នៅ២ថ្ងៃ ៣ថ្ងៃទទួលមេខ្ញុំហ្នឹង មកបាត់ មកសុំខ្ញុំយកទៅវិញ ថាមិត្តភក្តិហ្នឹង គាត់មានខុសអី បាន

យកគាត់មកកន្លែងហ្នឹង។ ហើយបានខ្ញុំភ្ញាក់ខ្លួនថា អ៉ំអានេះ គេយកខ្ញុំមកកន្លែងចូលគុកតើ។ ខ្ញុំស្មានតែផ្លាស់មកហ្នឹង។ ហើយក៏មេខ្ញុំហ្នឹង សុំទៅវិញថា យកមិត្តភក្តិហ្នឹងទៅវិញ កុំទុកទៅកសាងខ្លួនថែមទៀត បើគាត់កសាងបាន បើមិនបាន អាហ្នឹងចាំយកគាត់មក។ បានខ្ញុំដឹងខ្លួនថា អូ ខ្ញុំមានកំហុសហើយ។

[១៥:៥៥:៣៧]

**ស៖** ឥឡូវខ្ញុំសួរលោកមួយដំណាក់កាលម្តង មួយដំណាក់កាលម្តង។ លោកបានឡើងជិះឡានលោកមកដល់មន្ទីរគុកនោះ ដំបូងតើលោកមាននៅចាំទេថា គេមានបានថតរូបលោកទេ? ហើយតម្រូវឲ្យលោកសរសេរប្រវត្តិរូបដែរឬទេ?

**ឆ៖** គេបានថត ឲ្យធ្វើប្រវត្តិរូប ធ្វើប្រវត្តិរូបសង្ខេបខ្ញុំហ្នឹង ហើយនិងថត។ ហើយខ្ញុំក៏អត់បានចាប់ភ្លឹកអីទេ ស្មានតែគេថតហ្នឹង ទុកធ្វើក្នុងដាក់ប្រវត្តិរូប។

**ស៖** តើលោកអាចរៀបរាប់អំពីផ្លូវដែលលោកធ្វើដំណើរ នៅពេលដែលគេចាប់ខ្លួនលោកនោះ រហូតមកដល់ពេលដែលលោកមកដល់មន្ទីរមួយ គេហៅថា មន្ទីរគុកហ្នឹង ដែលគេតម្រូវឲ្យលោកសរសេរប្រវត្តិរូប ហើយគេថតរូបលោកហ្នឹង? សូមលោកជួយរៀបរាប់បន្តិចមើល៉ ផ្លូវដែលលោកចេញដំណើរមករហូតដល់ហ្នឹង ផ្លូវណា?

**ឆ៖** ជំនាន់នុ៎ង ខ្ញុំវាចាំមិនច្បាស់ដែរ ព្រោះគេដាក់ក្នុងឡានឃ្លុបជិត ព្រោះឡាននុ៎ងរបស់អាមេរិកាំង អាកាត់កាត់អាមេរិកាំង ព្រោះគេដាក់វានេះជិត ព្រោះឲ្យមើលទៅមុខ វាអត់ច្បាស់ ព្រោះយើងអង្គុយបែរក្រោយ។

**ស៖** តើផ្លូវដែលធ្វើដំណើរនោះ នៅភ្នំពេញហ្នឹងមែនទេ?

**ឆ៖** នៅក្នុងភ្នំពេញហ្នឹង តែខ្ញុំអត់បានមើលឃើញ ព្រោះវានៅក្នុងឡាន ឡានគេជិត ឡានអាមេរិកាំងហ្នឹង អាកាត់កាត់អាមេរិកាំងហ្នឹង ឃ្លុំជិត មើលអត់ឃើញ។

**ស៖** នៅក្នុងកំណត់ហេតុស្តាប់ចម្លើយរបស់លោក លោកបានឆ្លើយថា នៅពេលដែលលោកទៅដល់កន្លែងនោះ មេអង្គភាពរបស់លោក បងឃិត គឺបាន -- បងយៀត បានមកដល់ <ហើយគាត់បានខ្សឹបប្រាប់លោកថា>៖ “តើលោកដឹងទេ កន្លែងនេះ គឺជាមន្ទីរគុកហ្នឹង ឬក៏អត់? ពីព្រោះថានៅពេលដែលលោកសរសេរប្រវត្តិរូបហើយអីហ្នឹង គឺគេថា គេនឹងនាំខ្លួនលោកចេញទៅហើយ។” លោកចាំទេថាលោកបានឆ្លើយអីចឹង?

[១៥:៥៨:៣១]

**ឆ៖** ខ្ញុំបានចាំ ថាកន្លែងហ្នឹងកន្លែងមន្ទីរគុកហើយ ដល់បានមេខ្ញុំនាំចេញទៅ គេឲ្យខ្ញុំទៅកសាង។ តែដល់ក្រោយមក គេចាប់មេខ្ញុំទៀតទៅ ខ្ញុំក៏គេថា ខ្ញុំហ្នឹងជាប់ខ្សែខ្មាំងដែរ ក៏គេយកខ្ញុំទៅនៅយើងឯខេត្តកំពង់ឆ្នាំង ធ្វើព្រលានយន្តហោះ ឲ្យទៅកាប់គាស់ធ្វើព្រលានយន្តហោះនៅខេត្តកំពង់ឆ្នាំង។

**ស៖** ចម្លើយរបស់លោកឆ្លើយជូនមជ្ឈមណ្ឌលឯកសារកម្ពុជា ERN ជាភាសាអង់គ្លេស 0025 1253, ខ្មែរ <00019646>, បារាំង 00291003។ លោកបាននិយាយថា លោកត្រូវបានគេចាប់ខ្លួន និងបញ្ជូនទៅមន្ទីរគុកទួលស្លែង គឺនៅក្នុងឯកសារ E3/7537។ តើធ្វើម៉េចបានលោកដឹងថា លោកនៅឯមន្ទីរគុកទួលស្លែងនោះ?

**ឆ៖** មិនទាន់ដឹងថាមន្ទីរគុកទេ ព្រោះដល់ ប៊ុអុល ហ្នឹងខ្ញុំដឹងថា គេអ្នកនេះហ្នឹងទៅគ្រប់គ្នា ចាប់ទៅ ឲ្យ តាអុល ហ្នឹងយកទៅ គឺថាត្រូវជាប់គុកហើយ ព្រោះគាត់ហ្នឹង វាធ្វើការការិយាល័យគុក។ ដល់អ៊ីចឹង ខ្ញុំទៅដល់កន្លែងនុ៎ង ខ្ញុំភ្ញាក់ខ្លួនថា អ៊ូ! អុល ហ្នឹងយកមក ប្រាកដជាជាប់គុកហើយ ព្រោះ មិត្តអុល ហ្នឹងគេអ្នកខាងចាប់ដាក់គុកដាក់ច្រវាក់ហ្នឹង។

**ស៖** ប៉ុន្តែខ្ញុំមិនយល់ថា ហេតុអ្វីបានជាលោកនិយាយថា វាជាមន្ទីរគុកទួលស្លែង? ម៉េចក៏លោកមិននិយាយថា អាចជាមន្ទីរគុកណាមួយ ុ<>ដែលជាកន្លែងគុកចំណុះឲ្យកងពលនោះទៅ?

**ឆ៖** ហ្នឹងចំណុះមន្ទីរគុកហ្នឹង គឺកាលណាចាប់កន្លែងហ្នឹង គឺគេប្រគល់ទៅកន្លែងគុកទួលស្លែង ដែល អុល ហ្នឹងត្រូវយកទៅ។ ហ្នឹងគឺជាចំណុះកងពល មន្ទីរគុកហ្នឹង។ គុកហ្នឹង ពីកងពលហ្នឹងយកទៅគុកទួលស្លែង។

**ស៖** លោកប្រធាន សុំការអនុញ្ញាតសួរសំណួរមួយចុងក្រោយ។ លោកសាក្សី តើលោកធ្លាប់ដែលបានទៅមើលគុកទួលស្លែងដែរឬទេ ក្រោយឆ្នាំ១៩៧៩? តើអគារនៅគុកទួលស្លែង ឬក៏បរិវេណជុំវិញគុកទួលស្លែង វាអាចជួយរំឭកដល់លោកថា វាជាគុកមួយដែលលោកធ្លាប់បានចូលនៅក្នុងឆ្នាំ១៩៧៧នោះ ឬក៏មិនមែនទេ?

**ឆ៖** ខ្ញុំអត់ដែលបានមកភ្នំពេញផង ព្រោះមិនដែលទៅឃើញផង ព្រោះធ្លាប់នៅតែជំនាន់នុ៎ងដល់នេះទៅ ៗរស់នៅតាមស្រុកកំណើតវិញ មិនដែលមកភ្នំពេញម៉េចផង។

[១៦:០២:១៤]

**ប្រធានអង្គជំនុំ៖**

បាទ ហើយសវនាការនៅថ្ងៃនេះ ដល់ពេលឈប់សម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ច

ដំណើរការសវនាការសម្រាប់ថ្ងៃនេះ ត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃអង្គារ ទី០៦ ខែធ្នូ ឆ្នាំ២០១៦ ដែលនឹងចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយសវនាការនៅថ្ងៃស្អែកនេះ អង្គជំនុំជម្រះនឹងធ្វើសវនាការស្ដាប់សក្ខីកម្មសាក្សី 2-TCW-920 តាមរយៈប្រព័ន្ធសោតទស្សន៍ និងមានសាក្សី នួន ត្រិច ជាសាក្សីបម្រុង សូមភាគីជ្រាប និងអញ្ជើញចូលរួមតាមពេលវេលាបានកំណត់នេះ។

អង្គជំនុំជម្រះអរគុណលោក នួន ត្រិច។ សវនាការស្ដាប់សក្ខីកម្មរបស់លោកក្នុងឋានៈជាសាក្សីនៅមិនទាន់ចាប់នៅឡើយទេ អង្គជំនុំជម្រះកោះអញ្ជើញលោក មកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែកទៀត ជាសាក្សីបម្រុង។

ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងបុគ្គលិកនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការជូនសាក្សីរូបនេះ វិលត្រឡប់ទៅកាន់កន្លែងដែលគាត់ស្នាក់នៅ និងឲ្យអញ្ជើញគាត់ត្រឡប់មកកាន់ ត្រឡប់មកកាន់ អ.វ.ត.ក នៅថ្ងៃស្អែក ក្នុងឋានៈជាសាក្សីបម្រុង។

ហើយបង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងពីរ ត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ និងបង្គាប់ឲ្យនាំខ្លួនគាត់ត្រឡប់ចូលរួមសវនាការនៅថ្ងៃស្អែក ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

*(សវនាការផ្អាកនៅម៉ោង ១៦:០៣ នាទី)*